# ជំនឿឥណ្ឌានិងជំនឿអ្នកស្រុកដើមនៅចម្ប៉ា

## បាឋកថាធ្វើនៅសារមន្ទីរ *Louis Finot* [១]

Paul Mus

បន្ទាប់ពីមានការស្រាវជ្រាវនៃអ្នកជំនាញផ្នែកបូពា៌សាស្ត្រ គឺលោក Bergaigne និងលោក Barth ព្រមទាំងក្រោយមកគឺ លោក Finot និង លោក Cœdès *(នេះពុំពោលពីលោក Pelliot ដែលជាអ្នកជំនាញខាងអារ្យធម៌ចិនផង)* នោះមក ប្រវត្តិសាស្ត្របុរាណនៃឥណ្ឌូចិនខាងត្បូងនិងខាងកើតអាចសង្ខេបមកដូចតទៅ៖ នៅវវាងដើមគ្រឹស្តសករាជ្យ សាសនាឥណ្ឌាបានពង្រីកវិសាលភាពខ្លួនមកចុងបូពា៌ប្រទេស ជាហេតុធ្វើឲ្យអារ្យធម៌បែបឥណ្ឌានោះរីកដុះដាលនៅអាណាចក្រផ្សេងៗ ដូចជាហ្វូណន, កម្ពុជា និងចម្ប៉ា ព្រមទាំងអាណាចក្រដទៃទៀតនៅឧបទ្វីបដាច់ចេញពីឥណ្ឌានិងនៅឥណ្ឌូណេស៊ី។

យើងត្រូវយល់ថាកាលពីជំនាន់ដែលអ្នកស្រាវជ្រាវចាប់ផ្តើមរុករកសិក្សាអំពីស្រុកខ្មែរ និងស្រុកចម្ប៉ា នៅផ្នែកទី២ នៃស.វ.ទី ១៩ ហើយចាប់ផ្តើមផ្សព្វផ្សាយទៅអឺរ៉ុបនោះ ជនទូទៅយល់ដឹងស្តួចស្តើងខ្លាំងណាស់ពីប្រទេសទាំងពីរនេះ។ ក្នុងរយៈពេលយ៉ាងយូរ គេច្រើនគិតថាប្រាសាទចាមផ្សេងៗ ដែលបានប្រទះឃើញគឺជាស្នាដៃខ្មែរ។ ជួនកាលចំណងជើងរូបប្រាសាទចាមខ្លះដាក់ថា "ប្រាសាទខ្មែរនៅអាណាម"។ សូម្បីតែសព្វថ្ងៃ ក៏ការច្រឡំច្របល់នេះនៅឃើញមានម្តងៗ។ ថ្វីត្បិតតែអ្នកប្រាជ្ញបូពា៌សាស្ត្រ Albel Bergaigne បានចាប់ផ្តើមផ្សព្វផ្សាយប្រវត្តិសង្ខេបនៃនគរចម្ប៉ាតាំងពីឆ្នាំ ១៨៨៨មកម្ល៉េះ។ ការសិក្សានោះធ្វើឡើងតាមទស្សនាវដ្តី Journal Asiatique ដោយផ្អែកទៅលើសិលាចារិក។ ក្នុងនោះមានផ្នែកមួយនិយាយពីសាសនាផង។ គាត់បានបង្ហាញថា ចាមបុរាណគោរពអទិទេពដូចជាព្រះឥសូរ, ព្រះនារាយណ៍ និងព្រះព្រហ្ម។ ឃើញថាកាលនោះ នៅប៉ារីស៍ គេស្គាល់នគរចម្ប៉ាគ្រាន់បើជាងនៅឥណ្ឌូចិនខ្លួនឯង។ នេះគឺមកពីសិលាចារិកសំខាន់ៗ ដែលផ្តល់ពត៌មានពីអតីតកាលនោះមានជាភាសាសំស្ក្រឹត។ ពីឆ្នាំ ១៨៨៤ ដល់ ១៨៨៧ ពោលគឺក្នុងពេលដែលលោក Aymonier ស្រាវជ្រាវរុករកនៅតំបន់តាមខ្លះនៃអាណាមភាគខាងត្បូង គេសិក្សាភាសាសំស្ក្រឹតតែនៅក្រុងប៉ារីស៍ប៉ុណ្ណោះ។ ដូច្នេះ លោក Aymonier គ្មានជម្រើសអ្វីក្រៅពីផ្ញើតសិលាចារិក ហើយផ្ញើរក្រដាសផ្តិតទាំងនោះទៅលោក Bergaigne ដោយចោះយកផ្នែកណាជាភាសាសំស្ក្រឹត រីឯខ្លួនលោកផ្ទាល់ប្រែផ្នែកណាដែលជាភាសាចាម។ លោក Bergaigne ធ្វើការបានផ្លែផ្កាត្រចះត្រចង់យ៉ាងណានោះ យើងដឹងគ្រប់គ្នាហើយ។ ឯកសារជាភាសាសំស្ក្រឹតឲ្យពត៌មានស្របគ្នានិងឯកសារចិនដែរ ធ្វើឲ្យយើងសន្និដ្ឋានថានៅចុងស.វ.ទី២ *(រវាងគ.ស.១៩២)* នគរចម្ប៉ាចាប់ផ្តើមមករកើតឡើង។ គប្បីយើងកុំភ្លេចថាម្តុំៗពេលនោះ បារាំងគ្រាន់ជាខេត្តមួយនៃអាណាច័ក្ររ៉ូមប៉ុណ្ណោះ។ ភាសាមួយដែលមានខ្សែស្រឡាយជាមួយភាសាក្រិចនិងឡាតាំងត្រូវគេចាប់ផ្តើមប្រើប្រាស់ ហើយមិនយូរមិនចាប់ គេចាប់សរសេរភាសានោះតាមឆ្នេរតំបន់ Nha Trang ដែលកាលនោះគេហៅជាសំស្ក្រឹតថា ស្រុក "កៅដ្ឋាន"។ នេះហើយប្រវត្តិអារ្យធម៌ឥណ្ឌា ដែលចាស់ជាងគេនៅឥណ្ឌូចិន។ គប្បីយើងយល់ថានៅជំនាន់នោះ មានទំនាក់ទំនងពាណិជ្ជកម្មធំៗ ព្រមទាំងនាវាចរច្រើនសណ្ឋានភ្ជាប់ឥណ្ឌាមកឆ្នេរសមុទ្រអាណាមរួចស្រេចមកហើយ។

---

[១] ចុះនៅក្នុង *Bulletin de l'École Française d'Extrême-Orient*, XXXIII, p.367-410។ ប្រែសម្រួលដោយ ស៊ីយ៉ុន សុភារិទ្ធ *(សូមអាន "កំណត់អ្នកប្រែ" នៅខាងក្រោយ)*។

ពេលដែលលោក Paul Doumer ចាត់តាំងលោក Finot ឱ្យគ្រប់គ្រង "សាលាបារាំងចុងបូព៌ា" គឺជាពេលដែលគេរៀបចំកម្មវិធីស្រាវជ្រាវជាពិសេសស្រាវជ្រាវខាងបុរាណវិទ្យា។ នាថ្ងៃទី១៦ ខែតុលា ឆ្នាំ១៨៩៩ លោក Finot អមដំណើរដោយលោក de Lajonquière ផង ចាកចេញពីព្រៃនគរឆ្ពោះទៅហាណូយ តាមផ្លូវគោក។ ជំនាន់នោះមធ្យោបាយគោកយ៉ាកណាស់ ដូច្នេះលោកចំណាយពេល៣ខែតាមបណ្ដោយឆ្នេរនោះ ដោយឈប់សិក្សាចុះបញ្ជីប្រាសាទនានាតាមផ្លូវ ព្រមទាំងសិក្សារូបចម្លាក់ផង។ លទ្ធផលបានមកគួរជាទីគាប់ចិត្តក្រៃលែង។ ពេលដែលមកដល់ហាណូយ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩០០ លោក Finot យល់ច្បាស់ថាទេពទាំងប៉ុន្មានដែលគេគោរពនៅឥណ្ឌា គឺគេស្គាល់ទាំងអស់នៅចម្ប៉ាសម័យបុរាណ។ លោកបានយកការ សិក្សានោះមកចុះក្នុងអត្ថបទឈ្មោះថា "La religion des Chams d'après les monuments" នៅក្នុងទស្សនាវដ្ដីយើងនេះ[២] នៅឆ្នាំ១៩០១។ ដោយសារការសិក្សានេះ យើងស្ទើរតែអាចអះអាងថា យើងអាចសរសេរប្រវត្តិសាស្ត្រឥណ្ឌាដោយផ្អែកតែលើឯកសារចាមប៉ុណ្ណោះ ត្បិតទាំងអទិទេព ទាំងទេពតូចតាចផ្សេងៗទៀតក៏មានស្ទើរតែទាំងអស់ នៅប្រទេសចម្ប៉ា។

ឥឡូវនេះយើងដើរតាមតម្រាយលោក Finot ម្ដង ហើយយើងចាប់ផ្ដើមសិក្សាសាសនាផ្សេងៗនៅចម្ប៉ា ដោយយករូបខ្លះៗមកពិនិត្យ។ រូបទាំងនេះយកទៅគួបផ្សំជាមួយសិលាចារិក គឺសុទ្ធសឹងជាប្រភពឯកសារដ៏សំខាន់បំផុត[៣]។

[ទីនេះកំពុងបញ្ចាំងរូប]

១. *ព្រះនារាយណ៍ (សារមន្ទីរ Louis Finot)*។ ទេពនេះឈរផ្អែកលើវង្វង់ជន្ទល់មួយរាងក្រចកសេះ, សក់រាងជាបំពង់, ដៃ៤, កេតនភណ្ឌ៖ សង្ខ័, ច័ក្រ, ដំបង។ ដៃស្ដាំខាងក្រោមកាន់វត្ថុរាងមូល ដែលពិបាកសម្គាល់ថាជាអ្វី ប៉ុន្តែដែលស្រដៀងគ្នានឹងវត្ថុដែល លោក Cœdès *(សូមមើលសៀវភៅគាត់ឈ្មោះ Bronzes khmers)* ស្នើថាជាផ្លែឈើឬរុក្ខអ្វីមួយដែលព្រះនារាយណ៍ប្រទានទៅសាសនិករបស់ព្រះអង្គ។

២. *ព្រះគណេសទ្រង់ឈរ (សារមន្ទីរ Tourane)*, ដៃបួន *(ក្នុងនោះពីរខូចខាតហើយ)*, ដៃឆ្វេងខាងក្រោមកាន់ភាជន៍មួយដែលប្រមោយមុជចូលទៅក្នុងនោះ, ដៃស្ដាំខាងលើកាន់ផ្កាំ, មានពស់ពាត់ឈៀង, ភ្នែកទី៣ ចំកណ្ដាលថ្ងាស, ភ្លុកមានតែម្ខាងទេ គឺនៅស្ដាំ។

៣_៤. *ព្រះស្កន្ទ (សារមន្ទីរ Tourane)*, ទ្រង់ឈរ, លើក្ងោកដែលពុងត្រដាងស្លាបជារាងក្រចកសេះ, ដៃ២, ដៃស្ដាំកាន់ផ្លែរទ្ទះពីរ *(រូបលេខ៣)*។

៥. *ប្រាជ្ញាបារមី ឬ តារា (សារមន្ទីរ Tourane)*

រូបមួយក្រុមនេះទាក់ទងទៅនឹងសាសនាទាំងបីដែលប្រទេសចម្ប៉ាធ្លាប់កាន់។ រូបទី១ ដែលខ្ញុំបានបង្ហាញនោះគឺព្រះនារាយណ៍តែម្ដង រីឯព្រះគណេសនិងព្រះស្កន្ទគឺជាបុត្រ២អង្គនៃព្រះឥសូរ រីឯទេពីនោះគឺជាទេពីក្នុងព្រះពុទ្ធសាសនា។ លិទ្ធិនារាយណ៍និងពុទ្ធសាសនានោះ មាននាទីសំខាន់ណាស់នៅចម្ប៉ា។ បើពោលពីព្រះពុទ្ធសាសនា គឺគេបានប្រទះឃើញសិលាចារិកចាមនៅ Vo-canh ព្រមទាំងប្រាសាទយ៉ាងសំខាន់មួយ Dong-duong ដែលទាក់ទងនិងសាសនានោះ។ ប៉ុន្តែខ្ញុំចង់សង្កត់ធ្ងន់ទៅលើលិទ្ធិព្រះឥសូរ ត្បិតនេះជាសាសនាដែលសំខាន់ជាងគេនៅចម្ប៉ា។ គ្រាន់តែយកស្ថិតិមួយនេះមកគិតក៏គង់យល់ហើយ គឺថាក្នុងចំណោមសិលាចារិកសំខាន់ចំនួន ១២៨ នៅចម្ប៉ានេះ មាន២១ដែលពុំពោលពីទេពអ្វីមួយប្រាកដ ប៉ុន្តែ៩២ទាក់ទងទៅនឹងព្រះឥសូរឬទេពអ្វីមួយដែលនៅក្នុងលទ្ធិជាមួយគ្នា, ៣ទាក់ទងនឹងព្រះនារាយណ៍, ៥ទៅនឹងព្រះព្រហ្ម, ហើយ៧ទៅនឹងព្រះពុទ្ធ។ លំដាប់តទៅយើងនឹងឃើញបន្តិចម្ដងៗ ថាហេតុអ្វីបានជាលិទ្ធិព្រះឥសូរសំខាន់ជាងគេ។

ទេពទាំង៤ នេះសុទ្ធសឹងមាននាទីច្រើនបែបយ៉ាង រីឯបដិមាសាស្ត្រដែលទាក់ទងនោះ ក៏ពុំមែនជារឿងសាមញ្ញ។ ប៉ុន្តែចូរសង្កេតថា ក្បួនច្បាប់

---

[២] *Bulletin de l'École Française d'Extrême-Orient* ។

[៣] នៅទីនេះ យើងយកតែរូបចម្លាក់ដែលសំខាន់ខ្លាំងប៉ុណ្ណោះមកបង្ហាញ។



រូបលេខ១១ - បល្ល័ង្កថ្នាក់រូបស្រីរាំ( Tra-kieu)



រូបលេខ១២ - ព្រះឥសូរលុតជង្គង់



រូបលេខ១៣ - ព្រះស្កន្ទ



រូបលេខ២៤ - ព្រះកេសព្រះឥសូរ



រូបលេខ២៥ - ដងខ្លួនក្សត្រីមួយអង្គដែលគេទុកជាទេពី

បដិមាឥណ្ឌា គេគោរពទាំងស្រុង។ នៅឥណ្ឌាព្រះគណេសមានភ្លុកតែមួយទេ ហើយកាន់ភាជន៍មានបង្អែមមួយ ដែលព្រះអង្គចូលចិត្តសោយ ថ្វីត្បិតតែជាទេពដែលពោរពេញទៅដោយសុគតិក៏ដោយ។ ចំណុចតូចៗទាំងនេះ សុទ្ធសឹងមានសព្វគ្រប់នៅលើបដិមានៃសារមន្ទីរ Tourane ជាការបង្ហាញឲ្យឃើញថាទេពទាំងនោះ មានលក្ខណះបដិមាសាស្ត្រឥណ្ឌាពេញលេញ ហើយបើជនជាតិឥណ្ឌាណាមកឃើញក៏អាចស្គាល់ភ្លាមដោយគ្មានស្រពិចស្រពិល។

៦. *ព្រះកេសព្រះឥសូរ* (Mi-son) ៖ មានព្រះនេត្រទី៣នៅលើថ្ងាស, សក់ក្រងល្អិតហើយបួងជាគន្លាក់ៗឡើងលើ ដោយមានចំណិតព្រះចន្ទ្រនៅលើនោះផង (*រូបលេខ២៤*)។

បដិមាខាងលើនេះក៏ជាទេពឥណ្ឌា ៖ ភ្នែកនៅលើថ្ងាសព្រមទាំងសក់បួងស្លួចស្តើងឡើងលើនេះគ្រប់គ្រាន់នឹងឲ្យស្គាល់ថាជាព្រះឥសូរហើយ។ ប៉ុន្តែទម្រង់មុខគឺជាមុខចាម។ នៅក្នុងចំណោមអស់លោក មានអ្នកខ្លះធ្លាប់បានឃើញបណ្ឌិតចាមដែលធ្លាប់ធ្វើការជាមួយខ្ញុំអស់រយៈពេលពីរឆ្នាំនៅទីនេះហើយ។ អ្នកទាំងនោះច្បាស់ជាយល់ស្របជាមួយខ្ញុំថា មុខគាត់ស្រដៀងមុខបដិមាព្រះឥសូរនេះ។ យើងអាចពោលថាទេពឥណ្ឌាទាំងនោះប្តូរសញ្ជាតិ។ តទៅនេះ ខ្ញុំចង់បង្ហាញអំពីអារ្យធម៌ឥណ្ឌាដែលផ្សព្វផ្សាយទៅក្រៅដោយរក្សាទុកគំនិតមូលដ្ឋានដើមរបស់ខ្លួនផង ព្រមទាំងដោយបត់បែនទៅតាមបរិបទវប្បធម៌នៃប្រជាជាតិនីមួយៗផង។ ខ្ញុំនឹងបង្ហាញពីទេពីមួយចំនួន ដែលគេគោរពបូជានៅឥណ្ឌាផ្នែកកណ្តាល ចូងកាត់តាមឥណ្ឌាខាងត្បូងរហូតមកដល់ចម្ប៉ា។

៧.៨.៩. *យក្ខិណីនៅ* Sañci និង Mathura

១០. *នាងលក្ស្មីធ្វើពីសម្រិត (ឥណ្ឌាខាងត្បូង)*

១១. *បល្ល័ង្កដែលមានរូបស្រីរាំ* (Tra-kieu, *រូបលេខ១១*)

១២. *លំអិតរូបខាងលើនេះ*

១៣. *បដិមាមួយកំណាត់ឡើងលើនៃក្សត្រីមួយអង្គដែលគេទុកជាទេព (?)* (Hoa-quê, *រូបលេខ១៤*)

ទេពីទាំងនេះរស់រវើកព្រោះគេសាងឡើងដោយជំនឿ ដូច្នេះជីវិតនោះពុំផ្អែកលើក្បួនខ្នាតចម្លាក់ឬរឿងរ៉ាវទេពឥណ្ឌាសុទ្ធនោះឡើយ តែគឺឆ្លុះបញ្ចាំងពីទស្សនៈជនជាតិដែលឆ្លាក់នោះ។ នៅឥណ្ឌាកណ្តាល ទេពីមានមាឌធំ ថ្វីត្បិតតែមានសម្រស់សមសួន។

បើទេពីនៅតំបន់ Tamil មានរាងល្មមតល្មទ់ជាង រីឯនៅចម្ប៉ាគឺស្រឡូនទន់ភ្លន់ជាពន់ពេក។ ដូច្នេះជាតិសាសន៍បីឆ្លាក់ទេពឥណ្ឌាដែលបូជាដូចគ្នានោះ ក្រោមទិដ្ឋភាពបីខុសគ្នា។ ចំណុចដែលខ្ញុំចង់បញ្ជាក់ គឺថាចាមស្គាល់អារ្យធម៌ឥណ្ឌាល្អិតល្អន់ ប៉ុន្តែចាមពុំចម្លងយកមកទាំងស្រុងឡើយ។ តទៅនេះជារូបសត្វខ្លះដែលខ្ញុំយកមកដើម្បីជាឧទាហរណ៍។

១៤. *ស្វា (សារមន្ទីរ* Tourane*)*

*រូបស្វាតូចនេះឆ្លាក់ដូចធម្មជាតិខ្លាំងណាស់។ គេតែងប្រទះឃើញរូបរបៀបនេះញឹកញាប់ ជាហេតុឲ្យដឹងថាចម្ប៉ាសម័យបុរាណជ្រួតជ្រាបនិងរឿងរាមាយណ ដែលជាកាព្យតែងដោយវាល្មីកិ។ សង្ខេបរឿងនោះឲ្យខ្លីបំផុតមក គឺរាពណ៍ដែលជាស្តេចអសោរនៅកោះលង្កាចាប់នាងសីតាដែលជាមហេសីនៃព្រះរាមយកទៅ។ ព្រះរាមមិនគឺនរណាក្រៅពីព្រះនារាយណ៍ឡើយ ព្រោះត្រូវចុះមកលើដែនដីនេះដើម្បីកំចាត់រាពណ៍ចេញ។ ព្រះរាមចងសម្ព័ន្ធជាមួយក្រុមស្វា ហើយដោយសារមានជំនួយនោះហើយ ទើបសម្លាប់រាពណ៍យកកោះលង្កាហើយរំដោះនាងសីតាវិញបាន។ រូបបន្ទាប់នេះច្បាស់ជាទាក់ទងនឹងរឿង* Iliade *នៃអាស៊ីនេះហើយ។*

១៥. ស្វានិងអ្នកបាញ់ធ្នូ (សារមន្ទីរ Tourane)

លោក Claeys ដែលជាសហសេវិកខ្ញុំ បានរកឃើញសិលាចារិកភាសាសំស្ក្រឹតមួយ ពីស.វ. ទី១៧ ដែលខ្ញុំបានប្រែហើយ ហើយដែលនិយាយលើកតម្កើងសរសើរវាល្មីកិ។ ពុំតែប៉ុណ្ណោះពោលថា វាល្មីកិនេះជាអ្នកបង្កើតកំណាព្យសម្រាប់ទេវកថាផង។ ដូច្នេះឃើញថាកាព្យសំស្រ្កិតពុំមែនជារឿងចម្លែកចំពោះចាមឡើយ។ ប៉ុន្តែចម្លាក់ប៉ុន្មាននោះបង្ហាញថាចាមពុំគ្រប់គ្រាន់តែស្គាល់រឿងនៅជាទ្រឹស្តីឬជាអក្សរសាស្រ្តឡើយ។ ចូរពិនិត្យមើលរូបសិង្ហដែលមានលក្ខណៈជាចាមនេះ។

១៦. សិង្ហឈរជំទើត (Tra-kieu)

មើលទៅឃើញថាអ្វីៗសឹងតែខុសទាំងអស់ ហាក់បីដូចជាតួអង្គអ្វីមួយដែលពាក់មុខបន្លំខ្លួន។ នេះគឺមកពីជាងចម្លាក់នោះពុំមានសិង្ហឯណានិងចម្លងតាម ត្បិតគ្មានក្នុងធម្មជាតិ។ នៅរូបបន្ទាប់មកទៀត គឺផ្ទុយទៅវិញ សូមប្រៀបធៀបសិង្ហដែលនៅជ្រុងជាមួយដំរីដែលនៅកណ្តាល ហើយដែលហាក់ដូចរស់រវើក។

១៧. បល្ល័ង្កឆ្លាក់រូបដំរី (មកពី Hà-trung, សារមន្ទីរ Tourane)

រូបដែលទើបនឹងបង្ហាញទាំងប៉ុន្មាននេះ បញ្ជាក់ថាចាមទទួលគំនិតអ្វីៗមកពីឥណ្ឌាមែនពិត តែយកមកបត់បែនតាមផ្នត់គំនិត ឬបទពិសោធន៍ផ្សេងៗដែលជារបស់ខ្លួនផ្ទាល់។ ចំណុចនេះគប្បីចងចាំ ត្បិតនឹងជួយឲ្យយើងយល់ពីចំណុចផ្សេងៗទៀត កាលណាយើងពិនិត្យវិស័យសាសនាក្នុងពេលបន្តិចទៀត។

បដិមាសាស្រ្តដែលសម្បូណ៌ហើយមានច្រើនបែបយ៉ាងនេះ បង្ហាញថាជំនឿផ្សេងៗពីឥណ្ឌាបានចូលមកចាក់ស្រេះនៅទីនេះ។ តាមពិតទៅក្នុងរយៈពេល ប្រមាណមួយពាន់ពីររយឆ្នាំ សាសនាផ្លូវការនៃប្រទេសចម្ប៉ាជាសាសនាបែបឥណ្ឌា ឬក៏អាចថាជាសាសនាឥណ្ឌាតែម្តងផង។

តើស្ថានភាពបច្ចុប្បន្ននេះយ៉ាងដូចម្តេចដែរ? ការស្រាវជ្រាវដំបូងដែលមានទាំងប៉ុន្មានបង្ហាញថា អារ្យធម៌ចាមបុរាណនោះ នៅសល់តិចតួចស្តើង។ ការសិក្សាទាំងមូលទៅលើជំនឿជនជាតិចាមនាបច្ចុប្បន្ននេះ ហើយដែលមានជម្រៅជាងគេ គឺអត្ថបទ របស់លោក Aymonier នៅក្នុងទស្សនាវដ្តី Revue de l'histoire des Religions ចេញផ្សាយនៅឆ្នាំ១៨៩១ ក្រោមចំណងជើងថា Les Tchames et leurs religions។ ស្នាដៃរបស់លោក Aymonier នេះ ត្រូវបានលោក Cabaton និងលោក Durand ធ្វើបន្តមកទៀត។ ចំពោះជនជាតិចាមសព្វថ្ងៃ បដិមាដែលមានជាកម្រនៅតាមប្រាសាទខ្លះ ហើយថែមទាំងបាក់បែកផងនោះ គេយល់ថាជាព្រះរាជាឬក្សត្រផ្សេងៗពីសម័យបុរាណដែលគេចាត់ទុកដូចជាទេព។ ឧទាហរណ៍ នៅ Phanrang លិង្គព្រះឥសូរដែលនៅក្នុងតួប៉មក្រហមនេះក្លាយទៅជាស្តេចដែលមានតែនៅក្នុងរឿងព្រេង ហើយដែលមានព្រះនាមថា Po Klauṅ Garai។ ហេតុនេះហើយការសិក្សាអំពីជនជាតិចាមដែលចុះផ្សាយនៅក្នុងទស្សនាវដ្តី Bulletin de l'École Française d'Extême-Orient នៅឆ្នាំ១៩២១នោះ ពោលដាច់ណាត់ថា ការគោរពបូជានៃជនជាតិចាមសព្វថ្ងៃនេះ “លែងមានទំនាក់ទំនងអ្វីទាំងអស់ទៀតហើយជាមួយសាសនាឥណ្ឌាពីបុរាណ ព្រោះតំណែលដែលនៅសេសសល់សុទ្ធសឹងតែគេយល់ខុសឬយល់ឃ្លាងឃ្លាតពីភាពដើម”។ តទៅនេះខ្ញុំនឹងបង្ហាញថាការវិនិច្ឆ័យនេះដូចជាដាច់អហង្ការពេក។

ចំណុចនេះមានសារៈសំខាន់ណាស់ ព្រោះបើគេយល់ គេអាចឃើញថាអារ្យធម៌ឥណ្ឌាបានចាក់គ្រឹះរឹងមាំព្រមទាំងបន្តឥទ្ធិពលទៅវែងឆ្ងាយទៀត។ ប្រសិនបើជនជាតិចាមបានបោះបង់ចោលដាច់ស្រឡះនូវសាសនារដ្ឋដែលខ្លួនធ្លាប់កាន់ជាច្រើនសតវត្សនោះ បានសេចក្តីថា ចាមពីដើមមកគ្រាន់តែទុកថាសាសនារដ្ឋនោះជាសម្បកក្រៅតែប៉ុណ្ណោះ។ ក្នុងន័យនេះតើសាសនានោះមានតែស្រទាប់វណ្ណៈខ្ពស់ប៉ុណ្ណោះទេដែលកាន់ឬយ៉ាងណា? ផ្ទុយទៅវិញ ប្រសិនបើគេប្រទះឃើញស្លាកស្នាមនៃសាសនាបុរាណនោះនៅក្នុងប្រពៃណីបច្ចុប្បន្ន ទោះជាវិចវិលឬលំអៀងឃ្លាងឃ្លាតក៏ដោយក៏គេអាចមានដានថា សាសនាឥណ្ឌាដែលជនជាតិចាមបុរាណកាន់នោះ ចាក់ឫសជ្រៅទៅក្នុងអារ្យធម៌របស់ខ្លួន។

យ៉ាងណាក៏ដោយយើងត្រូវតែចោទសួរថា ឥទ្ធិពលឥណ្ឌាដែលវាតទីមកលើឥណ្ឌូចិននោះជាអ្វីពិតប្រាកដ? តើជំនាន់នោះ អារ្យធម៌ឥណ្ឌា

ដែលផ្សព្វផ្សាយមកលើអារ្យធម៌ខ្មែរនិងចាម មានរូបភាពជាអ្វី? បើយើងយកសិលាចារឹកភាសាសំស្ក្រឹតដែលនៅតាមឆ្នេរសមុទ្រប្រទេសចម្ប៉ាមកពិនិត្យ ឃើញថាឥទ្ធិពលនោះជាឥទ្ធិពលឥណ្ឌាប្រភេទខ្ពស់ ហើយដែលមានទំនាក់ទំនងជាប់ស្អិតនឹងអារ្យធម៌ឥណ្ឌូ-អឺរ៉ុបផង។ ប្រការនេះត្រូវតែយើងពិនិត្យឱ្យបានហ្មត់ចត់ជាងសព្វមួយដង ថ្វីត្បិតតែយើងអាចអះអាងថា ប្រភេទអារ្យធម៌ដែលទើបនឹងពោលមកនេះបាត់បង់អស់ទៅហើយនៅក្នុងវង្វង់ជនជាតិចាមសព្វថ្ងៃ ដែលនៅសល់តែប៉ុន្មានម៉ឺននាក់ប៉ុណ្ណោះ។

ប៉ុន្តែសំនួរទាំងប៉ុន្មានខាងលើជាការត្រឹមត្រូវពិតប្រាកដឬទេ? គប្បីយើងគិតថា ឥណ្ឌាពុំមែនមានន័យត្រឹមតែព្រហ្មញ្ញាសាសនា ព្រមទាំងភាសាសំស្ក្រឹតប៉ុណ្ណោះឡើយ។ យើងពុំអាចជៀសវាងពុំគិតអំពីប្រភពនៃអារ្យធម៌ឥណ្ឌានោះទេ បើពុំដូច្នោះយើងច្បាស់ជាពង្រួញអារ្យធម៌នៃប្រទេសមួយទាំងមូលឱ្យមកនៅត្រឹមតែជាបណ្ណាល័យមួយប៉ុណ្ណោះ។ អារ្យធម៌ឥណ្ឌាពុំអាចសង្ខេបមកនៅត្រឹមតែអ្វីៗដែលចែងនៅក្នុងអក្សរសាស្ត្រសំស្ក្រឹតប៉ុណ្ណោះឡើយ។ ថ្វីត្បិតតែអក្សរសាស្ត្រនោះមានកិត្តិនាមធំធេង យើងមិនត្រូវភ្លេចថាអារ្យធម៌ឥណ្ឌូ-អឺរ៉ុបនោះក៏ជាចំណែកផ្សេងៗដែលសំខាន់ដែរពោលគឺជាចំណែកអារ្យធម៌ដែលចេញមកពីអ្នកស្រុកសាមញ្ញផ្ទាល់តែម្តង។

ជាដំបូងយើងនឹងពិនិត្យត្រួសៗទៅលើស្រទាប់វប្បធម៌ដែលពុំទាន់ទទួលឥទ្ធិពលពីពួក "អារ្យ", បន្ទាប់មកឥទ្ធិពលអារ្យ , ហើយបន្ទាប់មកទៀតការលាយចូលគ្នារវាងវប្បធម៌ទាំងពីរ។ ជាការសន្មត់យើងហៅថា "ហិណ្ឌូ" ដោយសំដៅទៅលើស្រទាប់វប្បធម៌ដែលមានការលាយចូលគ្នារវាងវប្បធម៌ឥណ្ឌាដើមនិងឥទ្ធិពលឥណ្ឌូ-អឺរ៉ុប។

## ប្រទេសឥណ្ឌាមុនសម័យ "អារ្យ" និងអាស៊ីក្រោមរបបមូសុង

កាលពីជំនាន់ដែលកុលសម្ព័ន្ធវេទចាប់ផ្តើមចូលមកអាស៊ីខាងត្បូង ដោយឆ្លងកាត់តាមប៉ែកពាយព្យនៃប្រទេសឥណ្ឌានោះ តើអ្នកទាំងនោះបានជួបនឹងអ្វីខ្លះ? ជំនាន់ដែលយកមកនិយាយនេះ គឺនៅរវាងសហសវត្សទី២មុនគ្រឹស្តករាជ្យ បើមុនឬក្រោយបន្តិចបន្តួចក៏គ្មានសារៈសំខាន់អ្វីដែរនៅទីនេះ។ តើសំនួររបៀបនេះអាចមានន័យដែរឬទេ បើយើងយកទៅដាក់ក្នុងបរិបទប្រវត្តិសាស្ត្រសម័យនោះ? ហើយតើជំនាន់នោះជនជាតិ "អាស៊ី" ដែលពួកឥណ្ឌូ-អឺរ៉ុប (កុលសម្ព័ន្ធវេទ) ពើបប្រទះ ស្ថិតនៅក្នុងអារ្យធម៌តែមួយបែបឬយ៉ាងណា? ក្នុងប្រការនេះយើងដឹងច្បាស់ថា អាស៊ីពេលនោះមានជាតិសាសន៍ចំរុះគ្នាសន្ធឹកសន្ធាប់ ថ្វីត្បិតតែយើងពុំមានទិន្នន័យក្បោះក្បាយពីជាតិសាសន៍ទាំងនោះក្តី។ ក្រៅពីអារ្យធម៌ដែលហៅថា Civilisation de l'Indus ជនជាតិទាំងនោះឥតមានសរសេរទុកអ្វីឡើយ ម្យ៉ាងទៀតធាតុអាកាសនៅតំបន់នោះពុំមានអំណោយផលក្នុងការរក្សាទុកវត្ថុធាតុអ្វីផងក្រៅពីប្រភេទថ្ម ជាហេតុធ្វើឱ្យកំណាយក្នុងបុរាណវិទ្យាពុំបានផល។ តែយ៉ាងណាក៏ការសិក្សាលើប្រទេសឥណ្ឌានិងប្រទេសចិនផ្តល់មកឱ្យយើងនូវទិន្នន័យមួយចំនួនជាមូលដ្ឋានដែរ។ បើយកទៅគួបផ្សំជាមួយទិន្នន័យដែលបានមកពីជាតិពន្ធុវិទ្យា យើងអាចឃើញដានខ្លះៗនៃការគ្រប់គ្រងសង្គមនិងសាសនានៃជនជាតិទាំងឡាយនោះ កាលពីសម័យដែលពុំទាន់ប្រើប្រាស់អក្សរ។ ដូច្នេះយើងអាចគូសវាសចេញជាភិនភាគនៃសង្គមទាំងនោះ កាលជំនាន់ដែលទ្រឹស្តីព្រាហ្មណ៍នឹងទ្រឹស្តី "ខុងចឺរ" (Confucius) ពុំទាន់ជ្រួតជ្រាបចូល។ លោក Sylvain Lévi និងលោក Przyluski បានត្រួសត្រាយផ្លូវឱ្យយើងបានស្គាល់វប្បធម៌ឥណ្ឌា កាលមុនពួកអារ្យចូលមក។ រីឯលោក Granet ក៏បានជួយយើងឱ្យមានពន្លឺខ្លះអំពីវប្បធម៌ចិនបុរាណ ដែលជាវប្បធម៌ប្រជាជនសាមញ្ញ ពោលគឺក្រៅពីវប្បធម៌អ្នកបណ្ឌិត។

ការសិក្សាស្រាវជ្រាវដែលមានមកទាំងប៉ុន្មាន ជួយសម្រួលឱ្យយើងមុជឆ្ងាយតទៅទៀត ហើយសព្វថ្ងៃនេះយើងអាចពោលដោយត្រួសថា ពីសម័យកាលចាស់យូរលង់មកហើយនោះ មានអារ្យធម៌មួយក្រុមដែលប្រហាក់ប្រហែលគ្នា ហើយដែលលាតសន្ធឹងនៅលើទឹកដីដ៏ធំមួយ ដែលគេអាចរាប់បញ្ចូលប្រទេសឥណ្ឌា, ឥណ្ឌូចិន, ឥណ្ឌូណេស៊ី, ផ្នែកមួយនៃទ្វីប Océanie, ព្រមទាំងភាគខាងត្បូងនៃប្រទេសចិនផង។ អារ្យធម៌មួយក្រុមនោះ ពុំមែនដូចគ្នារហូតដល់ទៅមានឯកភាពក្នុងទស្សនៈពូជសាសន៍នោះឡើយ។ តែទោះបីយ៉ាងណាក៏មានភាពប្រហាក់ប្រហែលគ្នា ក្នុងវិស័យជំនឿដែលយើងនឹងយកមកពីគ្រោះគ្នាក្នុងពេល នេះដែរ។

ទំហំទឹកដីដ៏ធំធេងខាងលើនេះ ពុំមែនជាឧបសគ្គអ្វីមួយឡើយ។ ជាតិពន្ធុវិទ្យាពីមុនមកច្រើនតែធ្វើឱ្យយើងយល់ថា អ្នកនៅដីគោកគ្មានទំនាក់ទំនងជាមួយអ្នកនៅកោះ។ តាមពិតទៅ កុលសម្ព័ន្ធមនុស្សនីមួយៗរស់បាន ដោយការផ្លាស់ប្តូរទូទាត់ផ្សេងៗប្រព្រឹត្តទៅបានក្នុងភាពងាយស្រួល

ទោះបីខ្សែស្រឡាយនានានៅដាច់ឆ្ងាយពីគ្នាខ្លាំងក៏ដោយ។ បើលើផែនទី ជួនកាលឃើញក្រុមជនជាតិមនុស្សពីរដាច់ស្រឡះពីគ្នាឆ្ងាយ ឬក៏នៅជិតគ្នាបង្កើយ។ ប៉ុន្តែជួនកាលហាក់បីដូចជាការភាន់ភ្នែកប៉ុណ្ណោះ ព្រោះជួនកាលសមុទ្រមួយដែលមើលលើផែនទីទៅ ឃើញថាញែកជាតិសាសន៍ឱ្យដាច់ចេញពីគ្នានោះ តាមពិតភ្ជាប់ជាតិសាសន៍ទាំងនោះទៅវិញក៏មាន។ ឧទាហរណ៍គេអាចនិយាយអំពី "អារ្យធម៌មេឌីទែរាណេ" (Civilisation méditerranéenne)។ ចម្ងាយ ១០០, ២០០, ១.០០០ គ.ម តាមផ្ទៃសមុទ្រ (ជាពិសេសបើរបបខ្យល់មានអំណោយផល) អាចងាយឱ្យមនុស្សប្រាស្រ័យទាក់ទងគ្នាជាង១០០, ២០០, ១.០០០ គ.ម លើដីគោក ប្រសិនបើភូមិសាស្ត្រដីនោះសម្បូណ៌ទៅដោយភ្នំ, ព្រៃ ឬក្រុមមនុស្សប្លែកៗដែលធ្វើឱ្យខ្លាចដូចក្នុងករណីឧបទ្វីបឥណ្ឌូចិន ឬក៏តំបន់ Dekkan កាលជំនាន់ដើម។ នៅតំបន់ណាដែលនាវាចរប្រព្រឹត្តទៅបានស្រួល ធ្វើឱ្យមានទំនាក់ទំនងទៀងទាត់រវាងក្រុមមនុស្សផ្សេងៗ គេតែងឃើញថាអារ្យធម៌ក្រុមមនុស្សផ្សេងគ្នានោះបង្កើតជាឯកភាពមួយ។ នេះពុំមែនជារឿងប្លែកអ្វីឡើយ។ បើពោលថា "ជំនឿសាសនាតំបន់មូសុង" គឺពិតជាមានន័យជាងពាក្យថា "សាសនាឥណ្ឌា", "សាសនាចិន" ចំពោះជំនាន់ដែលឥណ្ឌាឬចិនពុំទាន់រឹងប៉ឹងថ្កុំថ្កើងជាអារ្យធម៌ធំនោះ។ ប្រសិនបើការសិក្សាទៅលើពិធីផ្សេងៗដែលទាក់ទងនឹងរដូវ ហើយដែលធ្វើឡើងជាពិសេសដោយលោក Przyluski និងលោក Granet នឹងកាន់តែល្អិតល្អន់ទៅទៀតនោះ ប្រហែល ជាទៅអនាគតយើងអាចពោលអំពី "សាសនាតំបន់មូសុង" ហើយ។

នៅទីនេះគួរយើងប្រើពាក្យថា "ជីវចល" (animisme) ដើម្បីសំដៅងាយស្រួលទៅលើជំនឿចាស់ ដែលមានជាយូរអង្វែងមកហើយនៅតំបន់មូសុងនេះ។ ខ្ញុំប្រើពាក្យនេះដើម្បីងាយស្រួលរៀបរាប់ប៉ុណ្ណោះ ពុំមែនក្នុងន័យល្អិតល្អន់ មានព្រំដែនច្បាស់លាស់ដូចអ្នកខ្លះនិយមប្រើឡើយ។ តាមរយៈពាក្យថាជីវចលនេះ ខ្ញុំគ្រាន់តែចង់និយាយថា កាលពីសម័យយូរលង់មក ក្រុមមនុស្សដែលរស់នៅទឹកដីប្រទេសឥណ្ឌា, ឥណ្ឌូចិន, ព្រមទាំងប៉ែកខាងត្បូងនៃប្រទេសចិនតែងជឿទៅលើភូតផ្សេងៗ ដែលធ្វើឱ្យវត្ថុឬទីកន្លែងនានាមានជីវិត ដូចជាអមនុស្សដែលគ្មានរូប, ភូតដែលរស់នៅតាមទឹក ឬតាមព្រៃព្រឹក្សានានា។ល។ ម្យ៉ាងទៀតអ្នកទាំងនោះជឿថាមនុស្សគ្នាឯងមួយចំនួនចេះមន្តវិជ្ជានិងប្រើសិល្បសាស្ត្រផ្សេងៗ។ ថ្មីៗនេះបព្វជិត Cadière ពោលអំពីពួកយួននៅអាណាមថា "សាសនាពិតប្រាកដនៃពួកយួនអាណាមគឺការគោរពភូត។ សាសនានេះកំណត់ប្រវត្តិដើមពុំបានឡើយ ត្បិតមានដើមកំណើតចេញឡើងជាមួយជនជាតិនោះតែម្តង។ កន្លែងណាក៏មានភូតដែរ។ ភូតទាំងនោះសុទ្ធសឹងចេះហោះយ៉ាងលឿន ឬក៏ធ្វើដំណើរតាមផ្លូវព្រៃ ឬតាមផ្លូវទឹកផង។ ជួនកាលលាក់ខ្លួនតាមផ្លូវទឹក ក្នុងក្រហែងថ្ម ឬក្នុងបឹងបួរផ្សេងៗ។ ពួកវាចូលចិត្តរស់នៅច្រកជ្រលងជួរភ្នំអាណាម ឬមួយក្នុងព្រៃជ្រៅដែលគួរឱ្យខ្លាច។ បើពុំនោះកំពូលភ្នំ ឬក៏ផ្ទាំងសិលាធំៗដែលរាំងផ្លូវទឹក មួយវិញទៀតថ្មយ៉ាងសាមញ្ញមួយដុំក៏សុទ្ធសឹងជាលំនៅស្ថានរបស់ពួកវាដែរ។ រីឯឈើដែលមានមែកសាខា ក៏អាចជាជម្រកនៃសត្វខ្លះ ដែលអាចថ្លឹងឫទ្ធិអំណាចឬអនុភាពពីពួកវាផង"។ សូមកុំភ្លេចថា ពាក្យមួយវគ្គនៃបព្វជិត Cadière នេះគ្រាន់តែជាការបង្រួញសង្ខេបមកឱ្យខ្លីជាទីបំផុតនូវការសិក្សាលំអិតទៅលើប្រភេទភូតនីមួយៗ ដែលលោកបានធ្វើរួចមកហើយ។

នេះគ្រាន់តែពោលឱ្យស្រួលស្តាប់ថា ប្រជាជននោះជឿលើអ្វីខ្លះ។ ស្តាប់ទៅហាក់បីដូចគ្រាប់តែជាការរៀបរាប់ទេសភាពតំបន់មួយដែលមានភ្នំនិងត្រពាំងបឹងបួរប៉ុណ្ណោះ។ ជំនឿលើភូតផ្សេងៗនោះតាមពិតទៅគ្របដណ្តប់លើអ្វីៗទាំងអស់ បីដូចជាគេពិពណ៌នាលោកយើងនេះដោយយកពណ៌ច្រើនស្អេកស្កះមកលាបលន។

ប៉ុន្តែប្រការដែលថា ភូតទាំងអម្បាលមាណមាននៅគ្រប់ទីកន្លែងច្រកល្ហកនោះ គ្រាន់តែជាផ្នែកមួយនៃជីវចលប៉ុណ្ណោះ រីឯផ្នែកមួយទៀតគឺជំនឿថា បើធ្វើកិច្ចផ្សេងៗបានត្រឹមត្រូវ គេអាចនឹងអន្ទងយកភូតនោះមកបាន ឬមួយអាចធ្វើឱ្យភូតនោះសប្បាយ ហើយទោទន់ចិត្តមករកយើង ឬក៏បញ្ចៀសភូតនោះឱ្យឃ្លាតឆ្ងាយពីយើង។ តាមពិតទៅការយកចិត្តយកថ្លើម ឬការបញ្ចៀសជាគូនឹងគ្នា ហើយនេះជាកិច្ចដែលពពួកគ្រូអូមអាមតែងប្រព្រឹត្ត។ តាមការសូត្រអន្ទងរបស់គ្រូទាំងនោះ យើងឃើញថាទីណាដែលមនុស្សរស់នៅឬឆ្លងកាត់ សុទ្ធសឹងតែជាទីទាំងឡាយដែលពពួកភូតរស់នៅដែរ។ នេះមកអំពីជំនឿលើភូតគឺអាស្រ័យទាំងស្រុងទៅលើទំនាក់ទំនងជាមួយមនុស្ស។ ពុំដែលគេជឿលើភូតណាមួយដែលគ្មានទំនាក់ទំនងអ្វីសោះជាមួយមនុស្សឡើយ។ វត្តមាននៃភូតទាំងឡាយ តាមពិតទៅជាកាឆ្លុះបញ្ចាំងបញ្ហាទាំងឡាយរបស់មនុស្ស។

ក្នុងចំណោមភូតនានាដែលគេស្គាល់ គឺភូតដែលគ្រប់គ្រងដី ដែលមានសារៈសំខាន់ជាងគេ។ ការគោរពបូជា ព្រមទាំងទំនងទំនងរវាងភូតនោះជាមួយសហគមន៍ដែលពាក់ព័ន្ធ មានភាពពិសេសខ្លាំងណាស់ បើយើងសង្កេតមើលទៅជាតិសាសន៍នៃអាស៊ីដែលរងរបបមូសុង។ លោក Ed. Chavannes បានស្រង់ឃ្លាមួយអំពី "ក្បួនពិធី "(Livre des rites) ថា៖ "ទេពនៃដីគឺជាថាមពលផ្សេងៗនៃដីដែលគេបូជា"។ អត្ថន័យនេះអាចយកទៅអនុវត្តបានវែងឆ្ងាយហួសស្រុកចិនទៅទៀត ពោលគឺតំបន់ធំធេងដែលយើងកំពុងនិយាយនេះ។ នៅទីណាក៏ដោយ ទេពឬភូតនៃដី (dieu du sol) សុទ្ធសឹងឆ្លុះបញ្ចាំងពីជំនឿថា ដីមានសក្តានុពលភាព អាចបង្ករភោគផលព្រមទាំងចិញ្ចឹមសត្វធាតុ។ ជំនឿនេះមានភាពទូលំទូលាយវែងឆ្ងាយលើស

ពីជីវចលទៅទៀត។

“គោរពថាមពលដី ហាក់បីដូចជាទេព” ជាគំនិតមួយជ្រៅណាស់ ត្បិតទេពឬភូតណាមួយពុំមានលក្ខណៈរាងកាយចម្លងតាមភិនភាគរាងកាយមនុស្សឡើយ។ ថាជាទេពក៏មិនត្រឹមត្រូវ ព្រោះមិនមែនជាអមនុស្ស (ក្នុងន័យថាជាភូតអ្វីមួយដែលមានអនុភាពលើសមនុស្ស តែទ្រង់ទ្រាយមុខមាត់ចម្លងតាមមនុស្ស)។ មូលដ្ឋាននៃជំនឿនោះពុំផ្អែកលើមនុស្សទេ គឺផ្អែកលើព្រឹត្តការណ៍ឬបាតុភូតផ្សេងៗ។ យូរៗទៅព្រឹត្តការណ៍ឬបាតុភូតនោះមានរូបមនុស្សមកភ្ជាប់ជាមួយ បានសេចក្តីថាមានជំនឿលើទេពដែលមានរាងកាយមុខមាត់យកគំរូតាមមនុស្ស ហើយដែលជាទេពប្រចាំដី ឬតំបន់ណាមួយ។ ប៉ុន្តែនៅដំណាក់កាលដែលខ្ញុំយកមកពិចារណានេះ គឺដីឬតំបន់នោះឯងតែម្តងដែលជាទេព។ គឺទេពដែលមិនចម្លងតាមមនុស្ស ដែលគ្មានរាងកាយមុខមាត់ ហើយដែលកំណត់ដោយតែទីតាំងប៉ុណ្ណោះ។ ជំនឿរបៀបនេះ យើងឃើញមានជានរហូតមកដល់សាសនាធំៗដែរ។ នៅក្នុងសាសនាធំៗ គេនិយាយពីកន្លែង ឬភូមិដ្ឋានជាទីសក្ការៈដែលមនុស្សទៅបូជា, ភូមិដ្ឋានដែលមានទេពកាន់កាប់, ដែលមានបដិមាដើម្បីឱ្យមនុស្សងាយបូជាព្រមទាំងងាយទាក់ទង។

ដូច្នេះពេលនេះយើងយកសាសនាធំៗនៅអាស៊ីទុកមួយអន្លើសិន ហើយយើងទៅពិនិត្យមើលឬក៏ខំតាមដានជំនឿមួយប្រភេទ នៅសម័យកាលណាមួយដែលកំណត់មិនបាន ហើយដែល “ទេពនៃដី” តាមពិតទៅគឺជាដីនោះតែម្តង។ លុះដល់ពេលដែលយើងយកការគោរពបូជាដូនតា (culte des ancêtres) មកពិនិត្យ យើងនឹងយល់ច្បាស់ជាងនេះបន្តិចម្តងៗ។ អំពីទេពនៃដីនោះ។ តែជាដំបូងបង្អស់ ខ្ញុំចង់បំភ្លឺចំណុចមួយសិន។ ជំនឿលើទេពដែលជាដីនោះ ពុំមែនជាលក្ខណៈវិនិច្ឆ័យថាជាជំនឿមុនដំបូងបង្អស់នៃមនុស្សលោកឡើយ។ ខ្ញុំយល់ថាជាដំណាក់កាលនៃជំនឿមួយពាក់ព័ន្ធទៅនឹងដីដែលមុននឹងឈានចូលមកដល់សាសនាធំៗ។ ទេពនោះគ្មានរូបរាងអ្វីពិតប្រាកដឡើយ ហើយនេះពុំមានន័យថា ដោយសារជាជំនឿដំបូងបង្អស់បានជាមនុស្សមានការស្រពិចស្រពិលទេ តែផ្ទុយទៅវិញគឺជាលទ្ធផលនៃដំណើរយ៉ាងវែងមួយ។ ជំនឿនេះទាក់ទងទៅនឹងការគ្រប់គ្រងដីធ្លីព្រមទាំងរបៀបរបបដែលទាក់ទងនៅនឹងដីធ្លីនោះ។

នៅក្នុងការបូជាប្រភេទនេះ មនុស្សតែងចោទសួរថា ធ្វើដូចម្តេចទាក់ទងទៅនឹងទេពបាន, ធ្វើដូចម្តេចឱ្យទេពនេះដឹងពីកង្វល់ ឬចំណង់ ឬសំណូមពរនៃសហគមន៍ដែលរស់នៅលើដីនោះ បើទេពគ្មានរូបរាងដូច្នេះ?។ ម្ខាងគឺជាទេពដែលប៉ះ ឬទាក់ទងមិនបាន ឯម្ខាងទៀតគឺជាសហគមន៍មនុស្សដែលគោរពទេពនោះ។ ជំនឿដែលចាស់យូរលង់នេះ ពុំមានរៀបចំជាទ្រឹស្តីសំខាន់ៗដូចជានៅក្នុងសាសនាធំៗឡើយ។ សាសនាណាក៏ដោយ កិច្ចដែលប្រើមន្តអាគមណាមួយក៏ដោយ សឹងតែមានបំណងឱ្យមនុស្សនិងទេពទាក់ទងឆ្លើយឆ្លងគ្នាបាន។ បានសេចក្តីថាទេពនោះមានភ្នែកអាចមើលមនុស្សឃើញ, មានត្រចៀកអាចស្តាប់ពាក្យ បន់ស្រន់របស់មនុស្សឮ។

មានមធ្យោបាយមួយដែលគេជឿថាអាចធ្វើទៅបាន គឺជាការបូជាមនុស្សទាំងរស់។ ប្រការនេះមានការបកស្រាយច្រើនបែបច្រើនយ៉ាងណាស់ដែលច្រើនតែខុសផង តាំងពីបុរាណកាលមកដល់បច្ចុប្បន្ននេះ។ យើងត្រូវប្រុងប្រយ័ត្នក្នុងការបកស្រាយ ត្បិតអីការបូជាមនុស្ស ពីក្រុមមួយទៅក្រុមមួយអាចមានន័យខុសគ្នា។ ក្នុងជំនឿនៃតំបន់ដែលយើងកំពុងសិក្សានេះ អត្ថន័យមានច្បាស់លាស់។ មនុស្សដែលត្រូវបូជា ពុំមែនគេចាត់ទុកថាជាអាហារឬក្រយ៉ានៃទេពទេ ត្បិតទេពពុំមែនជាភូតដែលស៊ីសាច់មនុស្សឡើយ។ អ្នកដែលត្រូវគេបូជានោះគ្រាន់តែជារូប ឬទីពំនាក់អាស្រ័យនៃទេព ក្នុងមួយពេលកិច្ចពិធីនោះ។ ទេពដែលទទេ គ្មានរូបរាង ពេលនោះទៅចាប់រូបរាងតាមរយៈអ្នករងគ្រោះនោះឯង ធ្វើឱ្យមនុស្សទាក់ទងជាមួយបាន។ នៅជំនាន់ដើម ចិនដែលមានបណ្តាស័ក្តខ្ពស់ តែងសូត្រពាក្យសម្បថភក្តីភាពនៅមុខទេពនៃដី (dieu du sol) ដែលជាប្រធានសាក្សី។ ពេលនោះគេយកមនុស្សម្នាក់មកបូជាទាំងរស់ ពុំនោះទេយកសត្វមកជំនួសក៏បាន។ គេសូត្រពាក្យសម្បថនោះខ្លាំងៗនៅមុខបណ្តាជន ដោយមានភាជន៍មួយនៅពីមុខ ក្នុងនោះមានត្រចៀកមួយដែលគេកាត់មកពីជនរងគ្រោះ (អ្នកដែលគេត្រូវបូជា)។ គ្មានអ្វីគួរឱ្យច្ងល់ទេ ត្រចៀកនៅពេលនោះ គេចាត់ទុកថាជាត្រចៀកទេព ដែលធម្មតាពុំដឹងរូបរាងជាអ្វីនោះ។ ជនរងគ្រោះឲ្យត្រចៀកទៅទេពខ្ចី។ លុះគេពិឃាតនឹងកប់ទៅក្នុងដីហើយ ជននោះហាក់ដូចជាក្លាយជាទេពនោះតែម្តងក្នុងរយៈពេលវែងឬខ្លីណាមួយ។

ក្រៅពីពេលធ្វើកិច្ចបូជានោះ តើទេពនៅតែជាទទេឥតរូបរាងដដែលឬយ៉ាងណា? តាមមើលទៅប្រហែលជាពុំមែនដូច្នោះឡើយ។ ប្រហែលជាពីយូរយាមកហើយ គេចាត់ទុកជាវត្ថុអ្វីមួយដែលមានរូបរាងជាតំណាង ប៉ុន្តែដែលពុំមានជារូបរាងមនុស្សជាទីសំគាល់។ ថាមពលដីដែលគេគោរពជាទេពនោះ គេសំគាល់ថាផ្តុំគ្នាមកនៅក្នុងដើមឈើណាមួយ ឬក៏នៅក្នុងថ្មណាមួយដុំ ដែលគេដាក់នៅក្រោមដើមឈើនោះ។ ខ្ញុំយល់ថា គេនិយមយកដុំថ្មមកជាតំណាងទេព ដោយសារជាការងាយស្រួលសម្រាប់កិច្ចពិធី។ ដុំថ្មនោះងាយស្រួលនឹងចាក់ទឹកស្រោចស្រប់។ ស្រោចស្រប់លើដុំថ្មនោះ គឺស្រោចស្រប់លើផ្ទៃដីដាំដុះទាំងមូល ដែលថ្មនោះជាតំណាង។

មិនតែប៉ុណ្ណោះ ភ្ជាប់ទៅនឹងការគោរពដើមឈើឬថ្មនោះ គេតែងប្រទះឃើញជំនឿអំពី "ថ្មដុះ" ដោយគេជឿថាថ្មនោះមានចលនា ព្រមទាំងរីកធំទៅៗ។ ដូច្នោះហើយក៏ហៅថា "ថ្មអ្នកតា" *(pierre-génie)* តែម្តង។ គេជឿលើថ្មដុះនោះដោយប្រៀបធៀបទៅនឹងរុក្ខជាតិដែលរីកធំឡើងៗ។ តែទីនេះមិនមែនជារឿងធម្មជាតិទេ គឺជាបាតុភូតហួសពីធម្មជាតិទៅទៀត។ ដុំថ្មនោះគេជឿថាជានិមិត្តនៃថាមពលដីភូមិករដែលអ្នកស្រុករស់នៅ។ អ្នកស្រាវជ្រាវខ្លះសង្កេតឃើញថា ជួនកាលជំនឿថ្មដុះនោះមានមូលដ្ឋានដែលជាបាតុភូតធម្មជាតិ គឺថាជួនកាលមានឫសឈើធំ មកចាក់រុលផ្ទាំងថ្មមួយឲ្យលេចចេញកាន់តែខ្លាំងឡើងពីដី។ ទោះជាដោយប្រការណាមួយ ក៏យើងឃើញថាការគោរពថ្មនោះមានពាក់ព័ន្ធទៅនឹងការគោរពដើមឈើដែលនៅក្បែរ ពីព្រោះឫសដែលចេះតែរីកលូតទៅនោះបង្កឲ្យផ្ទាំងថ្មលេចចេញពីដី។ តាមស្មានមើលទៅប្រហែលជាដោយហេតុនេះហើយ បានជាគេយល់ថាថ្មនោះជាទីប្រមូលផ្តុំសសៃសរសូងនៃថាមពលដីភូមិករ។

ប្រការដែលថាអនុភាព ឬថាមពលដីដែលសហគមន៍មនុស្សទាំងមូលរស់នៅទីនោះ មករួមផ្តុំគ្នានៅក្នុងថ្មមួយដុំ ឬមួយផ្ទាំង ធ្វើឲ្យអ្នកស្រុកគិតថាមានទេពឬភូត ឬកម្លាំងអ្វីមួយ ដែលមានជីវិត ប៉ុន្តែដែលគ្មានរូបរាងអ្វីមួយច្បាស់។

សូមកុំយល់ច្រឡំថា ថ្មនោះជាទីអាស្រ័យឬជាលំនៅនៃទេព។ ថ្មនោះជាទេពតែម្តង ត្បិតទេពនិងថ្មនោះរលាយចូលគ្នា។ ដូច្នេះពុំមែនជា "ថ្មនៃអ្នកតា" ទេ គឺជា"ថ្មអ្នកតា"។ បើយើងវិភាគជំនឿនេះ យើងឃើញថា មានប្រការបីលេចចេញឡើង៖ ប្រការទេព, ប្រការមនុស្ស, និងកិច្ចពិធីសម្រាប់ឲ្យមានទំនាក់ទំនងរវាងទេពនិងមនុស្ស។ ដុំថ្មនោះគឺជាថាមពលដីសុទ្ធសាធ ដែលគេលើកតំកើងមកជាទេព។ ដីនោះគឺជាដីភូមិករនៃសហគមន៍មួយក្រុម។ គេត្រូវរកវិធីអ្វីមួយ ដើម្បីធ្វើឲ្យមនុស្សនិងទេពមានទំនាក់ទំនងគ្នា។ ដូច្នោះទេពដែលគ្មានរូបរាងប្រាកដនោះ ត្រូវតែរកវិធីយ៉ាងណាធ្វើឲ្យចេញជារូបរាងមនុស្ស ក្នុងរយៈពេលមួយវែងឬខ្លីដើម្បីឆ្លើយឆ្លងគ្នា។ ជួនកាលគេបូជាមនុស្សឬសត្វ ហើយក្នុងពេលនៃកិច្ចពិធីបូជានោះ មនុស្សឬសត្វដែលគេបូជាចាត់ទុកថាជាទេពតែម្តង ព្រោះហាក់ដូចជាប្រគល់ខ្លួនឲ្យទេពមកសន្ថិត ដោយសារទេពនោះគ្មានរូបរាង, គ្មានមុខមាត់, ត្រចៀក, ច្រមុះអ្វីទាំងអស់។ ជួនកាលទៀតវិធីដែលធ្វើឲ្យមនុស្សនិងទេពទាក់ទងគ្នាបាន គឺសហគមន៍មនុស្សបញ្ជូនសមាជិកណាម្នាក់របស់ខ្លួន ដើម្បីធ្វើជាស្នងឬនិមិត្តនៃទេព។ សមាជិកនោះច្រើនជាអ្នកសាសនា ឬបើពុំនោះទេជាមេ ឬប្រធាននៃក្រុមមនុស្សទាំងមូលតែម្តង។

សង្ខេបមកគឺថា ទេពខ្លួនឯងផ្ទាល់គ្មានរូបរាងអ្វីទាំងអស់។ គេពុំអាចប៉ះពាល់បាន, ពុំអាចស្ទាបបាន, ពុំអាចមើលឃើញ ពោលគឺពុំអាចទាក់ទងបាន។ ដូច្នេះហើយបានជាមនុស្សរិះរកបង្កើតកិច្ចពិធីផ្សេងៗ ដើម្បីឲ្យទំនាក់ទំនងនោះធ្វើឡើងបាន។ រឿងទេពគឺជារឿងដី ហើយរឿងដីនោះជាកង្វល់របស់មនុស្ស ដោយសារមនុស្សត្រូវទាញភោគផលពីដី។ នៅក្នុងសាសនាធំៗក៏ជំនឿ ជាមូលដ្ឋាននេះពុំបាត់បង់ទៅណាដែរ។

សាសនាធំៗក៏តែងត្រឡប់មកធ្វើកិច្ចដែលជាលក្ខណៈនៃជំនឿជីវចល ដូចទើបនឹងពោលមកនេះ។ គេធ្លាប់អះអាងឬជឿថា "វិញ្ញាណ" នៃទេពស្ថិតនៅក្នុងថ្មនោះ ហើយចូលមកសន្ថិតនៅក្នុងខ្លួនមនុស្សស្នងដែលពោលមកមុននេះ។ ដូច្នេះគេជឿថា ទេពលាក់ខ្លួននៅក្នុងថ្ម ហើយថ្វីត្បិតតែយើងមើលពុំឃើញ ក៏យើងគិតថាទេពនោះមានទម្រង់រាងកាយដូចមនុស្ស។ អាស្រ័យហេតុនេះ រូបរាងដូចមនុស្សដែលមើលពុំឃើញនោះ ចូលមកក្នុងខ្លួនរូបស្នង ក្នុងរយៈពេលកិច្ចពិធី។ ប៉ុន្តែចំពោះដំណាក់កាលជំនឿដែលខ្ញុំកំពុងលើកឡើងនេះ គំនិតរបៀបនោះពុំទាន់ច្បាស់ថាដូច្នោះឡើយ ប្រហែលជាគេយល់ផ្សេងទៅវិញ។ ពុំមែនទេព (ឬ "អ្នកតា") ទេ ដែលរំកិលខ្លួនចេញពីដីទៅនៅក្នុងរូបស្នង, ពុំមែនទេពដែលជាថាមពលដីនោះទេ ដែលរំកិលខ្លួនចេញពីដីទៅនៅក្នុងរូបមនុស្សដែលគេបូជា។ មានន័យថា ពុំមែនជាការរំកិលឬប្តូរទីកន្លែងឡើយ គឺវត្តមាននោះមានពីរស្របគ្នា *(bi-présence)*។ ថ្មនោះនៅតែជាទេពដដែល ប៉ុន្តែក្នុងរយៈពេលនៃកិច្ចពិធី ទេពនោះជារូបស្នងព្រមជាមួយគ្នាផង។ ប្រការនេះពុំចោទជាបញ្ហាអ្វីទាំងអស់ ព្រោះទេពនៅតែរមួតស្អិតជាសាច់មួយជាមួយថ្មនោះ ដោយគ្មានរើរុះទៅណាក្នុងពេលណាមួយឡើយ។ ប៉ុន្តែទេពដដែលនេះមាននិម្មិតក្រោមរូបភាពផ្សេងៗទៀត ពោលគឺនិមិត្តជារូបរាងកាយ តាមរយៈរូបរាងកាយនៃរូបស្នង ក្នុងរយៈពេលនៃកិច្ចពិធី។ រីឯរូបស្នងដែលជាតំណាងនៃសហគមន៍ទាំងមូលពេលនោះ ហាក់បីដូចជាស្ថិតនៅចន្លោះមនុស្សនិងទេព។ ជាធម្មតាមនុស្សនិងទេពនោះពុំអាចទាក់ទងគ្នាបានឡើយ ប៉ុន្តែក្នុងរយៈពេលកិច្ចពិធី ទេពនិងសហគមន៍មនុស្សនោះរលាយចូលគ្នា តាមរយៈរូបស្នងនោះឯង។

ពេលនេះចូរយើងក្រឡេកមើលមកសាសនាធំៗម្តង ដូចជាពុទ្ធសាសនា, ព្រហ្មញ្ញសាសនា, សាសនាដែលកាន់នៅប្រទេសចិន។ ទំនាក់ទំនងដែលពោលមកអម្បាញ់មិញរវាងទេពដែលជាថាមពលនៃដី (ហើយដែលគ្មានរូបរាងអ្វីទាំងអស់) និងមនុស្ស មិនប្រាសចាកពីមូលដ្ឋានជីវចលខាងលើនេះឡើយ គ្រាន់តែមូលដ្ឋាននេះបង្កើតជាទ្រឹស្តីលំអិតតទៅទៀត។ នៅជំនាន់ដែលប្រទេសឥណ្ឌានិងប្រទេសចិនថ្កុំថ្កើង ហើយអារ្យធម៌លេចធ្លោចេញមករៀងៗខ្លួននោះ គឺពេលនោះហើយដែលចាប់ផ្តើមមានការគោរពបូជាទីកន្លែងជាទីសក្ការៈ ហៅថាបូជណីយដ្ឋាន។ ឧទាហរណ៍ភ្នំ ឬបុរី

ផ្សេងៗ។ បើមើលតែមួយត្រួសទៅ ឃើញថាភ្នំឬបុរីនោះមានភាពសក្ការៈដែលជារបស់ខ្លួនផ្ទាល់។ ទោះបីជាមានការដូរសាសនា ពោលគឺដូរជំនឿពីទេពមួយទៅទេពមួយ ក៏បូជណីយដ្ឋាននោះឥតមានរង្គោះរង្គើ។ អាចពោលម្យ៉ាងទៀតថា ភាពសក្ការៈនោះពុំមែនស្ថិតនៅលើទេពប៉ុន្មានឡើយ គឺស្ថិតនៅលើបូជណីយដ្ឋានតែម្តង។ ក្នុងទស្សនៈនេះ តើអ្នកលោកយល់ថា ជំនឿលើថាមពលដីដែលមាននៅក្នុងជីវចលនោះ ពុំមាននៅក្នុងសាសនាធំៗឬយ៉ាងណា?

ខ្ញុំបាននិយាយពីខាងលើមកថា សហគមន៍មនុស្សតែងបញ្ជូនសមាជិកណាម្នាក់ឲ្យតំណាងខ្លួន ហើយសមាជិកនោះក៏ស្នងឲ្យទេពនោះ ក្នុងរយៈពេលកិច្ចពិធីដែរ។ ម្យ៉ាងទៀតសមាជិកដែលជាស្នងនោះ ច្រើនតែជាមេឬប្រធាននៃសហគមន៍អ្នកស្រុកទាំងមូល។ អាស្រ័យហេតុនេះ “និមិត្តនៃថាមពលដី” ជានិមិត្តនៃទេពផង និងមេឬប្រធាននោះផង ព្រោះទាំងអស់នេះរលាយចូលគ្នា តាមរយៈរូបស្នងនោះ។ បានសេចក្តីថា មេឬប្រធាននៃសហគមន៍ជាឧបករណ៍សំរាប់ភ្ជាប់ទៅទេព ហាក់បីដូចជាប្រតិភូរបស់ទេពនោះដែរ ដើម្បីធានាឱ្យមានភាពសម្បូណ៌សប្បាយនៃសហគមន៍ទាំងមូល។ ខ្ញុំពុំមែនអះអាងថាគេផ្តល់កិត្តិយសឲ្យមេឬប្រធានសហគមន៍ ចាប់តាំងពីពេលដែលគេបង្កើតកិច្ចពិធីទាក់ទងនឹងថាមពលដីនោះទេ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា នៅទីនេះគេលើកតំកើងមេនោះ ដោយសារជារូបស្នងនៃទេព។

ដូច្នេះឃើញថាក្រុមមនុស្សនីមួយៗតែងខ្វល់ខ្វាយ តែងតាំងនរណាម្នាក់ឲ្យជាតំណាងខ្លួន ដើម្បីអាចប្រាស្រ័យទាក់ទងគ្នាបានជាមួយទេពដែលគ្មានរូបរាងអ្វីសោះ ដោយសារគ្រាន់តែជាថាមពលដី។ តាមរយៈមេឬប្រធាននោះ ដីដែលជាទេព ព្រមទាំងសហគមន៍អ្នកស្រុក អាចពោលបានថារលាយចូលគ្នា។ ប៉ុន្តែគួរជ្រើសរើសនរណាឲ្យតំណាងសហគមន៍ឲ្យបានសមរម្យ ហើយឲ្យមានប្រសិទ្ធិភាពជាទីបំផុត? ឃើញថាមានតែដូនតាដែលស្លាប់ទៅហើយនោះទេ ត្បិតខ្លួនអ្នកទាំងនោះកប់រលាយចូលក្នុងដីហើយស្រាប់។ ដូច្នេះហើយបានជាមេកើយនៃសហគមន៍ ហើយដែលស្លាប់យូរយាមកហើយនោះតែងក្លាយទៅជា “អ្នកតា” ពោលគឺជីដែលជាមនុស្សដែលគេអន្ទងឡើងនៅក្នុងកិច្ចពិធីផ្សេងៗ។ មេកើយនិងដីភូមិករ ហាក់ដូចជារលាយចូលគ្នាតែម្តង។

ខ្ញុំបាននិយាយហើយថា ប្រការនេះមានភាពសាំញ៉ាំណាស់។ ដីគ្មានរូបរាងអ្វីពិតប្រាកដអ្វីទាំងអស់ រីឯបញ្ហារបស់មនុស្ស គឺធ្វើយ៉ាងណាឲ្យមានទំនាក់ទំនងនិងដី ហើយបត់បែនដីនោះទៅតាមគំនិតរបស់ខ្លួន ពោលគឺបញ្ជាដីបាន។ ដើម្បីសម្រេចបំណងនេះ លុះត្រាតែដីមានលក្ខណៈជាមនុស្ស ក្នុងមួយរយៈពេលណាមួយ ដើម្បីឆ្លើយឆ្លងគ្នាបាន។ មានតែតាមរយៈរូបដែលជាតំណាងសហគមន៍នោះប៉ុណ្ណោះទើបធ្វើទៅបាន។ ដើម្បីឲ្យតំណាងនោះជាតំណាងជាប់លាប់ ហើយមានទំនាក់ទំនងស្អិតរមួតជាមួយដី គឺមានតែជ្រើសរើសតំណាងក្នុងចំណោមបុព្វការីជនដែលស្លាប់ទៅហើយ។ ប្រសិនបើទស្សនៈខ្ញុំនេះសមហេតុសមផល មានន័យថាមិនត្រឹមតែជាមេកើយទេដែលត្រូវស្នងសហគមន៍ គឺមេកើយនោះត្រូវស្នងឲ្យបុព្វការីជនទៅទៀត ត្បិតសហគមន៍ត្រូវការអន្ទងទេពនៃភូមិកររបស់ខ្លួនដែលអាចមើលឃើញ, ដែលអាចស្តាប់ឮ, ពោលគឺដែលមានលក្ខណៈរាងកាយដូចមនុស្សមានត្រចៀក និងភ្នែកជាដើម។

នៅក្នុងអារ្យធម៌ចិន ការគោរពបូជាទេពនៃដីប្រទេសចិនទាំងមូលក៏ជាឧទាហរណ៍មួយបញ្ជាក់ពីគំនិតខាងលើនេះដែរ គឺថាតែងតែមានបុព្វការីជនស្តេចណាមួយអង្គដែលគេរាប់បញ្ចូលថាជាទេពនោះ។ “រាប់បញ្ចូល” នោះមានន័យយ៉ាងដូចម្តេច? ពាក្យនេះពុំមានន័យថា មានការច្របូកច្របល់ ពុំស្គាល់ថាអ្វីជាបុព្វការីជន និងអ្វីជាទេពឡើយ។ លោក Chavannes យល់ថាគេគោរពបូជាបុព្វការីជន ព្រមទាំងទេពព្រមពេលជាមួយគ្នា ប៉ុន្តែក្នុងន័យថាជាភូតពីរដាច់ដោយឡែកពីគ្នា។ យោបល់នេះពុំត្រូវទេ តាមពិតគឺបុព្វការីជនរលាយចូលទៅក្នុងទេពនោះដូចលោក H. Maspéro បានបង្ហាញដូច្នោះមែន។ ប៉ុន្តែលោក H. Maspéro ពុំបានពន្យល់ទេថាទេពទាំងមូលនោះក៏រលាយចូលមកនៅក្នុងបុព្វការីជនមុនដែរ។ ការវិភាគដែលមើលទៅគ្មានអ្វីប្លែកនោះ គឺបុព្វការីជនផ្តល់រូបកាយ ឬមុខមាត់ឲ្យទេពដែលសហគមន៍នោះធ្លាប់តែគោរពបូជាតាំងពីដូនតាមក។ ក្នុងមួយរយៈពេលនោះ ពោលគឺរយៈពេលនៃកិច្ចពិធី បុព្វការីជនគឺជាទេពនោះឯង។ បុព្វការីជនជាទេពពេញទី ពោលគឺទេពពេញទីក្នុងមួយរយៈ។ ប៉ុន្តែទេពពុំមែនជាបុព្វការីជនពេញទីឡើយ ព្រោះទេពជាទេពគ្រប់ពេលវេលា។ ហេតុនេះហើយបានជានៅស្រុកចិន មានបុព្វការីជនដែលជាទេពនៃដី ដែលគេលែងរាប់រក ពោលគឺជាបុព្វការីជននៃសន្តតិវង្សដែលដាច់ពូជ ឬដែលរលត់រាជ្យ។ ម្នាក់ៗសុទ្ធតែបានឆ្លងអាយុកាលអស់ហើយ ព្រោះជាអ្នកដែលសន្តតិវង្សនីមួយៗចាត់ទុកថាជាបុព្វការីជនរបស់គេ ដូច្នេះដល់សន្តតិវង្សនោះរលត់ ពាក្យថា“បុព្វការីជន” នោះរលត់ទៅឯង។ រីឯទេពដែលជាទេពសុទ្ធគ្មានអ្វីមកលាយឡំនោះ គឺពុំអាចរលត់ឡើយ ព្រោះទេពនោះជាដី បានសេចក្តីថាជាដីមានមុនភូមិករសហគមន៍មនុស្សនោះទៅទៀត។ ប៉ុន្តែលក្ខណៈសម្បត្តិផ្សេងៗទៀតនៃទេពនោះ រលត់រលាយ កាលណាក្រុមមនុស្សដែលពាក់ព័ន្ធ (គ្រួសារ, សន្តតិវង្ស, ប្រជាជន) នោះរលាយ។

សេចក្ដីសង្កេតខាងលើនេះបង្ហាញថា មានការគោរពបូជាដែលមានដីជាមូលដ្ឋាននៅទីកន្លែងផ្សេងៗ ហាក់ដូចជាមាន "សូរិយោដី" ផ្នែកជំនឿមួយដូច្នោះ។ មួយកន្លែងៗគឺមេកើយនៃក្រុមមនុស្សផ្សាភ្ជាប់ដីនិងសហគមន៍ដែលពាក់ព័ន្ធគ្នានោះ។ នេះបើពោលពីលំហរភូមិសាស្ត្រ។ បើពោលពីកាលប្រវត្តិវិញ គឺក្រុមមនុស្សនិងដីដែលពាក់ព័ន្ធតែងផ្សាភ្ជាប់គ្នាយ៉ាងស្អិតរមួត ដរាបណាកិត្តិនាមនៃបុព្វការីជនដែលជាមេកើយនោះនៅតែមាន។ ច្បាប់ដីធ្លីនិងច្បាប់គ្រប់គ្រងសង្គមនៅបុរាណកាល ថ្វីត្បិតតែប្លែកៗគ្នាទៅតាមបរិបទសង្គមនិងសាសនា ហាក់ដូចជាចេញពីមូលដ្ឋានជំនឿនេះឯង។

ទំនៀមពិធីចិននិងយួនមានមូលដ្ឋានរបៀបនេះ។ ដើម្បីយល់អំពីទេពឬបុព្វការីជនរបស់អ្នកទាំងនោះ ទាល់តែយើងពិនិត្យមើលថា គេមានវត្ថុអ្វីមកប្រើប្រាស់ក្នុងការគោរពបូជា។ បន្ទះអសនៈដែលជនជាតិចិនឬយួនតែងតែដាក់នៅក្នុងផ្ទះគេនោះ គឺមានដំណែលពូជពង្សច្បោះត្រង់ទៅរកដុំថ្មធម្មជាតិ គ្មានទ្រង់ទ្រាយអ្វីពិតប្រាកដ ឬមួយដុំថ្មធម្មជាតិដែលគេគ្រាន់តែយកមករំលីងបន្តិចបន្តួច ហើយដែលនៅបុរាណកាលគេចាត់ទុកជាទេពដូចបាននិយាយពីមុនមក។ បន្ទះអសនៈនោះហៅថា tchou។ លោក Chavannes សរសេរថា "ពាក្យនេះគេនិយមប្រែថា "tablette"[៤] ។ សព្វថ្ងៃនេះ tchou ជាបន្ទះក្ដារមួយ ដែលមានសរសេរឈ្មោះទេព ហើយគេជឿថាជាអសនៈ ពោលគឺជាលំនៅនៃទេពនោះ។ ប៉ុន្តែពិធីខ្លះដែលនៅសេសសល់ដល់សព្វថ្ងៃបង្ហាញថាកាលដើមឡើយបន្ទះក្ដារនោះពុំមែនជាអសនៈនៃទេពឡើយ គឺជាទេពនោះតែម្ដង។ នៅក្នុងការគោរពបូជាបុព្វការីជន (ដូនតា) មានពិធីសំខាន់ៗមួយចំនួនដែលតំរូវឲ្យគេយកឈាមទៅផ្តិតជាចំណុចខ្លះលើបន្ទះក្ដារនោះ ត្រង់កន្លែងដែលសន្មត់ថាជាភ្នែកនិងជាត្រចៀកនៃអ្នកដែលស្លាប់។ ឈាមដាស់ឲ្យភ្នែកនោះចេះមើលឃើញ ហើយឱ្យត្រចៀកនោះចេះស្ដាប់បាន មិនតែប៉ុណ្ណោះឲ្យមើលវិញ្ញាណឃើញផង...។ ដូច្នេះយើងអាចស្មានបានថាវត្ថុដែលក្លាយមកជាបន្ទះក្ដារនេះ កាលដើមឡើយជាបង្គោលឈើមួយឬថ្មទ្រវែងបញ្ឈរមួយដុំ បីដូចជាបដិមាមួយដែលពុំមានភាពសម្រិតសម្រាំង។ ជំនាន់នោះ ទេពនៃដីព្រមទាំងទេពអ្វីដ៏ទៃទៀតមានរូបភាពពុំសម្រិតសម្រាំងឡើយ។ បើយើងពិនិត្យជំនឿនៃជនជាតិចាម យើងឃើញថាសមត្ថិកម្មនៃលោក Chavannes ប្រហែលជាត្រឹមត្រូវ។ បន្តិចទៀតនេះ ខ្ញុំនឹងបង្ហាញរូបបន្ទះថ្មដែលគេគ្រាន់តែរំលីងឲ្យស្អាតល្មមៗ ហៅថា kut ហើយដែលចាមអះអាងថាជាវត្ថុស្នងឲ្យដូនតា ហាក់បីដូចជាដូនតានោះក្លាយខ្លួនជាថ្ម។ ជាមួយគ្នានេះយើងត្រូវដឹងថា kut ប្រចាំគ្រួសារនេះ គេយកទៅដាក់កណ្ដាលស្រែ ដែលជាស្រែពិសេសប្រចាំគ្រួសារនីមួយៗ ពោលគឺស្រែដែលគេយកស្រូវអង្ករ ឬក្រោមរូបភាពជាស្រាបិទមកធ្វើពិធី។ ថ្មនោះជានិមិត្តនៃដូនតាផងនិងទេពនៃដីផង។ យើងឃើញថាថ្មមួយបន្ទះនោះពុំមែនស្នងឲ្យភូតពីរដាច់ពីគ្នាឡើយ តែគឺស្នងឲ្យភូតពីរដែលរលាយចូលគ្នា។ ទេពនៃដីដែលគេពុំស្គាល់រូបរាងអ្វីទាល់តែសោះនោះ គឺគ្រួសារនីមួយៗគេបង្ហាញក្រោមរូបភាពនៃថ្មដែលជាបុព្វការីជនរបស់គេ ហើយដែលនឹងជួយទ្រទ្រង់កូនចៅរបស់គេបន្តទៀត។ ថ្មនោះគឺជាការរលាយចូលគ្នានៃទេពនិងក្រុមគ្រួសារ ហាក់ដូចជាបញ្ជាក់ថាជាកិច្ចសន្យាភ្ជាប់សម្ព័ន្ធអ្វីមួយ។

មកទល់ពេលនេះខ្ញុំបានរៀបរាប់ច្រើនពីជំនឿចិន ព្រោះអស់លោកអ្នកងាយស្រួលយល់ ត្បិតយួនអាណាមនិងចិនមានជំនឿនិងកិច្ចប្រតិបត្តិប្រហាក់ប្រហែលគ្នា។ ប៉ុន្តែបើខ្ញុំយកឧទាហរណ៍ឥណ្ឌាមកបង្ហាញវិញ ក៏នឹងគ្មានការខុសប្លែកគ្នាអ្វីប៉ុន្មានដែរ។

នៅឥណ្ឌា ទេពនៅតាមភូមិនានា សុទ្ធសឹងតែជាថ្មធម្មជាតិ ឬគ្រាន់តែគេរំលីងល្មមៗឲ្យស្អាត។ ពិធីដែលពាក់ព័ន្ធនោះ ច្រើនតែជាការប្រោះព្រំឬច្រូចដោយប្រើឈាម, ប្រេង, ឬទឹក។ ធ្វើបែបនេះ គេសង្ឃឹមថានឹងបណ្ដាលឲ្យដីបង្ករឬបង្កើនភោគផលបានច្រើន មានន័យថាប្រោះព្រំលើថ្មនោះស្មើនឹងប្រោះព្រំលើដីភូមិករទាំងមូល។ នៅឥណ្ឌានេះក៏ដូចគ្នាដែរ គឺបព្វជិត ("អ្នកបួស" ដែលពោលនៅខាងលើ) មានទំនាក់ទំនងផ្ទាល់ទៅនឹងដី ពោលគឺដីដែលជាមនុស្ស។ ហេតុនេះហើយបានជាក្នុងការសាងសង់ខ្លះ គេតែងកប់បព្វជិតឬអ្នកមន្តអាគម ឬមួយទៀតគេកប់នរណាម្នាក់ដែលសហគមន៍នោះដៅមក។ ការធ្វើរបៀបនោះ មិនមែនដើម្បីឲ្យទេពនៃដីសប្បាយរីករាយចិត្តនោះទេ តែគឺដើម្បីឲ្យទេពដែលគ្មានរូបរាងអ្វីនោះមានរូបរាងឡើង ឬមានបុគ្គលិកលក្ខណៈសំគាល់បាន។ ចំពោះពិធីទាក់ទងនឹងសពវិញ ខ្ញុំយល់ថាគេអាចឲ្យភស្តុតាងបានថា កាលដែលប្រជាជនសាមញ្ញឥណ្ឌានៅតាមជនបទនានាចាប់ផ្តើមបត់បែនកែច្នៃប្រពៃណីព្រាហ្មណ៍ឲ្យមកតាមផ្នត់គំនិតរបស់ខ្លួននោះ ផ្នូរខ្មោចនានាដែលធ្វើតាមប្រពៃណីវេទទទួលការវិវឌ្ឍន៍យ៉ាងខ្លាំង។ គឺថាផ្នូរលែងជាលំនៅនៃសពហើយ តែគឺជាសពនោះតែម្ដង។ ពោលម្យ៉ាងទៀតថា ផ្នូរជារាងកាយនៃសព មិនខុសគ្នាអ្វីប៉ុន្មានពី kut របស់ជនជាតិចាម ឬពីបន្ទះអសនៈរបស់ជនជាតិចិនយួនឡើយ។ មិនតែប៉ុណ្ណោះ ខ្ញុំជឿថាចេតិយពុទ្ធសាសនា ពោលគឺសំណង់

[៤] មានន័យថាជាបន្ទះអ្វីមួយ (ទីនេះគឺបន្ទះក្ដារអសនៈដូនតា)។

រាងមូលខាងលើ ដែលក្នុងនោះមាននិមិត្តរូបថា គេតម្កល់សារីរិកធាតុនៃព្រះសក្យមុនីនោះ គឺជាព្រះកាយនៃព្រះពុទ្ធអង្គតែម្តង។ ជំនឿនេះ ខ្ញុំនឹងវែកញែកនៅក្នុងការសិក្សាមួយដាច់ដោយឡែក។ នៅទីនេះ ខ្ញុំគ្រាន់តែលើកឡើងនិយាយតែមួយម៉ាត់ប៉ុណ្ណោះ។ បន្តិចទៀតយើងនឹងយល់ច្បាស់ជាងនេះ ដោយយកពិធីខ្លះៗនៃសាសនាព្រះឥសូរមកវិភាគ ត្បិតចាមបុរាណទទួលឥទ្ធិពលខ្លាំងណាស់ពីលទ្ធិព្រះឥសូរ។

ដូច្នេះអ្វីៗក៏ស្របគ្នាគួរឲ្យយើងស្រាវជ្រាវរកជំនឿឥណ្ឌាដែលមានមុនជំនាន់ព្រាហ្មណ៍ ឬជំនាន់វេទនោះទៅទៀត ដោយសារឃើញថា ជំនឿនោះប្រហាក់ប្រហែលគ្នានឹងជំនឿជីវចលដែលជាមូលដ្ឋាននៃជំនឿនៅឥណ្ឌូចិន ដូចជានៅចម្ប៉ាជាដើម។ មិនតែប៉ុណ្ណោះក៏ប្រហាក់ប្រហែលគ្នានឹងជំនឿនៅចិននិងអាណាម ថ្វីត្បិតតែមានស្រទាប់ជំនឿខុងជឺ ឬតាវ មកគ្របដណ្តប់ពីលើក៏ដោយ។

មូលដ្ឋានជំនឿនៃអាស៊ីដែលស្ថិតនៅក្រោមរបបមូសុង បង្កើតបានទៅជាការគ្រប់គ្រងវែងឆ្ងាយតទៅទៀត។ អស់លោកអ្នកក៏ដឹងដែរថាការគោរពបូជាដីនៅប្រទេសចិនសម័យបុរាណ ព្រមជាមួយគ្នានឹងការចាត់ចែងរៀបចំសង្គម អាចឲ្យយើងពោលបានថា មានដែនទីពីរដែលរៀបរាប់ពីប្រទេសតែមួយនេះ។ ដែនទីទី១ជាដែនទីរដ្ឋបាលមនុស្ស ឯមួយទៀតជាដែនទីជំនឿ ពោលគឺរដ្ឋបាលដែលអ្នកគ្រប់គ្រងសុទ្ធសឹងជាអមនុស្ស ឬ (“ទេព” ដូចធ្លាប់ពោលខាងលើ)។ ទីប្រជុំជនស្រុកស្រែឬក្រុងនីមួយៗ តែងតែមាន “ទេព” (ឬ “អ្នកតា”) ជាអ្នករក្សា។ ទេពទាំងនោះមិនមែនកាន់កាប់ដីធ្លីក្នុងភាពអនាធិបតេយ្យឡើយ ផ្ទុយទៅវិញគឺសុទ្ធសឹងតែធ្វើតាមលំដាប់ថ្នាក់ តាមដ្ឋានានុក្រម ដូចក្នុងការគ្រប់គ្រងដោយមនុស្សដែរ។ ឧទាហរណ៍ទេពនៃទីប្រជុំជនទំហំល្មមមួយមានសិទ្ធិបញ្ជាទៅលើទេពផ្សេងៗដែលគ្រប់គ្រងទីប្រជុំជនតូចជាងនោះ ហើយម្យ៉ាងទៀតស្តាប់បង្គាប់ទេពដែលកាន់កាប់ក្រុងធំៗ។ ព្រះចៅអធិរាជ ព្រមគ្នាជាមួយទេពនៃដីរបស់សន្តតិវង្សព្រះអង្គ ស្ថិតនៅលើ “រដ្ឋបាលបរលោក” ដែលចែកចេញជាក្រសួងផ្សេងៗនេះ។ ព្រះចៅអធិរាជមានសិទ្ធិរហូតដល់ទៅអាចតែងតាំងឬដកហូតទេពប្រចាំតំបន់តូចៗពីតំណែងរបស់ខ្លួន។

ដោយសារមានការហៀរហូរឥទ្ធិពលឥណ្ឌូ-អឺរ៉ុបខ្លាំងឡើងៗមកក្នុងប្រទេសខ្លួននោះ ឥណ្ឌាក៏បោះបង់ចោលរបៀបរបបចាស់ក្នុងការគ្រប់គ្រងដីធ្លីនិងស្រុក។ របៀបរបបនោះប្រហាក់ប្រហែលគ្នានឹងចិនដូចទើបនឹងនិយាយមកនេះ។ បើពិនិត្យមើលរឿងជាតក, គម្ពីរនិងអដ្ឋកថានានាជាបាលី យើងនឹងឃើញថាមានការគ្រប់គ្រងរដ្ឋបាលក្នុងវិស័យបរលោកដូចគ្នា ពោលគឺទេពប្រចាំគ្រួសារជាចំណុះនៃទេពប្រចាំក្រុង រីឯទេពប្រចាំក្រុងក៏ជាចំណុះនៃទេពធំៗប្រចាំទិសទាំងបួន។ ឯទេពទាំងបួនក៏គ្រាន់តែជាបរិវារនៃព្រះឥន្ទ្រទៅទៀត។ ព្រះឥន្ទ្រគង់នៅបុរីទេពមួយដែលគេចម្លងមកសាងឲ្យបានដូចគ្នានៅស្ថានមនុស្ស ហើយដែលជារាជធានី។ មានន័យថារាជធានីដែលព្រះរាជាមនុស្សគង់នៅ គឺជារូបថ្លុកនៃរាជធានីព្រះឥន្ទ្រ។ នៅឥណ្ឌា ទេពនៃដីសហគមន៍មនុស្សនានា ក៏ព្រះរាជាអាចដកចេញពីតំណែងដូចនៅស្រុកចិនដែរ។

ទោះជាយ៉ាងណាក៏ប្រការផ្សេងៗដែលពោលមកពីខាងលើ គ្រាន់តែបានលើកមកលាតត្រដាងក្នុងភាពចោះៗប៉ុណ្ណោះ។ ម្យ៉ាងទៀតចំណុចខ្លះគ្រាន់តែជាសមត្ថិកម្មផង។ ហេតុនេះពុំទាន់អាចហៅថាជាការសិក្សាលំអិត ឬគ្រប់ជ្រុងជ្រោយឡើយ។ ជាដំបូងខ្ញុំធ្វើការបញ្ជាក់បន្តិចដើម្បីចៀសវាងការច្របូកច្របល់។ យើងបាននិយាយអំពីជីវចល។ បន្ទាប់មកយើងនិយាយអំពីការគោរពបូជាដីភូមិករដែលពុំមែនជាការបូជាចំពោះ “ភូត” ឬ “ទេព” អ្វីពិតប្រាកដ ព្រោះជាភូតឬទេពដែលជាដីនោះឯងតែម្តង ពោលគឺពុំមែនជាទេពដែលគ្រប់គ្រងដីភូមិករនោះឡើយ។ បានសេចក្តីថាដែលហៅថា “ថ្មអ្នកតា” ពុំមែនមានន័យថាមានអ្នកតាមួយនៅក្នុងថ្មមួយដុំទេ គឺមានន័យថាថ្មនិងអ្នកតានោះរលាយចូលគ្នា ពុំមែនថ្មផ្សេង អ្នកតាផ្សេងទេ។ តើជំនឿនេះកើតឡើងមុនជំនឿទៅលើទេពដែលមានមុខមាត់ពិតប្រាកដឬយ៉ាងណា? ចំពោះខ្ញុំវិញ ខ្ញុំពុំជឿយ៉ាងដូច្នោះឡើយ។

នៅសម័យកាលចាស់យូរលង់មកហើយ ប្រហែលជាមានក្រុមមនុស្សខ្លះ ក្នុងចំណោមមនុស្សជាតិទាំងមូលដែលយល់ថា ថ្មខ្លះមានកំលាំងសក្តិសិទ្ធិអ្វីមួយនៅក្នុង។ ខ្ញុំមិនយកប្រការនេះមកវែកញែកនៅទីនេះទេ ព្រោះនេះជាប្រធានបទមួយផ្សេងទៀត។ ថ្មដែលវែកញែកនៅទីនេះគឺថ្មដែលពាក់ព័ន្ធនឹងជំនឿគោរពបូជាដីភូមិករ។ ថ្មមួយដុំពិសេសនោះ គឺជាការបង្រួមមួយឲ្យតូចនូវភូមិករមួយទាំងមូល។ រីឯភូមិករនោះមិនអាចផ្តាច់ចេញពីសហគមន៍មនុស្សដែលរស់នៅនិងកាន់កាប់ឡើយ។ បើយកវិស័យភូមិសាស្ត្រមួយធំមកនិយាយ គឺហាក់បីដូចជាមានការរៀបចំសូរិយោដីមួយដែលជាសូរិយោដីបរលោក ឬសូរិយោដីដែលគេបូជា ត្បិតវិស័យនៃសហគមន៍តូចៗនីមួយៗសុទ្ធសឹងតែមានថ្មជាតំណាង។ បណ្ឌិត Cadière បានសិក្សាអំពីការគោរពបូជាថ្មក្នុងទស្សនៈចិត្តសាស្ត្ររបស់មនុស្សម្នាក់ៗ។ តែទោះជាយ៉ាងនោះក្តីក៏លោកបានពោលពីទំនាក់ទំនងជិតស្និតរវាងជំនឿលើ “ថ្មអ្នកតា” និងជំនឿលើ “គោលអ្នកតា”។ សូមកុំភ្លេចថា ការបោះគោលសីមាជាការដែលធ្វើឡើងដោយសហគមន៍មួយទាំងមូល មនុស្សតែងយល់ថា

ទាំងថ្មដែលនៅកណ្ដាលភូមិ ទាំងគោលដែលនៅជុំវិញភូមិ សុទ្ធសឹងមានថាមពលឬអំណាចស័ក្តសិទ្ធិអ្វីមួយ។ យើងមើលតែប្រការដែលថាមានចំណុចកណ្ដាល ហើយមានចំណុចជុំវិញនោះទៅក៏គង់យល់ហើយថាជាជំនឿដែលបានបង្ករបង្កើតជាមូលដ្ឋានដល់ច្បាប់ទម្លាប់គ្រប់គ្រងដែនដី។ កុំភ្លេចថាការគោរពបូជាដីភូមិករជាប់ស្អិតរមួតទៅការគោរពបូជាបុព្វការីជនដូចបានពោលរួចមកហើយ។ ម្យ៉ាងទៀតយើងក៏បានឃើញដែរថា ថ្មដែលស្អងឲ្យដីផង ឲ្យបុព្វការីជនផង មានន័យហាក់បីដូចជាចំណងសម្ព័ន្ធរវាងសន្តតិវង្ស (ឬពូជពង្សគ្រួសារមួយធំ) ជាមួយដីនៃសហគមន៍ដែលខ្លួនគ្រប់គ្រង។ ប្រការទាំងអស់នេះជារឿងជំនឿនិងគោរពបូជា ដែលពុំអាចផ្ដាច់ចេញពីច្បាប់ទម្លាប់គ្រប់គ្រងដែនដីឡើយ។ និយាយម្យ៉ាងទៀតថា ការគ្រប់គ្រងវិស័យបរលោក ជះឥទ្ធិពលត្រង់ទៅការគ្រប់គ្រងសង្គមនោះ។

ការពិនិត្យរែកញែកមកទល់ពេលនេះបង្ហាញថា មិនមែនអំពីសង្គមមនុស្សក្នុងតំណាក់កាលអន់ថយមួយទេ (mentalité primitive) ដែលយើងរៀបរាប់ គឺថាមិនមែនជាសង្គមមនុស្សដែលគោរពថ្មដោយគ្រាន់តែជាថ្មប៉ុណ្ណោះទេ ព្រោះថ្មនេះជាមូលដ្ឋានជំនឿពាក់ព័ន្ធនឹងការគ្រប់គ្រងដីធ្លី។ យើងពុំអាចបញ្ជាក់ថាជំនឿនេះលេចចេញមកពីពេលណាប្រាកដ រីឯរយៈពេលនៃការវិវឌ្ឍន៍ដុះដាលស្របតាមការរីកដុះដាលនៃជំនឿជីវចលនោះក៏មិនអាចកំណត់បានដែរ។ ការគោរពបូជា "ថ្មអ្នកតា" (ដែលខុសពីការគោរពបូជាថ្មសុទ្ធសាធ) នោះមិនមែនជារឿងសាមញ្ញបង្ករបង្កើតឡើងដោយជនជាតិមនុស្សដែលពុំទាន់ជឿនលឿននោះឡើយ ផ្ទុយទៅវិញគឺជារឿងជ្រៅ។ សូមកុំយល់ច្រឡំថា ការដែលទេពពុំមានរូបរាងអ្វីប្រាកដនោះជាគំនិតសាមញ្ញ គឺជាគំនិតជ្រៅទៅវិញទេ ត្បិតប្រការនេះបង្ហាញថាទេពដែលគេជឿថាមានពិតនោះ សំគាល់មិនបាន (abstrait)។ រីឯប្រការដែលថា សំគាល់មិនបានដោយពុំមានរូបរាងដូចមនុស្សនោះ គឺមកពីវិស័យនៃទេពនោះជាដី ហើយទាក់ទងនឹងការគ្រប់គ្រងដី។ ដូច្នេះថ្មកណ្ដាលភូមិ និងគោលផ្សេងៗនោះមានលក្ខណៈសម្បត្តិបី។ មួយគឺលក្ខណៈសង្គម (ដែលខ្ញុំប្រៀបទៅនឹងសូរិយោដីពីលើមកនេះ), ទីពីរគឺលក្ខណៈពិធី ត្បិតតាមរយៈថ្មនោះគេអាចធ្វើកិច្ចដើម្បីឲ្យបានភ្លៀងនិងភោគផល, ឯទីបីគឺលក្ខណៈសាសនា។

ន័យជ្រៅរបៀបនេះមិនអាចចាត់ទុកថាកើតឡើងពីអារ្យធម៌មួយដែលមានភាពអន់ថយឡើយ។ ខ្ញុំមិនអះអាងថា អារ្យធម៌នោះអាចប្រៀបប្រដូចទៅនឹងអារ្យធម៌អឺរ៉ុប, ឥណ្ឌា ឬចិន ដែលកំពុងថ្កុំថ្កើងពេញបន្ទុកនោះទេ។ ប៉ុន្តែយ៉ាងណាក៏អារ្យធម៌នោះវិវឌ្ឍន៍មកដល់ដំណាក់កាលមួយដែលមានលំនឹង ៖ លំនឹងខាងផ្លូវចិត្ត, ខាងសាសនា និងក្នុងវិស័យសង្គម។ ក្នុងទស្សនៈសាសនា ជំនឿថ្មអ្នកតាដែលភ្ជាប់ទៅការគ្រប់គ្រងដីនោះបង្ហាញឲ្យឃើញថាជាមូលដ្ឋានក្នុងការរៀបចំច្បាប់ទម្លាប់ប្រើប្រាស់ដីធ្លី។ សូមបញ្ជាក់ម្ដងទៀតថា មុននឹងមកដល់ដំណាក់កាលដែលមានលំនឹងនេះ ការវិវឌ្ឍន៍នោះឆ្លងកាត់រយៈពេលយ៉ាងយូរ។

សូមលោកអ្នកជ្រួតជ្រាបថា មុនសម័យកាលដែលអារ្យធម៌ខ្ពង់ខ្ពស់មកពីឥណ្ឌានិងមកពីចិនវាតទីគ្របដណ្ដប់លើខ្លួន តំបន់អាស៊ីដែលស្ថិតនៅក្រោមរបបមូសុងនេះ ពុំមែនមានប្រជាជនផ្សេងៗដែលមានកំរិតវប្បធម៌ទាបអន់ថយដូចអស់លោកបណ្ឌិតឥណ្ឌាឬចិនអះអាងនោះឡើយ។ ប្រជាជនទាំងនោះបានវិវឌ្ឍន៍មកដល់តំណាក់កាលអារ្យធម៌មួយដែលមានកម្រិតព្រមទាំងលំនឹងគ្រាន់បើដែរ។

មកដល់កន្លែងនេះ យើងអាចស្រួលយល់ពីលក្ខណៈសម្បត្តិបីដែលលើកឡើងអម្បាញ់មិញ ៖ ទីមួយទេពនៃដីដែលគ្មានរូបរាងអ្វីសោះ ឬដែលស្អងដោយវត្ថុធម្មជាតិអ្វីមួយដែលគេពុំកែច្នៃ, ទីពីរបុព្វការីជន, ទីបីសហគមន៍មនុស្សដែលតពូជពង្សមកពីបុព្វការីនោះ ហើយដែលកាន់កាប់ប្រើប្រាស់ដីនោះ។ តាមយោបល់ខ្ញុំជាការភាន់ច្រឡំទេ ប្រសិនបើគេយល់ថាសហគមន៍នេះបង្កើតទ្រឹស្ដីអ្វីមួយច្បាស់លាស់អំពីទេពដែលជាដីនោះហើយបន្ទាប់មក ដោយឃើញថាមិនអាចទាក់ទងនឹងទេពនោះបាន ទើបរកច្រកណាមួយដើម្បីទាក់ទងគ្នា។ ខ្ញុំដឹងហើយថាការដែលខ្ញុំរៀបរាប់មកអាចឲ្យយល់ថាដូច្នោះមែន ប៉ុន្តែនេះគ្រាន់តែដើម្បីរែកញែកប៉ុណ្ណោះ ព្រោះជាការវិភាគ។ ជាការជាក់ស្ដែង ជំនឿនីមួយៗពុំមែនផ្ដួចផ្ដើមឡើង ហើយបត់បែនហូរហែរដូចការវិភាគឡើយ ព្រោះអ្នកវិភាគឃើញលទ្ធផលទីបញ្ចប់រួចហើយ រីឯការវិវឌ្ឍន៍នៃជំនឿពុំមែនវិវឌ្ឍន៍តាមខ្សែបន្ទាត់មួយត្រង់ទេ គឺបត់បែនក្រវិកក្រវក់ ទំរាំមកដល់ចំណុចលទ្ធផលដែលអ្នកវិភាគបានឃើញ។

មុននឹងឈានមកដល់ដំណាក់កាលដែលមានលំនឹងដូចខ្ញុំបានពោលបន្តិចហើយនោះ មនុស្សជាតិនានាបានឆ្លងកាត់ការគោរព "ភូត" ច្រើនបែបយ៉ាង។ គេធ្លាប់ជឿថា មេកើយរបស់គេជាអ្នកមានឫទ្ធិអំណាច អាចធ្វើឲ្យកុលសម្ព័ន្ធគេបានថ្កុំថ្កើង, អាចធ្វើឲ្យការបរបាញ់សត្វ ឬការយកផលក្នុងព្រៃឬក៏ការចិញ្ចឹមសត្វ ប្រកបដោយលទ្ធផលជាទីពេញចិត្ត។ គេធ្លាប់ប្រើមន្តអាគមផ្សេងៗ ដូចជាការច្រូចឬស្រោចស្រប់ទឹកជាដើម។

សហគមន៍តូចៗនីមួយៗតែងតែធ្វើម្ដេចឲ្យបានប្រយោជន៍មកខ្លួន, ប្រយោជន៍សម្រាប់គ្រួសារផ្ទាល់, សម្រាប់សន្តានមួយទាំងមូល, ឬសម្រាប់ កុលសម្ព័ន្ធមួយទាំងមូល។ ប្រការនេះ ជួនកាលមានទំនាស់នឹងគ្នា ជួនកាលទៀតជួយបំពេញផ្គួបផ្សំគ្នា។ ទំនាស់ឬការជ្រោមជ្រែងគ្នានោះក៏កាន់តែរីកធំខ្លាំងឡើងៗ កាលបើក្រុមមនុស្សផ្សេងៗកាន់តែខិតខំរៀបចំការប្រើប្រាស់និងគ្រប់គ្រងភូមិករឲ្យកាន់តែល្អិតឡើង។ ក្នុងដំណាក់កាលនេះ ក្រុមនីមួយៗយល់ថាទំហំនិងសិទ្ធិរបស់ខ្លួនកំណត់ឡើងដោយទំហំផ្ទៃដីដែលខ្លួនកាន់កាប់។ ប៉ុន្តែក្នុងពេលជាមួយគ្នា ក្រុមនោះក៏ឃើញដែរថាក្រុមគេដទៃទៀតដែលនៅជុំវិញខ្លួនក៏វាតទីក្នុងគំនិត, ជំនឿនិងនីតិវិធីដូចគ្នាដែរ។ ក្រុមនីមួយៗយល់ថាខ្លួនឯងជាកណ្ដាលរៀងៗខ្លួន ឯនរណាពុំមែនក្រុមខ្លួនសុទ្ធតែជាក្រុមនៅជាយ បើនរណាពុំស្របនឹងខ្លួន គឺខ្លួនយល់ថាជាអ្នកផ្សេង។ ពិតមែនហើយថាគេជឿលើឫទ្ធិអំណាចនៃមេកើយដែលអាចនាំភោគផលមកដល់ក្រុម ប៉ុន្តែគេក៏ឃើញដែរថាឫទ្ធិអំណាចនោះពុំវាតទីទៅដល់ណាហួសពីផ្ទៃដីពីសហគមន៍ខ្លួនឡើយ។ ដូច្នេះអាគមអួមអាមនិងកិច្ចពាក់ព័ន្ធនោះ ស្ថិតនៅតែក្នុងបរិវេណគោលជុំវិញភូមិករដែលបាននិយាយពីខាងលើប៉ុណ្ណោះ។ ប្រការនេះមានសារៈសំខាន់ក្រៃលែង ត្បិតក្នុងការវិវឌ្ឍន៍សាសនា នេះជាដំណាក់កាលមួយដែលជំនឿថាទេពគឺជាដីផងនោះ (dieu-sol) ករកើតនឹងរឹងប៉ឹងឡើង។ សហគមន៍មនុស្សមួយក្រុមៗវាតទីទៅលើតែផ្ទៃដីដែលនៅក្នុងបរិវេណកំណត់ដោយគោលសីមាប៉ុណ្ណោះ ហើយឃើញច្បាស់ថាសហគមន៍ផ្សេងៗពីខ្លួនក៏ដូចគ្នាដែរ គឺថាមួយក្រុមៗសុទ្ធសឹងមានទេពដែលជាដីទីទៃពីគ្នា ពុំអាចក្រុមណាវាតទីចូលទៅក្នុងវិស័យនៃក្រុមផ្សេងបានឡើយ។ ជំនឿសាសនានេះមានលក្ខណៈជាជនបទ ហើយទេពនីមួយៗនោះសុទ្ធសឹងជាទេពដែលពាក់ព័ន្ធនឹងកម្មសិទ្ធដី ពុំដូចទេពនៃសហគមន៍ពនេចរ (nomades) ដែលផ្លាស់ប្ដូរទីកន្លែងពុំឈប់នោះឡើយ។ ដូច្នេះទេពរបស់គេគឺជាទេពពាក់ព័ន្ធនឹងទីតាំងភូមិសាស្ត្រ។ កាលណាមានរឿងព្រេងពន្យល់ពីប្រវត្តិសហគមន៍នីមួយៗ រឿងព្រេងនោះតែងបង្ហាញថា ទេពរបស់ក្រុមខ្លួនខុសពីទេពរបស់ក្រុមដទៃ រីឯបុណ្យឬពិធីដែលពាក់ព័ន្ធនឹងទេពនោះ តែងបង្ហាញពីចំណងសម្ព័ន្ធដែលភ្ជាប់សហគមន៍នីមួយៗទៅទេពរបស់ខ្លួនយ៉ាងជិតស្និទ្ធ។ នេះហើយដែលជាមូលដ្ឋាននៃកម្មសិទ្ធិភូមិករ ត្បិតផ្អែកលើចំណងរវាងសហគមន៍ និងបុព្វការីជនខ្លួន។

នេះហើយដែលធ្វើឲ្យទេពដែលជាដី (dieu-sol) នោះពុំមែនមានភិនភាគឬលក្ខណៈអ្វីទាំងអស់ជាមនុស្ស។ ជំនឿនេះពុំមែនកើតឡើងមុនជំនឿដែលយើងបានហៅថាជីវចលឡើយ ព្រោះធ្លុះបញ្ចាំងឲ្យឃើញច្បាស់នូវគំនិត ឬទស្សនៈរបស់សហគមន៍ទៅលើច្បាប់ ទោះបីទស្សនៈនោះពុំទាន់ល្អិតល្អន់វែងឆ្ងាយក៏ដោយ។ សិទ្ធិកាន់កាប់ ឬការប្រើប្រាស់ដីនៅទីនេះ មានជំនឿសាសនាជាបង្អែក ព្រោះមានទេពដែលជាដីជាបង្អែក។ ដូចបាននិយាយរួចម្ដងហើយ តាមពិតទៅជំនឿនេះមានជម្រៅខ្លាំងណាស់ ពុំមានភាពសាមញ្ញឡើយ។ ផ្ទុយទៅវិញ គឺជាលទ្ធផលនៃការវិវឌ្ឍន៍មួយយ៉ាងវែង។ ពីមុនមក ហើយសព្វថ្ងៃក៏នៅតែដូច្នោះ គឺគេគោរពបូជាដើមឈើឬថ្មធម្មជាតិក្នុងន័យដែលពាក់ព័ន្ធនឹងការរៀបចំភូមិករ។ ការគោរពនេះពុំមែនដោយសារគេពុំអាចយល់ថាទេពអាចជាអ្វីផ្សេងឡើយ។ ម្យ៉ាងទៀតថ្មដែលជានិមិត្តនៃទេពឬមេកើយ ទោះបីជាថ្មនោះនៅជាថ្មធម្មជាតិ ឬក៏គេឆ្លាក់ជារូបបដិមាហើយក៏ដោយ ក៏គំនិតដែលថាទេពគ្មានរូបរាងអ្វីទាំងអស់នោះនៅតែគេជឿ។

ទាំងអស់នេះបង្ហាញថាជំនឿនោះធ្លុះបញ្ចាំងអំពីការវិវឌ្ឍន៍នៃអារ្យធម៌ប្រភេទជនបទម្យ៉ាង ដែលបង្កើតបានជាទេពប្រភេទមួយខុសគ្នាពីអមនុស្សទូទៅ ពោលគឺអមនុស្សដែលសណ្ឋានរូបរាងជាមនុស្ស។ ក្រោយមក នៅពេលដែលគេគោរពទេពនានាដែលឆ្លាក់មានទម្រង់មុខមាត់តាមមនុស្ស គេក៏នៅតែគោរពទេពជាដីគ្មានរូបរាងអ្វីពិតប្រាកដនោះដដែល ព្រោះកង្វល់របស់គេនៅតែពាក់ព័ន្ធនឹងដី ដូច្នេះគេត្រូវធ្វើពិធីអ្វី ឲ្យត្រូវចំដីនោះតែម្ដង។ យើងបាននិយាយថាទេពស្ថិតនៅក្នុងបុព្វការីជន, ឬក្នុងមេកើយ, ឬក្នុងថ្មដែលតំណាងឲ្យដី ក្នុងន័យថាជាកិច្ចសន្យាឬជាសម្ព័ន្ធមួយ។ អាជ្ញាកណ្ដាលទាំងនោះធ្វើឲ្យទេពដែលពុំមានរូបរាងជាអ្វី, ដែលចាប់ពុំបាន, ប៉ះពុំបាននោះ ទៅជាអាចទាក់ទងគ្នាបាន។ ក្រៅពីកិច្ចសន្យាឬសម្ព័ន្ធដូចបានពោលមក ត្រូវតែច្បាស់ថាបព្វជិត[៥] ឬមេកើយ...នោះ ពិតជាស្នងឲ្យក្រុមអ្នកស្រុកមែន។ ប៉ុន្តែប៉ុណ្ណេះក៏មិនទាន់គ្រប់គ្រាន់ ព្រោះភាគីម្ខាងទៀតត្រូវជាភូមិករទាំងមូល។ គោរពបូជាភូមិករក្រោមរូបភាពជាមនុស្ស (តាមរយៈបព្វជិតឬមេកើយ...) ព្រមជាមួយគ្នានឹងក្រោមរូបភាពជាថ្មឥតមានភិនភាគពិតប្រាកដ មានន័យថាធ្វើឲ្យទេពដែលឥតរូបរាង ក្លាយទៅជាមានរូបរាងទាក់ទងគ្នាបាន។ តាមរយៈទេពនេះ គេអាចធ្វើកិច្ចអ្វីៗទៅលើដីភូមិករឲ្យមានប្រសិទ្ធភាព ព្រោះទេពនៅទីនេះមានរូបរាង ពោលគឺមិនមែនគ្រាន់តែជាទ្រឹស្ដីសុទ្ធនោះឡើយ។

បន្តិចទៀតនេះ ខ្ញុំនឹងព្យាយាមយកឧទាហរណ៍ខ្លះៗមកបង្ហាញថា ជំនឿខាងលើនេះនៅមាននៅឡើយក្នុងសាសនាឥណ្ឌាធំៗ។

---

[៥] ពាក្យនេះពោលក្នុងន័យទូលំទូលាយ គឺសំដៅនរណាម្នាក់ដែលអ្នកស្រុកចាត់ទុកថាជាមេគេ ក្នុងពិធី ឬកិច្ចប្រតិបត្តិជំនឿផ្សេងៗ។

## សាសនាវេទនិងសាសនាព្រាហ្មណ៍

ឃើញថានៅសម័យកាលដែលលពោលនេះ ជនបទនានានៅអាស៊ីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងទទួលអារ្យធម៌ថ្មី។ បើពោលឲ្យត្រឹមត្រូវជាងនេះទៀត គឺជនបទទាំងនេះមានមូលដ្ឋានគ្រប់គ្រាន់នឹងជុំរុញឲ្យគំនិត ឬឥទ្ធិពលថ្មីៗរីកសាយទៅមុខ។ ឥឡូវនេះដល់ពេលដែលយើងត្រូវលើកចំណុចដែលថាតើជំនឿនៅឥណ្ឌាវិវឌ្ឍន៍ទៅរបៀបណា នៅពេលដែលឥទ្ធិពលឥណ្ឌូ-អឺរ៉ុបហូរចូលមកបន្តិចម្តងៗនោះ។ ម្យ៉ាងទៀតគឺក្នុងវិស័យជំនឿសាសនានេះឯងហើយ ដែលយើងមានទិន្នន័យច្រើនជាបង្គួរ។ ទិន្នន័យនោះចេញមកពីប្រភពពីរដែលសុទ្ធសឹងតែមានសារៈសំខាន់ខ្លាំងហើយដែលកើតឡើងនៅសម័យកាលខុសគ្នា ព្រមទាំងជះឥទ្ធិពលក្នុងកិរិតខុសគ្នាដែរ។ ប្រភពពីរនោះគឺ គម្ពី "វេទ" និងគម្ពី "ព្រាហ្មណ"។ វេទគឺជាសម្រង់ធម៌សូត្រដែលរៀបរៀងឡើងតាំងពីជំនាន់ដែលក្រុមកុលសម្ព័ន្ធ "អារ្យ" ចូលមកដល់ភាគពាយព្យនៃប្រទេសឥណ្ឌា ឬពីមុននោះបន្តិចផងក៏សឹងថាបាន។ នេះនិយាយពីផ្នែកដែលចាស់បំផុតនៃគម្ពីវេទ។ ចំពោះផ្នែកដែលរៀបចំក្រោយគេនៃគម្ពីដដែលនេះវិញ គឺតាក់តែងឡើងនៅផ្នែកប្រទេសឥណ្ឌាតាមជ្រលងទន្លេគង្គា (ឥណ្ឌាផ្នែកកណ្តាល) ហើយដែលក្នុងនោះគេឃើញថា មានជំនឿអ្នកស្រុកសាមញ្ញជាប់នៅដេរដាស។ រីឯគម្ពីព្រាហ្មណវិញគឺសុទ្ធសឹងជាសម្រង់អដ្ឋកថាផ្សេងៗ រៀបរាប់ជាលំអិតនូវកិច្ចទាំងអម្បាលមាណដែលត្រូវធ្វើ នៅពេលដែលគេសូត្រធម៌វេទ។ នៅក្នុងនោះមានផ្នែកធំមួយហៅថា "សតបថព្រាហ្មណ" ដែលយ៉ាងយូរណាស់តាក់តែងឡើងនៅស.វ.ទី៧។ ប្រការនេះធ្វើឲ្យគេយល់បានថាផ្នែកគម្ពីព្រាហ្មណដែលតែងឡើងក្រោយពេលនោះ មានលក្ខណៈឥណ្ឌាច្រើនជាងឥណ្ឌូ-អឺរ៉ុប។ ម្យ៉ាងទៀត គេឃើញថាខាងក្នុងនោះ មានគំនិតច្រើនដែលចេញមកពីអ្នកស្រុកសាមញ្ញផ្ទាល់។

ពាក្យសូត្រក្នុងគម្ពីវេទជាពាក្យបូជាពេលព្រលឹម, ថ្ងៃ, ខែ, ភ្លៀង, មេឃ, ដែលគេធ្វើឲ្យមានបុគ្គលិកលក្ខណៈ ក្លាយទៅជាឧសស, សូរ្យ, សោម, បជ៌ន្យ, វរុណ។ល។ តើមានន័យថាសាសនាវេទជាសាសនាដែលបូជាធម្មជាតិឬអ្វី? មានអ្នកប្រាជ្ញមួយក្រុមជឿយ៉ាងដូច្នេះ។ អស់លោកទាំងនោះយល់ថាវេទជាគម្ពីនៃពួកអារ្យដែលពុំមានភាពចង្អៀតចង្អល់ដូចគម្ពីជនជាតិ Sémites។ មានន័យថាបាតុភូតធម្មជាតិក្នុងលោកដែលមានជាប្រក្រតី ត្រូវគេធ្វើឲ្យមានបុគ្គលិកលក្ខណៈ ពោលគឺបូជាក្នុងន័យជាទេព។ ទស្សនៈនេះប្រហែលជាត្រឹមត្រូវ បើសំដៅទៅលើគម្ពីវេទនៅជំនាន់ដែលករកើតឡើងដំបូង ហើយយើងត្រូវតែទទួលស្គាល់ថា ពាក្យសូត្រទៅថ្ងៃរះ (ឧសស) ជាដើមនោះ សុទ្ធសឹងច្ចុះបញ្ចាំងគំនិតខ្ពង់ខ្ពស់មួយចំពោះធម្មជាតិ។ ប៉ុន្តែគម្ពីវេទក្នុងទស្សនៈនោះប្រហែលជាអារ្យធម៌ឥណ្ឌាដែលរីកសាយតាមជ្រលងទន្លេគង្គាពុំបានជ្រួតជ្រាបឡើយ។ នៅពេលដែលក្រុមឥណ្ឌូ-អឺរ៉ុបចាប់ផ្តើមវាតទីមក សាសនានៃប្រជាជនដែលនៅទីនោះមានមូលដ្ឋានផ្សេង ដែលតមកនឹងឈានទៅចាប់យកទស្សនៈព្រាហ្មណ៍។ បើពោលពីការសូត្រផ្សេងៗ គឺគេសូត្រពាក្យពេចន៍ដូចគ្នា។ ប៉ុន្តែសំណូត្រទាំងនោះគ្រាន់តែធ្វើឡើងអបនឹងពិធីនានាដែលកាន់តែមានភាពស្មុគស្មាញខ្លាំងឡើងៗ ៖ ពិធីខ្លះកាន់តែវែងទៅៗរហូតរាប់ខែ ជួនកាលរាប់ឆ្នាំផង។ សារៈសំខាន់នៃពិធីនិមួយៗពុំស្ថិតទៅលើអត្ថន័យអ្វីជាជម្រៅទេ តែគឺស្ថិតនៅលើការរៀបចំរណ្តាប់, កាយវិការក្នុងពិធី, មន្តដែលយកមកសូត្រ។ រណ្តាប់នោះខ្វះឬលើសអ្វីមួយក៏មិនបាន, វត្ថុនីមួយៗខុសកន្លែងបន្តិចក៏មិនបាន។ កាយវិការក៏ដូចគ្នា បើបត់បែនម្រាមដៃឬចង្អុលដៃខុស ក៏ពិធីនោះទៅជាពុំបានការ។ រីឯការសូត្រវិញ ខុសពាក្យមួយម៉ាត់ក៏មិនបាន, ល្បះឬឃ្លាកាត់ចេញពុំត្រូវកន្លែង, ដាក់សម្លេងមិនត្រូវ ក៏ពិធីនោះអស់ប្រសិទ្ធិភាព។ ទាំងអស់នេះហៅថា "បូត" មានន័យថាសំបកក្រៅនៃពិធីត្រូវតែគត់មត់ឥតលំអៀងបន្តិចបានឡើយ ហាក់បីដូចជាអត្ថន័យជាជម្រៅនោះមានសារៈសំខាន់តិចតួចទៅវិញ។ ទាំងនេះហើយដែលជាលទ្ធផលនៃសំយោគរវាងសាសនាវេទនិងមូលដ្ឋានសាសនាដែលមាននៅឥណ្ឌាប៉ែកកណ្តាល។ ជាការងាយស្រួលក្នុងការប្រើប្រាស់ពាក្យ យើងហៅដំណាក់កាលដែល "បូត" នោះជារឿងសំខាន់ថា "ព្រហ្មញ្ញសាសនា" ឬ "សាសនាព្រាហ្មណ៍"។ រីឯលទ្ធផលនៃសំយោគជាមួយនឹងប្រព័ន្ធជំនឿជាមូលដ្ឋាននោះ យើងហៅថា "សាសនាហិណ្ឌូ"។

ដូច្នេះរឿងសំខាន់នៅក្នុងសាសនាព្រាហ្មណ៍ជំនាន់ដើមគឺ "បូត" នោះឯង ពោលគឺអ្វីៗដែលជាសម្បកក្រៅ ឃ្លាំងឃ្លាតអ្វីបន្តិចក៏មិនបាន។ ក្នុងភាពជានបុំសកលិង្គ ពាក្យ "ព្រហ្មន" ប្រែថា "ពាក្យសូត្រ, ក្បួនធ្វើកិច្ចពិធី" រីឯពាក្យ "ព្រាហ្មណ៍" ដែលជាពាក្យកម្លាយនោះ សំដៅទៅលើបព្វជិតដែលមាននាទីសូត្រឬអនុវត្តតាមអដ្ឋកថានោះ។ ប្រហែលជាអស់លោកនៅយល់ច្រឡំថា ទេពដែលហៅថា "ព្រហ្ម" ជាទេពសំខាន់បំផុតនៅក្នុងសាសនានេះ។ នៅជំនាន់ដើម គឺពុំទាន់ដូច្នេះឡើយ ត្បិត "ព្រះព្រហ្ម" គ្រាន់តែជានិមិត្តសញ្ញា មានភិនភាគជាមនុស្ស ដើម្បីសំគាល់ឬសំដៅលើគំនិតឬទស្សនៈថា "ព្រហ្មន" ខាងលើនេះ។ តាមពិតទៅ ទេពពិតប្រាកដនៃពួកបព្វជិតព្រាហ្មណ៍មិនគិតអ្វីក្រៅពីកិច្ចបូជានោះតែម្តងឡើយ គឺកិច្ចបូជាសុទ្ធ គ្មានអ្វីមួយជានិមិត្តរូប។ គំនិតនៅពីក្រោយ បូត នោះគឺថា បើរណ្តាប់, កាយវិការ, ពាក្យសូត្រ, របៀបរបបលើកដាក់សម្លេង... ក្នុងកិច្ចនោះធ្វើឡើងត្រឹមត្រូវមានន័យថាសណ្តាប់, របៀបរបបឬធម៌នៃលោកនេះទាំងមូល ក៏ត្រឹមត្រូវទៅតាមនោះដែរ។ ហេតុនេះបើព្រាហ្មណ៍សូត្រគ្មានខ្វះឬលើសពាក្យអ្វីមួយម៉ាត់,

លើកដាក់សម្លេង, កាត់ពាក្យ, ដកឃ្លា, ព្រមទាំងធ្វើកាយវិការត្រឹមត្រូវឥតខ្ចោះនោះ មានន័យថារដូវនានានឹងមានភាពប្រក្រតី, ភ្លៀងធ្លាក់ត្រឹមត្រូវតាមរបៀបរបប, ដំណើរការលោកទាំងមូលមានភាពប្រក្រតី។ ដូច្នេះកិច្ចពិធីទាំងឡាយសុទ្ធសឹងមានលក្ខណៈជាមន្តអាគមអូមអាម ដោយសារយកគំនិត “បូត” មកជាមូលដ្ឋានក្នុងកិច្ចណាមួយ។ ឥទ្ធិពលនៃបូត (ឬប្រក្រតីភាព) នោះនឹងជះទៅលើលោកទាំងមូល។

នៅទីនេះខ្ញុំត្រូវតែជម្រាបអស់លោកអ្នកថា គឺលោក Abel Bergaigne ជាអ្នកប្រាជ្ញខាងអារ្យធម៌ឥណ្ឌា ព្រមទាំងជាអ្នកបង្កើតឲ្យមានការសិក្សាអំពីចម្ប៉ាសម័យបុរាណនេះឯងហើយ ដែលបានធ្វើការបកស្រាយលើសំយោគរវាងសាសនាវេទនិងសាសនាព្រាហ្មណ៍ដែលពោលមកនេះ។ ម្យ៉ាងទៀតសូមជ្រាបថា លោក Sylvain Lévi បានយកមូលដ្ឋាននោះដើម្បីមុជជ្រៅតទៅទៀត លើទស្សនៈហៅថា “ព្រាហ្មណ” ដែលបានពោលពីខាងលើ។

យោងតាមទស្សនៈនោះ លោកព្រមទាំងចលនាទាំងអស់នៃលោកនេះ គ្រាន់តែជាលទ្ធផលឬការឆ្លុះបញ្ចាំងនៃកិច្ចពិធីប៉ុណ្ណោះ។ ពេលដែលគេអុជព្រះភ្លើងនៅពេលព្រលឹមស្រាងភ្លាម គឺគេជំរុញឲ្យព្រះអាទិត្យរះឡើង។ ឧទាហរណ៍មួយទៀត ៖ មានរឿងព្រេងមួយដែលពន្យល់ថា លោកយើងនេះករកើតឡើងយ៉ាងដូចម្ដេច។ រឿងនោះនិយាយថា ព្រះនារាយណ៍ឈានបីជំហានឡើងទៅលើដោយកាន់យកព្រះអាទិត្យទៅជាមួយផង។ ហេតុនេះហើយបានជាក្នុងពិធី គេឃើញថាបព្វជិតព្រាហ្មណ៍កាន់វែកមួយ ដែលមានអណ្ដាតភ្លើងក្នុងនោះត្រឹមកំពស់ជង្គង់ បន្ទាប់មកលើកមកដាក់ត្រឹមចង្កេះទើបទីបំផុតទៅលើកមកដាក់កំពស់មុខ។ ភ្លើងនៅក្នុងវែកនោះសំដៅថាជាព្រះអាទិត្យ ហើយព្រាហ្មណ៍បព្វជិតនោះក៏ឈានឡើងលើបីជំហានដែរ ដែលជាហេតុជំរុញឲ្យព្រះអាទិត្យឡើងទៅលើម្ដងបន្តិចៗ រហូតដល់កំពស់ត្រង់។ នោះហើយដែលថាកិច្ចពិធីបង្កើតលោកឡើង ហើយធានាឲ្យ ដំណើរការទូទៅនៃលោកនោះមានប្រក្រតីភាព។ លោកអ្នកច្បាស់ជាស្គាល់រឿងមួយ ដែលតែងដោយលោក Rostand ហើយដែលតួអង្គក្នុងរឿងនោះ ឈ្មោះ Chanteclerc។ តួអង្គនេះជឿថាខ្លួនជាអ្នកធ្វើឲ្យថ្ងៃរះឡើង។ នៅប្រទេសឥណ្ឌាក៏ដូចគ្នាដែរ គឺគេតែងចោទសួរថា “ពេលដែលខ្ញុំអុជភ្លើងឡើង ភ្លើងនោះធ្វើឲ្យព្រះអាទិត្យរះ។ ចុះប្រសិនបើខ្ញុំមិនអុជភ្លើងទេ តើគ្មានថ្ងៃឬអ្វី?” ឯចម្លើយនោះគឺថា លើលោកយើងនេះ មនុស្សដែលត្រឹមត្រូវហើយមានជំនឿនោះ ច្រើនរាប់មិនអស់។ ដូច្នេះគ្មានពោលណាមួយឡើយដែលយើងអាចយល់ថាគ្មាននរណាម្នាក់ធ្វើកិច្ចពិធីសោះលើលោកនេះ។ ប៉ុណ្ណោះក៏គ្រប់គ្រាន់នឹងរក្សាការត្រឹមត្រូវគត់មត់និងប្រក្រតីភាព (បូត) នៃលោកនេះបានហើយ។

យ៉ាងណាក៏គេមិនភ្លេចទេពនានានៅក្នុងសាសនាវេទដែរ ៖ ក្នុងពិធីឧបកិច្ចជំហានទាំងបីនៃព្រះនារាយណ៍នោះ ទេពវេទដែលពាក់ព័ន្ធ, ដែលទាក់ទងនឹងគំនិតថាបង្កើតនិងថែរក្សាលោក, មានរួមចំណែកនៅក្នុងនោះ។ ទេពវេទទាំងនោះមិនខុសអ្វីពីបព្វជិតដែលធ្វើកិច្ច ព្រោះបព្វជិតក៏ធ្វើកិច្ចនោះក្នុងន័យជំនួសឲ្យទេពដែរ ដើម្បីជាគុណប្រយោជន៍ដល់អ្នកដែលមករួមក្នុងពិធីនោះ។ ធ្វើតម្រូវទៅតាមរឿងព្រះ (ទេវកថា) គឺមានន័យថា បព្វជិតព្រមទាំងកិច្ចដែលធ្វើនោះឯងហើយដែលបង្កើតលោករាល់ព្រឹក, ផ្ដល់កំណើតឲ្យសត្វលោកគ្រប់បែបយ៉ាង, តាមរយៈទេពទាំងនោះឯង។ អាស្រ័យហេតុនេះហើយ បានជាគម្ពីរព្រាហ្មណហៅកិច្ចពិធីថា “ប្រជាប្រតិ” មានន័យថា “បិតានៃសត្វលោកទាំងពួង” ។ ប្រការទាំងអម្បាលមាណនេះសរុបមកថាអ្វីៗដែលមាននៅលើដី សុទ្ធសឹងឆ្លុះបញ្ចាំងពីអ្វីៗដែលមាននៅស្ថានលើ។ រីឯបព្វជិតធ្វើកិច្ចនោះ ដូចជាតំណាងឲ្យទេពដូច្នោះ។ កិច្ចបូជាកើតចេញមកពីលោក រីឯលោកវិញកើតចេញមកពីកិច្ចបូជា។

យើងពុំច្ងល់ទេថាហេតុអ្វីបានជានៅក្នុងសាសនាព្រាហ្មណ៍ជំនាន់ដើម ទេពឥតមានភិនភាគមុខមាត់អ្វីសោះ ពោលគឺឥតរូប។ តើចាំបាច់មានបដិមានៃទេពធ្វើអ្វី បើអ្នកធ្វើកិច្ច (បព្វជិត) នោះជាទេពដែលនៅដីស្រាប់ទៅហើយ។

នៅក្នុងសាសនាវេទបុរាណ ស្ដេចលើទេពទាំងអស់គឺព្រះឥន្ទ្រ ថ្វីត្បិតតែមានការប្រជែងពីទេពដ៏ទៃទៀតក៏ដោយ។ ព្រះឥន្ទ្រជាប្រភេទអទិទេពក្នុងអារ្យធម៌ឥណ្ឌូ-អឺរ៉ុប។ អាវុធរបស់ព្រះអង្គគឺវន្ទះ។ ដូច្នេះគឺជាទេពនៃធាតុអាកាស ហើយគេជឿថាបដិហារដ៏ធំធេងមួយរបស់ព្រះអង្គគឺព្រះអង្គពុសភ្នំធំៗនៅស្ថានលើ ដែលយើងហៅថាពពក ឲ្យរហែករយះរយាយដើម្បីឲ្យភ្លៀងបង្អុរមក។ ជំនឿនេះ មានគេស្គាល់នៅក្រិចនិងនៅរ៉ូមដែរ។

អ្វីដែលនៅលើដីសុទ្ធសឹងឆ្លុះបញ្ចាំងអ្វីដែលនៅស្ថានលើ។ ដូច្នេះងាយយល់ទេថា បើព្រះឥន្ទ្រជាស្ដេចនៃទេពទាំងពួង ព្រះរាជាគង់នៅស្ថានមនុស្សក៏ប្រៀបដូចជាព្រះឥន្ទ្រនៅស្ថានមនុស្សនេះដែរ។ រាជ្យនៃមនុស្ស គឺជារូបភាពនៃកិច្ចពិធីដែលមាននៅស្ថានលើដែរ ពោលគឺជីវិតនិងដំណើរការនៃចក្រវាឡទាំងមូល។ គម្ពីរព្រាហ្មណចាស់ៗមានបញ្ចេញទ្រឹស្ដីអំពីព្រះរាជាដែរ ដូចជាថាព្រះឥន្ទ្របំបែកខ្លួនចេញមកមួយអង្គទៀត

សណ្ឋានរូបរាងមុខមាត់ដូចបេះបិតនិងរូបដើម ដើម្បីឲ្យសោយរាជ្យលើដី ហើយដែលមានព្រះនាមថា៖ “កុត្ស”។ កុត្សនោះជាមនុស្ស ហើយអ្នកស្រាវជ្រាវខ្លះយល់ថាជាតួអង្គរឿងព្រេងដែលដើមឡើយជាមនុស្សដែលមានពិតប្រាកដ។ យើងអាចពោលបន្ថែមថា បើមនុស្សឬស្តេចដូចជាកុត្សនោះជាដើម អាចខ្ចីវិស័យព្រះឥន្ទ្រមកធ្វើជារបស់ខ្លួន ព្រះឥន្ទ្រក៏ខ្ចីវិស័យរបស់មនុស្សមកធ្វើជារបស់ព្រះអង្គដែរ។ ព្រះឥន្ទ្រពុំខុសអ្វីពីព្រះ Zeus (ក្នុងអារ្យធម៌ក្រិច) ទេ គឺពុំមែនជាទេពអ្វីដែលច្ងាយធ្វើពុំឲ្យមនុស្សនឹកនាបាននោះឡើយ។ បុគ្គលិកលក្ខណៈព្រះឥន្ទ្រឆ្លុះបញ្ចាំងពីបុគ្គលិកលក្ខណៈ មនុស្សរហូតអាចទៅប្រព្រឹត្តអំពើមិនគប្បីខ្លះផង។ មានរឿងមួយនិទានពីព្រះឥន្ទ្រថា ព្រះអង្គតាំងណែងខ្លួនជាព្រាហ្មណ៍ឈ្មោះគោតម ដើម្បីទៅបែចង់ភរិយារបស់ព្រាហ្មណ៍នោះ ដែលមានឈ្មោះនាងអហល្យា។ មានថ្ងៃមួយទៀតគឺកុត្ស ដែលជាផ្នែកមួយទៀតនៃព្រះឥន្ទ្រនោះតែម្តង ដែលមកបែចង់នាងដដែលនោះ ដោយសារកុត្សមានភិនភាគដូចព្រះឥន្ទ្រ ហើយព្រះឥន្ទ្រក្រឡាខ្លួនជាព្រាហ្មណ៍គោតម។ ចូរយើងស្លេះរឿងនេះមួយអន្លើសិន ហើយនឹងទុកយកទៅនិយាយនៅពេលក្រោយ។

សង្ខេបមក គឺសាសនាព្រាហ្មណ៍ជំនាន់ចាស់រាប់រកគម្ពីរវេទ ដែលទេពនានាសុទ្ធសឹងជាទេពនៃបាតុភូតធម្មជាតិ ប៉ុន្តែដែលយកមកបញ្ចូលក្នុងកិច្ចពិធី។ អំណើះតទៅ ដំណើរការធម្មជាតិទាំងមូលប្រព្រឹត្តទៅដោយមានការរៀបចំចាត់ចែងក្នុងកិច្ចពិធីផ្សេងៗ។ បព្វជិតប្រៀបបីដូចជាទេពផ្សេងៗនៅលើដីដែរ ឯកិច្ចពិធីដែលបព្វជិតទាំងនោះបំពេញ សុទ្ធសឹងជាអំពើកំណត់ដំណើរការចក្រវាឡ។ រីឯដំណើរគ្រប់គ្រងរាជ្យអំណាចក៏ធ្វើស្របតាមរូបភាពនោះដែរ គឺថាអ្វីដែលមាននៅលើដីសុទ្ធសឹងឆ្លុះបញ្ចាំងពីអ្វីដែលនៅស្ថានលើ។

## សាសនាហិណ្ឌូ

មកទល់ពេលនេះយើងបានឃើញគ្រួសៗអំពីទស្សនៈជំនឿនៃឥណ្ឌាមុនពួកអារ្យចូលមក ព្រមទាំងស្រទាប់ជំនឿវេទដែលពួកអារ្យនេះបានផ្សព្វផ្សាយជាបន្ទាប់មកទៀត។ លំដាប់តទៅយើងនឹងពិនិត្យលើលទ្ធផលនៃសំយោគរបស់សាសនាទាំងពីរ។ ជាដំបូង យើងពោលយ៉ាងខ្លីមួយម៉ាត់ថាសំយោគនេះគឺការដែលទេពនានានៃសាសនាវេទមកចាក់ឫសក្នុងជំនឿប្រជាជនដែលមានស្រាប់។ ការចាក់ឫសនោះពុំមែនមានន័យថា ទេពវេទទាំងអម្បាលមាណកាន់តែថ្កុំថ្កើងឡើង នៅពេលដែលបានទៅឈរលើមូលដ្ឋានជំនឿអ្នកស្រុកចាស់ប៉ុណ្ណោះទេ។ បើពោលបញ្ច្រាសមកវិញថាទេពទាំងនោះត្រូវជំនឿអ្នកស្រុកចាស់លេបយកជារបស់ខ្លួនហាក់ដូចជាត្រូវជាង ប៉ុន្តែនៅតែមិនទាន់គ្រប់ជ្រុងជ្រោយ ឬក៏ថានិយាយលើស។ ពាក្យថា “លេប” នៅទីនេះ បើគេយល់ថាចាក់ឫសនៅក្នុងដីនោះទើបត្រឹមត្រូវ។ យើងបាននិយាយនៅខាងលើថា ជំនឿសាសនាដែលមានមុនពេលពួកអារ្យចូលមកនោះ អាចគូសវាសលាតសន្ធឹងជាផែនទីជំនឿមួយដែលបង្ហាញអំពីភូមិករនានា ហើយភូមិករនីមួយៗពាក់ព័ន្ធទៅនឹងសហគមន៍មនុស្សមួយក្រុមដែលសុទ្ធសឹងមានទេពមួយជាតំណាង។ ទេពនោះអ្នកស្រុកឲ្យឈ្មោះផ្សេងៗ ហើយតំណក្រោយមកគេហៅជាពាក្យសំស្ក្រឹតថា “យក្ស”។ ការបែងចែកក្រុមមនុស្សស្របទៅតាមដីភូមិករ ជាមូលដ្ឋាននៃប្រព័ន្ធជំនឿនោះ។ ថាមពលនៃដី មានទេព (ឬអ្នកតា) មួយជានិមិត្តរូប។ ទេពនោះហើយដែលអាចនាំមកនូវភោគផលនិងសេចក្តីស្រណុកសុខសប្បាយ ដូច្នេះហើយក្រុមមនុស្សនីមួយៗភ្ជាប់ខ្លួនទៅនឹងទេពដែលខ្លួនគោរពនោះឯង។ ទីកន្លែងណាក៏មានយក្សដែរ ព្រោះយក្សជាទេពនៃភូមិករនីមួយៗ, ហើយដែលភ្ជាប់ខ្លួនទៅនឹងការបែងចែកដីធ្លី។ បើនៅរាជធានី យក្សជាទេពនៃប្រទេសទាំងមូល យ៉ាងហោចណាស់ក៏ជាទេពប្រចាំសន្តតិវង្សដែរ។ បើនៅជនបទ យក្សជាទេពប្រចាំនិគមដែលពាក់ព័ន្ធ។ គម្ពីនានា ទាំងហិណ្ឌូផង ទាំងពុទ្ធសាសនាផង សុទ្ធសឹងមានចែងបញ្ជីភូមិស្ថាន ដែលនីមួយៗទាក់ទងទៅនឹងយក្សមួយ។ យក្សឬទេពទាំងនោះសុទ្ធសឹងតែមានប្រភពចេញពីដីភូមិករ។ ថ្មីៗនេះ លោក Sylvain Lévi សរសេរថា៖ “បុរាណវិទ្យានៃប្រទេសឥណ្ឌានៅខ្សត់ខ្សោយនៅឡើយ ធ្វើឲ្យយើងពុំច្បាស់ថាការដែលជ្រុងមួយមានយក្សមួយជាអ្នករក្សានោះ តើពិតដូចជាគេថាមែនឬអ្វី។ ប្រសិនបើបញ្ជីយក្សដែលគេស្គាល់នោះយកជាការបាន យើងនឹងយល់ដឹងកាន់តែជ្រៅអំពីជំនឿអ្នកស្រុកនៅតាមមូលដ្ឋាន ពោលគឺយើងនឹងយល់ច្បាស់ជាងនេះថាអ្វីទៅដែលហៅថាយក្ស។ គម្ពីចែងថាយក្សដែលកាន់កាប់តំបន់ “ទ្វារក” គឺព្រះនារាយណ៍, យក្សនៃតំបន់ “រោហីតក” គឺជាព្រះស្កន្ទ, រីឯយក្សនៃតំបន់ “តាម្រាបណ៌ី” គឺព្រះពិភេក។ បើសិក្សាគម្ពីនេះមែនទែន ឃើញថាយក្សទាំងអម្បាលមាណនោះ មានទាក់ទងទៅនឹងស្មារតីអ្នកស្រុកដែលចងចាំតៗគ្នាពីជំនាន់មួយទៅជាជំនាន់មួយ ពោលគឺការចងចាំអំពីមេសហគមន៍មនុស្សនានាក្នុងអតីតកាល។ ក្នុងចំណោមមេកើយទាំងនោះ អ្នកខ្លះទៅជាល្បីល្បាញដោយសារមានរឿងព្រេងឬគម្ពីផ្សេងលើកតម្កើងឲ្យខ្ពស់ត្រដែត

រហូតដល់គេស្គាល់ គោរពពេញប្រទេសឥណ្ឌាទាំងមូល។ ខ្លះទៀតពុំមានភ័ព្វដល់នោះទេ ពោលគឺគេស្គាល់និង គោរពតែក្នុងរង្វង់ស្រុក ឬវិស័យភូមិសាស្ត្រតូចមួយប៉ុណ្ណោះ។ តួនាទីនិងកិត្តិនាមក៏រឹតខុសៗគ្នានេះ អាចប្រៀបប្រដូចទៅព្រះនៃតំបន់ផ្សេងៗ តូចឬធំ (saints patronaux) របស់យើងដែរ។ សមត្ថិកម្មនេះ ស្របនឹងលទ្ធផលនៃការស្រាវជ្រាវរបស់យើងពេញទី។ ដែលហៅថា "ស្មារតីចងចាំនៃអ្នកស្រុក" នោះ ពុំគឺអ្វីក្រៅពីកម្រងរឿងព្រេងនិងល្បែងនានាដែលគេយកមកលាតត្រដាងពេលបុណ្យទានខ្លះនៅតាមភូមិ ជាពិសេសបុណ្យដែលទាក់ទង នឹងទេពប្រចាំភូមិ។ ធាតុពិតជាមូលដ្ឋាននៃទេពនោះ គឺជាដីភូមិករនៃសហគមន៍ដែលពាក់ព័ន្ធនោះតែម្តង។ យើងនឹងយល់កាន់តែច្បាស់អំពីចំណុចនេះនៅពេលបន្តិចទៀត លុះដល់យើងសិក្សាអំពីប្រពៃណីលិង្គព្រះឥសូរ។

អ្នកស្រុកមូលដ្ឋានធ្លាប់ជឿទៅលើទេពមួយអង្គដែលពាក់ព័ន្ធនឹងកសិកម្មឬគង្វាលហ្វូងសត្វ។ លុះសាសនាវេទចូលមក ទេពនោះក្លាយទៅជាព្រះនារាយណ៍ មានន័យថាទេពនោះទៅទាក់យកព្រះនារាយណ៍មកបំពាក់លើខ្លួន ត្បិតព្រះនារាយណ៍មានឫទ្ធិថែស្តារធ្វើឲ្យលោកនេះមានជីវិតដោយជំហានបីរបស់ព្រះអង្គ (ត្រីវិក្រម)។ ទេពក្នុងនិកាយព្រះនារាយណ៍នោះ អាចជាព្រះក្រឹស្នា ដែលស្រីគង្វាលចៀមទុកជាសង្សារទៀតផង។ រីឯពួកព្រាហ្មណ៍ក៏និយមរាប់អានទេពនោះណាស់ ទើបបានជាមានទេវកថាផ្សេងៗករកើតឡើងអំពី "ប្រជាបតិ" ដែលព្រាហ្មណ៍ទាំងនោះថាជាព្រះនារាយណ៍។

រីឯរឿងទាក់ទងនឹងព្រះឥសូរ ពុំដូច្នោះឡើយ។ ព្រះឥសូរគឺជាព្រះ "រុទ្រ" នៃសាសនាវេទ ហើយដែលជាទេពនៃខ្យល់ព្យុះ, ភ្លៀង, ផ្គរ។ ភ្លៀងនោះពុំមែនជាភ្លៀងបង្អុរមកបង្កើនភោគផលដីធ្លីឡើយ គឺជាភ្លៀងព្យុះដែលនាំមហន្តរាយដល់ផែនដី។ នេះជាទេពកាច។ ព្រះនាមព្រះអង្គមានន័យថា "អ្នកស្រែក" ឬ "ក្រហម" ហើយអ្នកហែហមព្រះអង្គសុទ្ធសឹងជាពពួកអសោរ។ នៅក្នុងទេវកថាផ្សេងទៀត ទេពនោះទាក់ទងទៅនឹងសសៃសសូងនៃជម្រៅផែនដី។ ជំនឿពីព្រះរុទ្រក៏ដូច្នោះដែរ គឺពីសសៃសសូងនៃផែនដីនោះហើយ ដែលខ្យល់ព្យុះកំណាចធ្លាយចេញមក។ ជួនកាលព្រះរុទ្រគេទុកជាទេពភ្ជាប់ទៅនឹងដីធ្លី ហៅថា "វស្តោស្បតី"។ យ៉ាងណាក៏ដោយព្រះអង្គជាមេនៃពពួកភូតប្រេតនរកដែលនៅក្នុងដី។ លក្ខណៈប៉ុន្មាននេះហើយដែលធ្វើឲ្យព្រះអង្គភ្ជាប់ខ្លួនឬពាក់ព័ន្ធទៅនឹងដីដែលគេបូជា។ ទេពនៃដីភូមិករដែលអ្នកស្រុកនៅជនបទគោរពបូជានោះ ចំពោះពួកអារ្យវិញ គឺជាពួកអសោរដែលត្រូវខ្លាចរអារ។ ដូច្នេះហើយ កាលពីដំបូង ព្រះឥសូរគេគ្រាន់តែរាប់បញ្ចូលនៅក្នុងជំនឿព្រាហ្មណ៍ថាជាភាគមួយ ឬជាអាមាត្យម្នាក់នៃព្រះរុទ្រតែប៉ុណ្ណោះ។ ដើម្បីឧបកិច្ចឲ្យភាពអវិជ្ជមានក្លាយទៅជាវិជ្ជមាន ឬកែប្រែភាពកំណាចឃោឃៅឲ្យទៅជាភាពល្អស្លូតបូត គេក៏កែឈ្មោះ ទៅជា "សិវ" ដែលមានន័យថា "អ្នកចិត្តល្អ"។ នេះហើយដំណើរដើមទងនៃព្រះឥសូរ។

ដើម្បីឲ្យយល់អំពីជំនឿអ្នកស្រុកជាមូលដ្ឋាន ពោលគឺជំនឿអ្នកស្រុកនៅជនបទទៅលើព្រះឥសូរ មានតែការពិចារណាល្អិតល្អន់ទៅលើលិង្គដែលជានិមិត្តរូបនោះទេ ដែលជួយឲ្យយើងចាប់យល់។ អង្គជាតិនេះគ្មានអ្វីជាទីស្រពិចស្រពិលឡើយ គឺជានិមិត្តរូបនៃការបង្កើតភោគផល។ តើការគោរពបូជាលិង្គនោះមានជំរៅត្រឹមណា? ខ្ញុំយល់ថាក្នុងប្រការនេះ មនុស្សអាចយល់ច្រឡំឬយល់ផ្លូវច្រើន។ នៅប្រទេសឥណ្ឌាក៏មិនខុសគ្នាអ្វីនឹងនៅឥណ្ឌូចិនដែលទទួលអារ្យធម៌ឥណ្ឌានោះឡើយ គឺថាលិង្គជានិមិត្តរូបនៃរាជ្យអំណាច ហើយដើម្បីយល់ន័យនោះ លុះត្រាតែគេយល់រួចទៅហើយថាជំនឿលើលិង្គជាជំនឿភ្ជាប់ទៅការគោរពបូជាថ្មដែលជាដីភូមិករ ដូចបានពោលពីខាងលើ។ កិច្ចពិធីទាក់ទងទៅនឹងទេពជាដុំថ្មនោះ ច្រើនតែធ្វើឡើងតាមការប្រោះព្រំឬស្រោចទឹក។ រីឯកិច្ចពិធីពាក់ព័ន្ធនិងលិង្គគ្មានអ្វីប្លែកពីនោះឡើយ។ លិង្គតែងតែមានជើងទម្រម្យ៉ាងសម្រាប់ត្រងយកទឹកមន្តដែលគេស្រោចស្រប់នោះ។ គេអាចពន្យល់ន័យនៃជើងទម្រនោះដោយប្រការផ្សេងៗ តែចំពោះខ្ញុំវិញ ខ្ញុំយល់ថាគឺជាដីភូមិករណាមួយតូចឬធំ ដែលលិង្គនោះគ្របដណ្តប់លើ ឬពោលម្យ៉ាងទៀតថា ដីភូមិករតូចឬធំដែលជាចំណុះនៃលិង្គនោះ។ សូមជ្រាបថាលិង្គមួយដែលគេគោរពបូជានៅរាជធានីនៃអាណាចក្រធំឬតូចមួយ ឬពុំនោះទេដែលគេគោរពបូជានៅវិស័យតូចមួយ ដូចជាភូមិជាដើមនោះ ពុំមែនមានន័យថាជាព្រះឥសូរនៅលើស្ថានសួគ៌ ហើយដែលគ្រប់គ្រងមនុស្សជាតិពេញមួយផែនដីនោះឡើយ។ គឺជាព្រះឥសូរនៃប្រទេស, នៃរាជធានី, ឬនៃភូមិតូចនោះ។ ពោលឲ្យខ្លីមក លិង្គឥសូរនោះពុំខុសអ្វីពីដុំថ្ម, ដំបូក, ដីទួលដែលជាទេពនៃដីភូមិករដែលយួននិងចិនគោរពបូជា ហើយដែលយើងបាននិយាយរួចមកហើយទេ។

លោកបណ្ឌិត Bosch បានឃើញថា ទេវកថាចាស់បុរាណមួយស្តីពីលិង្គព្រះឥសូរដែលគេស្គាល់នៅប្រទេសឥណ្ឌានោះ នៅចម្ប៉ានិងនៅឥណ្ឌូណេស៊ីក៏គេស្គាល់ដែរ។ រឿងនោះប្រៀបលិង្គទៅនិងសសរភ្លើងយ៉ាងវែងមួយដែលធ្លាក់មកពីលើកប់ឈរនៅដី។ សរសរភ្លើងនោះអាចនឹងបណ្តាលឲ្យភ្លើងឆេះលោកទាំងមូល។ ដើម្បីទប់ស្កាត់វិនាសកម្ម ព្រះនារាយណ៍និងព្រះព្រហ្មយកស្រោមទៅរុំពាត់លិង្គនោះ ដើម្បីជៀសវាងកុំឲ្យប៉ះផ្ទាល់ទៅនឹងដី។ គឺនោះហើយដែលក្លាយទៅជាលិង្គ ៖ រាងមូលនៅខាងលើនោះក្លាយទៅជាប្រាំបីជ្រុងនៅកណ្តាល ហើយបួនជ្រុងនៅផ្នែកខាងក្រោម។

ប្រាំបីជ្រុងនោះគឺជាស្រោមនៃផ្នែកព្រះនារាយណ៍ពាក់ឲ្យ រីឯបួនជ្រុងជាផ្នែកដែលព្រះព្រហ្មបំពាក់មួយជាន់ពីលើទៅទៀត។ ផ្នែកទាំងនេះ គេបង្កប់នៅក្នុងជើងទម្រ។ ដូច្នេះគ្មានអ្វីគួរឲ្យច្ងល់ទៀតទេ ថាជើងទម្រនេះជាដីតែម្តង។ គឺដីនៃភូមិករឬប្រទេសទាំងមូលដែលពាក់ព័ន្ធនឹងការគោរពបូជាលិង្គនោះ។ នៅក្នុងជំនឿចាស់ពីព្រេងនាយមក ទឹកដែលគេស្រោចស្រប់នៅលើថ្មតែងហូរហៀរមកលើដី ដែលគេយល់ថាផ្តល់ជីវជាតិឲ្យដីនោះបង្កើតភោគផលឡើង។ រីឯក្នុងសាសនាហិណ្ឌូវិញ ទឹកក្នុងពិធីនោះក៏ស្រោចស្រប់ដីដែរ គឺដីដែលមានជើងទម្រជាតំណាង។ ជើងទម្រនោះស្នងឲ្យដីភូមិករ ឬអាណាចក្រទាំងមូល ដែលសង្ខេបមកយើងអាចហៅថាព្រះឥសូរ។ ទាំងទេវកថានៅឥណ្ឌា ទាំងការបូជាដែលមាននៅជ្វានិងចម្ប៉ា សុទ្ធសឹងតែពាក់ព័ន្ធដូចគ្នាទៅដីភូមិករ។ សូមជ្រាបថាលិង្គដែលគេយល់ថាសក្តិសិទ្ធបំផុតនោះ គឺលិង្គដែលគេអះអាងថាផុសឡើងចេញពីដី។ ក្នុងលទ្ធិព្រះឥសូរ គេយល់ថាបើនរណាយកលិង្គនោះចេញពីដី ឬក៏បំបែកឲ្យលែងលេចធ្លោចេញពីដីនោះនឹងបណ្តាលឲ្យអាណាចក្រនិងសន្តតិវង្សទាំងមូលរលំទៅជាមួយគ្នា។

ហេតុនេះយើងឃើញថា ទ្រឹស្តីនៅក្នុងសាសនាហិណ្ឌូគ្រាន់តែជាការរៀបចំឡើងឲ្យស្អាតបាត និងសម្រិតសម្រាំងប៉ុណ្ណោះ នូវជំនឿនៃអ្នកស្រុកជាមូលដ្ឋាន។ ទេពដែលសហគមន៍អ្នកស្រុកគោរពបូជា ជាអាជ្ញាកណ្តាលដែលភ្ជាប់សហគមន៍អ្នកស្រុកនោះទៅនឹងទេពធំពិតប្រាកដ តែដែលចាប់មិនបានហើយមើលមិនយល់ថាជាអ្វី។ ទេពនៃអ្នកស្រុកទាក់ទងស្អិតរមួតទៅនឹងសហគមន៍របស់គេ, ទៅនឹងដីធ្លីភូមិករដែលគេកាន់កាប់ជាលំនៅដ្ឋាន និងជាស្រែចំការបង្កើតភោគផល។

ជាដំបូងឡើយ ទេពនោះរលាយចូលខ្លួនជាមួយដុំថ្ម ហើយដើម្បីទាក់ទងគ្នាបាន លុះត្រាតែធ្វើតាមរយៈជនណាម្នាក់ដែលជាមេកើយ ឬជាបព្វជិត។ តមក ទេពនោះលេចចេញជាភិនភាគមនុស្សបន្តិចម្តងៗ រហូតដល់ទៅគេយល់ថា (ឬត្រឡប់ទៅយល់វិញថា) ជាទេពដែលយកថ្មជាទីលំនៅ ពោលគឺស្ថិតក្នុងថ្មនោះ មានន័យថាផ្សេងដាច់គ្នាពីមេកើយឬបព្វជិត ថ្វីត្បិតតែអាចចូលមកសន្ថិតក្នុងខ្លួនអ្នកនោះនៅក្នុងពិធីអ្វីមួយក៏ដោយ។ ការជឿរបៀបនេះ (ឬការត្រឡប់មកជឿរបៀបនេះវិញ) ងាយយល់ជាងមុន ព្រោះទេពនៅទីនេះមានភិនភាគជាមនុស្ស។ ទេពឥសូរអាចចេញពីលិង្គខ្លួនបាន ហើយមកបង្ហាញខ្លួនពាក់កណ្តាលឬពេញលេញចំពោះមុខសាសនិករបស់ខ្លួន។ លិង្គដែលជានិមិត្តរូបនេះ យើងអាចយល់បានដោយសារយើងយកទៅដាក់ក្នុងជំនឿលើថ្ម, គោល, ដែលទេពរលាយចូលក្នុងនោះដូចនិយាយនៅខាងលើ ហើយដែលអាចចេញពីនោះមកទាក់ទងគ្នានឹងមនុស្សក្នុងពេលធ្វើកិច្ចពិធី។ ដូច្នេះឃើញថា លិង្គមានន័យដូចគ្នានិងគោល, ដើមឈើ, ដុំថ្ម, ឬទួលដែលមានទេពរលាយជាមួយគ្នានោះ។

ចំពោះជំនឿទាក់ទងនឹងព្រះនារាយណ៍វិញ បើសង្កេតមើលនៅតាមមូលដ្ឋាន ពោលគឺនៅតាមជនបទ ឃើញថាអ្នកស្រុកនិយមគោរពបូជាអវតារទាំងដប់។ ជំនឿលើអវតារទាំងនោះ គឺជាការយកទេវកថានានាដែលមានប្រភពខុសៗគ្នាមកបញ្ចូលគ្នា។ ឧទាហរណ៍ជំនឿលើអវតារជាអណ្តើកសុទ្ធសឹងមានដំណើរដើមទងទៅនឹង “ប្រជាបតិ” នៃជំនឿព្រាហ្មណ៍បុរាណ។ ឯជំនឿលើព្រះឥសូរវិញក៏ដូច្នោះដែរ គឺមាននិយាយពីវង្សត្រកូលនៃទេពនោះទាំងមូល៖ នាងបាព៌តីជាព្រះជាយា, ព្រះគណេស និងព្រះស្កន្ទជាព្រះរាជបុត្រ, ព្រះគោនន្ទីជាជំនិះ។ល។ អ្នកទាំងនោះ ដើមឡើយសុទ្ធសឹងជាទេពតូចៗដែលភ្ជាប់ខ្លួនទៅភូមិស្រុកនានា ហើយទីទៃពីគ្នា។ ប្រសិនបើទស្សនៈរបស់ខ្ញុំពុំឃ្លាតឆ្ងាយពីការពិតទេនោះ មានន័យថានិកាយធំទាំងពីរនៃសាសនាហិណ្ឌូនេះ កើតឡើងដោយផ្អែកមូលដ្ឋានលើជំនឿអ្នកស្រុកនៅតាមជនបទពាក់ព័ន្ធនិងការរៀបចំ និងចាត់ចែងដីធ្លី ឬសូរិយោដីបុរាណដែលមានមុនជំនាន់ពួកអារ្យចូលមក។ ចំពោះលទ្ធិព្រះឥសូរជាពិសេស គេសង្កេតឃើញថាក្រុមបរិស័ទសាសនានីមួយៗ ច្រើនតែជាសហគមន៍មួយដែលមានទេពរបស់ខ្លួនផ្ទាល់។ រីឯទំនាក់ទំនងរវាងទេពទាំងនោះ គឺធ្វើឡើងតាមគំរូនៃទំនាក់ទំនងរវាងសហគមន៍ពាក់ព័ន្ធទាំងនោះ។ ទោះជានៅភូមិចាមតូចតាចយ៉ាងណា ដែលទេពនោះគ្រាន់តែជាថ្មធម្មជាតិមួយដុំ ក៏អ្នកស្រុកតែងមានជំនឿថា ទេពរបស់ខ្លួនជាសាច់ញាតិជាមួយទេពនៃសហគមន៍ជុំវិញនោះ ដូចជា ឪពុក, ម្តាយ, ប្តី, ប្រពន្ធ។ល។ នៃដុំថ្មដែលជាទេពនៅភូមិជិតៗ។ បើនៅប្រទេសឥណ្ឌាសព្វថ្ងៃវិញ ក្រុមពពួកទេពនៃលទ្ធិព្រះឥសូរសុទ្ធសឹងមានចាត់តាំងលំដាប់ថ្នាក់និងតួនាទីអស់ទៅហើយ។ សហគមន៍អ្នកស្រុកនីមួយៗមិនបាច់បង្កើតទេពឬតួនាទីថ្មីអ្វីឡើយ គ្រាន់តែជ្រើសរើសយកទេពណាមួយតាមចំណង់ចិត្តរបស់ខ្លួនមកធ្វើជាទេពរបស់ខ្លួនក៏ជាការស្រេច។ ប៉ុន្តែដើមឡើយ ជំនឿនេះប្រហែលជាករកើតព្រមទាំងវិវឌ្ឍន៍ក្នុងដំណើរបញ្ច្រាសមកវិញទេ។ មើលទៅប្រហែលជាចាប់ផ្តើមពីមានទេពប្រចាំសហគមន៍មនុស្សតូចៗ ដែលគ្មានរូបរាងប្រាកដ ឬមួយក៏គ្មានឈ្មោះផង ហើយទេពទាំងនោះចងសម្ព័ន្ធនិងគ្នា, រលាយចូលគ្នា, ដោយសារជាឪពុក, ម្តាយ, ប្តី, ប្រពន្ធ, កូន។ល។ នៅដំណាក់កាលនោះ ឥទ្ធិពលឥណ្ឌូ-អឺរ៉ុបមិនទាន់ហូរចូលមកនៅឡើយទេ។ ស្របគ្នានឹងនោះ ទេពប្រចាំសហគមន៍តូចៗនានាប្រហែលជាចងសម្ព័ន្ធរបៀបនោះដែរ ប៉ុន្តែជុំវិញតួអង្គព្រះនារាយណ៍ ហើយបង្កើតបានជាទ្រឹស្តីអំពីអវតារ។ ប្រការដែលពោលមកនេះ បង្ហាញពីសំយោគនៃវត្ថុធាតុដែលមកផ្តុំគ្នា ក្រោមឥទ្ធិពលនៃលទ្ធិព្រាហ្មណ៍ ហើយដែលបង្កើតបានមកជាសាសនាហិណ្ឌូ។

គម្ពីសាសនាជាភាសាសំស្ក្រឹត ពុំគ្រាន់តែជាលទ្ធផលនៃការបត់បែនរបស់ជំនឿព្រាហ្មណ៍ឲ្យស្របតាមការគោរពបូជាដែលមាននិកាយ ឬលទ្ធិច្រើនប៉ុណ្ណោះទេ។ បើមើលសើៗ ឃើញហាក់ដូចជាជំនឿលើ "ត្រីមូតិ៌" មានជម្រៅ ប៉ុន្តែនេះគ្រាន់តែជាការភាន់ភ្នែកប៉ុណ្ណោះ។ គេយកព្រះព្រហ្ម ដែលជាទេពតំណាងពាក្យពេចន៍ប្រើប្រាស់ក្នុងពិធី (ព្រហ្មន) ទៅភ្ជាប់ជាមួយព្រះឥសូរនិងព្រះនារាយណ៍។ ដូច្នេះព្រះព្រហ្មក៏ក្លាយទៅជាទេពបង្កើតលោក ត្បិតដើមឡើយទេពនេះជា "ពាក្យ" ដែលបង្ករបង្កើតលោក។ ពេលនោះព្រះនារាយណ៍ក្លាយទៅជាអ្នកថែរក្សាលោក រីឯព្រះឥសូរទៅជាអ្នករំលាយលោក។ ទ្រឹស្តីថ្មីនេះហាក់ដូចជាងាយចាប់យក ប៉ុន្តែជាការជាក់ស្តែង ព្រះព្រហ្មដែលគេអះអាងថាជាអ្នកបង្កើតលោកនោះពុំដែលទទួលការគោរពបូជាស្មើនឹងទេពពីរអង្គទៀតនោះឡើយ។ នៅប្រទេសឥណ្ឌាពុំដែលមាន "ព្រហ្មញ្ញសាសនា" ដែលក្នុងនោះគេគោរពព្រះព្រហ្មជាធំ (អទិទេព) ដូចជាលទ្ធិព្រះឥសូរ ឬលទ្ធិព្រះនារាយណ៍សោះ។ សូម្បីតែក្នុងប្រការនេះ ក៏នៅចម្ប៉ាគេសង្កេតឃើញដូចគ្នា។

នេះគឺចំណុចសំខាន់មួយ ៖ សាសនាវេទដែលជារបស់ពួកឥណ្ឌូ-អឺរ៉ុប ជាជំនឿប្រកាន់រើសត្អើងខ្លាំងណាស់ ហើយតែងចាត់ទុកអ្នកស្រុកតូចតាចនៅតាមជនបទឥណ្ឌានានាថាជាសត្រូវថោកទាប។ តើហេតុដូចម្តេចបានជាចុងបញ្ចប់ទៅក៏រលាយចូលគ្នាជាមួយប្រពៃណីជនបទនោះទៅវិញ?

ចូរយើងត្រឡប់ទៅមើលវិភាគដែលយើងបានធ្វើទៅលើជំនឿអ្នកស្រុកជនបទនិងជំនឿសាសនាវេទឡើងវិញ។ ក្នុងករណីទាំងពីរនេះ ថ្វីត្បិតតែផ្លូវដើរខុសគ្នា ក៏លទ្ធផលឃើញថាដូចគ្នាដែរ គឺថាទេពនៅតែមើលមិនឃើញ មិនដឹងជាអ្វីប្រាកដ ទាល់តែបព្វជិតឬមេកើយនៃសហគមន៍នីមួយៗស្នងឲ្យទើបទាក់ទងគ្នាបាន ហាក់បីដូចជាស្ពានមួយប៉ុណ្ណោះ។

ខ្ញុំយល់ថា ការប្តូរសាសនាពីមួយទៅមួយៗធ្វើឡើងទៅបានលុះត្រាតែតាមរយៈមនុស្សម្នាក់ដែលមានលក្ខណៈសម្បត្តិគ្រប់សព្វ ដើម្បីបំពេញតួនាទីនោះ។ មនុស្សនោះមិនមែនជារាស្ត្រសាមញ្ញ, មិនមែនជាពាណិជ្ជករសំខាន់ណាម្នាក់, ហើយពុំមែនជាបព្វជិតសុទ្ធសាធទៀតផង។ មនុស្សនោះគឺស្តេច។ នៅពេលមេណាមួយនៃពួកឥណ្ឌូ-អឺរ៉ុបមកដល់ដីឥណ្ឌាក្នុងតំបន់ណាមួយ មេនោះមិនមែនមកជួបនឹងមជ្ឈដ្ឋានមួយដែលខ្លួនស្គាល់ជាធម្មតាហាក់ដូចជាត្រីមកនៅក្នុងទឹកឡើយ។ ខ្លួនទៅជាមេកើយនៃក្រុមមនុស្សដែលមានមូលដ្ឋានជាតិសាសន៍និងវប្បធម៌ផ្សេង ដូច្នោះត្រូវបត់បែនទៅតាមមជ្ឈដ្ឋាននោះខ្លះៗ ពោលគឺចូលស្ទឹងតាមបទដែរ។ ជនជាតិឥណ្ឌាដើម នឹងជនជាតិឥណ្ឌូ-អឺរ៉ុបក្លាយបន្តិចម្តងៗទៅជាប្រជាជនតែមួយ តាមរយៈមេកើយនោះ ដោយស្តាប់បង្គាប់ថាជាមេពិតប្រាកដ ពោលគឺទុកជាស្តេច។ នេះមកពីបុគ្គលនៃស្តេចនោះអាចជាស្ពានឲ្យជំនឿទាំងពីរបោះដៃរកគ្នាទៅវិញទៅមកបាន ថ្វីត្បិតតែមានមូលដ្ឋានដើមខុសគ្នា។ ពីមុនមក អ្នកស្រុកមូលដ្ឋានធ្លាប់រកអាជ្ញាកណ្តាលណាមួយជាឧបករណ៍ឬជាធ្នាក់សម្រាប់ចាប់យកទេពដែលគ្មានរូបរាងប្រាកដនោះ។ ចំពោះក្រុមឥណ្ឌូ-អឺរ៉ុបដែលកាន់សាសនាវេទវិញ ស្តេចគឺជាអាទិទេពនៅលើដី ហើយជំនឿនេះមានតាំងពីសម័យគម្ពី "ព្រាហ្មណ" ម្ល៉េះ។ ជំនឿទាំងពីរប្រភេទនេះអាចស្រុះស្រួលមូលមតិគ្នាបាន ព្រោះអាជ្ញាកណ្តាលព្រមទាំងទេពលើដីនោះ គេអាចផ្ទុកផ្តាក់ទៅលើបុគ្គលនៃស្តេច។ ប៉ុន្មានសតវត្សតពីនោះមក ព្រះបាទ Alexandre ក៏ដើរតាមគន្លងនោះដែរ គឺថាក្នុងទស្សនៈមួយ ព្រះអង្គជាទេវបុត្រ ឯក្នុងទស្សនៈមួយទៀត ព្រះអង្គជាទេពដែលសោយរាជ្យលើដែនដី។ ទាំងជនជាតិក្រិច ទាំងជនជាតិអាស៊ីក្រោមចំណុះព្រះអង្គ ក៏ទទួលយកគំនិតនេះដោយគ្មានផុលរមាស់។

សាសនាហិណ្ឌូប្រហែលជាដំបូងឡើយករកើតឡើងក្នុងទិដ្ឋភាពជាសាសនាដែលមានមេកើយ។ ហេតុនេះហើយបានជាហិណ្ឌូជាសាសនាដែលភ្ជាប់ខ្លួនជាមួយរាជ្យអំណាចតរៀងមក។ នេះពុំមានន័យថាព្រះរាជានានាទៅដណ្តើមកន្លែងពួកព្រាហ្មណ៍ទេ។ ការងារសាសនាសុទ្ធគឺទុកឲ្យព្រាហ្មណ៍នៅក្នុងវាំងគ្រប់គ្រងដដែល។ ព្រាហ្មណ៍ទាំងនោះ ដែលសុទ្ធសឹងជ្រួតជ្រាបទស្សនៈគម្ពីរវេទផងនិងគម្ពីរ "ព្រាហ្មណ" ផង បានបញ្ចូលមកក្នុងក្បួនច្បាប់ហិណ្ឌូនូវគំនិតទ្រឹស្តីនៃពួកឥណ្ឌូ-អឺរ៉ុប ហើយបានតាក់តែងឡើងជាគម្ពីដែលមានលក្ខណៈសំយោគ ហើយដែលប្រើភាសាសំស្ក្រឹត។ មើលទៅប្រហែលជាសំយោគនេះធ្វើឡើងដោយមានការយល់ស្របពីពួកអារ្យផង ព្រមទាំងពីមជ្ឈដ្ឋានស្តេចដែលមានឈាមជ័រជាឥណ្ឌាអ្នកស្រុកចាស់នោះផង។ មជ្ឈដ្ឋានស្តេចទាំងនេះទទួលការចំណេញច្រើនពីសំយោគខាងលើ ដោយវណ្ណៈឬឋានៈរបស់ខ្លួនតម្រូវឲ្យខ្លួនពង្រឹងលទ្ធិសំយោគនេះ ដែលចុងបញ្ចប់មកក្លាយជាសាសនាហិណ្ឌូ។ ដំណើរវិវឌ្ឍន៍នេះ គេអាចឃើញច្បាស់នៅពេលដែលគម្ពីឈ្មោះថា "ឧបនិសទ" បានត្រូវរៀបរៀងឡើង ត្បិតគម្ពីនេះរៀបរៀងឡើងដោយពពួកព្រាហ្មណ៍ ក្រោមការពិនិត្យពិច័យរបស់ក្សត្រ។ គួរកត់សំគាល់ថា សូម្បីតែព្រះពុទ្ធសាសនា ក៏ឲ្យតម្លៃខ្លាំងទៅលើពិធីដែលទាក់ទងនឹងស្តេចដែរ។ លក្ខណៈនេះជាឥណ្ឌា ច្រើនជាងឥណ្ឌូ-អឺរ៉ុប។

ជំនឿសាសនាដែលពាក់ព័ន្ធខ្លាំងនិងរាជ្យអំណាចនេះជាកត្តាធំបំផុតដែលធ្វើឲ្យសាសនាហិណ្ឌូករកើតឡើង។ លទ្ធផលនោះ គឺថាមេកើយជាមេនៃជាតិសាសន៍ពីរដែលលាយគ្នា ហើយតាមរយៈបុគ្គលរបស់ខ្លួន មេកើយនោះក៏ជាទេពដែលជាសំយោគនៃទេពពីរផ្សេងគ្នាដែរ។

នៅតាមមូលដ្ឋានជនបទនៃប្រទេសឥណ្ឌា ទេពនានាពុំមានបុគ្គលិកលក្ខណៈច្បាស់លាស់ដូចទេពក្នុងសាសនាវេទ ដែលមានចែងល្អិតល្អន់នៅក្នុងគម្ពីផ្សេងៗនោះឡើយ។ ទេពនៃសាសនាវេទអង្គិលខ្លួនមករលាយចូលជាមួយទេពអ្នកស្រុកឥណ្ឌា តាមរយៈបុគ្គលនៃព្រះរាជា។ ដូច្នេះបន្តិចម្តងៗ ទេពសាសនាវេទក៏មកភ្ជាប់ខ្លួននឹងដីធ្លីភូមិកររបស់អ្នកស្រុក។ ទេពវេទសំខាន់នីមួយៗក្លាយទៅជាទេពប្រចាំនិគមធំមួយ ឬក៏ប្រចាំភូមិមួយ។ បើពោលម្យ៉ាងទៀតគឺថា ទេពចាស់ដែលជាអ្នកតាប្រចាំភូមិនោះ ទៅយកឈ្មោះទេពវេទមកដាក់លើខ្លួន មិនតែប៉ុណ្ណោះយកផ្នែកខ្លះនៃរឿងព្រេងទេពវេទមកបញ្ចូល ព្រមទាំងកែកុនរឿងរបស់ខ្លួនផ្ទាល់។ ព្រហ្មញ្ញសាសនាដែលរៀបចំតាក់តែងឡើងនោះ រក្សាហើយពុំប៉ះពាល់ដល់ទ្រឹស្តីឥណ្ឌូ-អឺរ៉ុបប៉ុន្មានឡើយ។ ប៉ុន្តែនៅពីក្រោមទ្រឹស្តីទាំងនោះ ជំនឿនៃអ្នកស្រុកមូលដ្ឋាននៅតែរស់រវើកជាធម្មតា មិនរលាយបាត់បង់ទៅណាឡើយ។ ហេតុនេះពេលដែលសាសនាហិណ្ឌូដែលមានគម្ពីភាសាសំស្ក្រឹតហូរចូលមកចុងបូព៌ាប្រទេសនោះ គំនិតនិងជំនឿចាស់ទាំងប៉ុន្មានក៏ហូរចូលមកជាមួយគ្នាដែរ។ ដោយសារជំនឿចាស់នោះពុំខុសប្លែកអ្វីខ្លាំងពីគំនិតអ្នកស្រុកនៅចុងបូព៌ាប្រទេស អ្នកស្រុកទាំងនោះចាប់យកបានដោយស្រួល ជួនកាលពុំបានគិតថាខ្លួនកំពុងទទួលយកសាសនាមពីឥណ្ឌាផង។

## កិច្ចប្រតិបត្តិសាសនាចាមសព្វថ្ងៃ ៖ ជំនឿលើ kut

*តើមានអ្វីគួរជាទីកត់សម្គាល់នៅចម្ប៉ា? តាមមើលទៅទេពីដែលគេគោរពនៅ* Nha-trang *(ចាមថា* Ya-traṅ, *សំស្ក្រឹតថា "កោដ្ឋារ")* ដើមឡើយជាទេពដែលមានមូលដ្ឋានអ្នកស្រុកសុទ្ធសាធ ហើយដែលទាក់ទងទៅនឹងដីភូមិករ។ សាសនាឥណ្ឌាដែលចូលមកពុំបានទាត់ចោលទេពីនោះឡើយ ផ្ទុយទៅវិញបានរាប់បញ្ចូលនាងនោះថាជាព្រះជាយានៃព្រះឥសូរ ហើយឲ្យឈ្មោះថានាងឧមា ឬនាងបាព៌តី។ មិនតែប៉ុណ្ណោះបន្ថែមងារហៅថា *"ភគវតីកៅដ្ឋារេស្វរី"* មានន័យថា *"នាងដ៏មានប្រភាគ ដែលជាក្សត្រីយ៍លើនគរកៅដ្ឋារ"* ។

គម្ពីឥណ្ឌាមានចែងពីការរួមផ្គុំគ្នារវាងព្រះឥសូរនិងនាងបាព៌តី។ ចំណុចនេះគេមានធ្វើជាបដិមាមើលទៅគួរឲ្យចម្លែក ព្រោះខ្លួនមួយចំហៀងប្រុស មួយចំហៀងស្រី ហើយអ្វីៗក៏ចម្រុះគ្នា ឧទាហរណ៍ទ្រូងមួយចំហៀងមានដោះ រីឯលើបបូរមាត់ម្ខាងទៀតមានពុកមាត់។ សិលាចារឹកជាភាសាសំស្ក្រឹតឲ្យយើងដឹងថា ជំនឿលើទេពចម្រុះនេះមាននៅចម្ប៉ាសម័យបុរាណ ទោះជាគ្មានជាបដិមាក៏មាននៅក្នុងពិធីដែលមានទេពីកៅដ្ឋារនេះដែរ។ សឲ្យឃើញថាទ្រឹស្តីលំអិតនៃសាសនាហិណ្ឌូសុទ្ធសឹងគេស្គាល់នៅចម្ប៉ា។

បើមើលមកសព្វថ្ងៃនេះវិញតែមួយភ្លែត យើងអាចគិតថាជំនឿរបៀបនេះគ្មាននៅសេសសល់អ្វីឡើយ។ ជនជាតិចាមរត់ភៀសខ្លួនមកខាងត្បូង Nha-Trang តែគេមិនភ្លេចទេពីបុរាណនៃដូនតាគេឡើយ ពោលគឺនៅតែហៅថា Po Nagar *(សិលាចារឹកបុរាណហៅថា* Yaṅ Pu Nagara*)* ប្រែថា មហាក្សត្រីយ៍នៃអាណាចក្រ។ ប៉ុន្តែរឿងព្រេងដែលទាក់ទងនឹងឈ្មោះនោះលែងសំដៅទៅលើនាងឧមាជាព្រះជាយានៃព្រះឥសូរទៀតហើយ។ ទេពីនេះត្រឡប់ទៅរកស្ថានភាពដើមវិញ ដោយមានន័យសាជាថ្មីថាជាទេពនៃភូមិករ។ សាសនាហិណ្ឌូដែលបានវាតទីមកដល់តំបន់ឆ្ងាយនេះក៏ត្រឡប់ទៅរកទីកន្លែងដើមរបស់ខ្លួនវិញ។

អ្វីៗតែងមានដំណើការរបៀបនេះ នៅក្នុងកិច្ចប្រតិបត្តិសាសនាចាម ៖ ដំបូងឡើយសាសនាគឺជំនឿអ្នកស្រុកនៅមូលដ្ឋាន បន្ទាប់មកមានការរលាយចូលគ្នាជាមួយសាសនាហិណ្ឌូ លុះដល់ទីបញ្ចប់ក៏ត្រឡប់មករកជំនឿមូលដ្ឋានដើមវិញ។ បើយកករណីពិសេសខាងលើនេះមកពិនិត្យឡើងវិញ ឃើញថាជំនឿហិណ្ឌូនោះរលាយបាត់អស់ទៅហើយពីប្រពៃណីបច្ចុប្បន្ន។ តើមានន័យថាក្នុងដំណើរវិវឌ្ឍន៍ជំនឿនោះ មានការផ្តាច់ខ្លួនពីរដងឬអ្វី? តើនៅលើកទីមួយចាមបានទាត់ចោលនូវទេពផ្សេងៗរបស់ខ្លួនដើម្បីមកចាប់យកលទ្ធិព្រះឥសូរ, លទ្ធិព្រះនារាយណ៍ ឬព្រះពុទ្ធសាសនា ហើយយូរក្រោយមកក៏ទាត់ចោលនូវទេពឥណ្ឌាទាំងនេះវិញ ដើម្បីត្រឡប់មកកាន់ជំនឿមូលដ្ឋានដើមឬអ្វី? មានអ្នកខ្លះយល់ថាដូច្នោះមែន ហើយពន្យល់ដំណើរវិវឌ្ឍន៍នោះថា មកពីឥទ្ធិពលឥណ្ឌាដែលចូលមកចម្ប៉ាមានភាពសើៗ ឬមួយក៏ថាស្រទាប់អភិជនជាអ្នកប្តូរជំនឿមុនគេ។ រីឯម្យ៉ាងទៀតថាមកពីចាមបាក់បែកខ្ទេចខ្ទីដោយចាញ់សង្គ្រាម។ ចំពោះខ្ញុំវិញ ខ្ញុំពុំយល់ដូចនោះឡើយ។ ទីមួយសាសនាហិណ្ឌូពុំមែននាំមកសុទ្ធតែទ្រឹស្តីឥណ្ឌូ-អឺរ៉ុបនោះទេ គឺនាំមកនូវជំនឿនិងទំនៀមទម្លាប់ផ្សេងៗដែលអ្នកស្រុកនៅចម្ប៉ាងាយនឹងចាប់យកដែរ ត្បិតខ្លួនឯងក៏ធ្លាប់មានជំនឿស្រដៀងៗគ្នា។ ដូច្នោះជំនឿចាមជាមូលដ្ឋាននិងជំនឿហិណ្ឌូពុំមានភាពផ្ទុយគ្នាឡើយ។ សូម្បីតែនៅឥណ្ឌាខ្លួនឯងក៏ដំណើរវិវឌ្ឍន៍នោះពុំខុសគ្នាប៉ុន្មាន ពោលគឺជំនឿជាមូលដ្ឋាន

នៃអ្នកស្រុកឥណ្ឌាចាស់ ក៏ប្រហាក់ប្រហែលគ្នានឹងជំនឿអ្នកស្រុកចម្ប៉ាដែរ។ ម្យ៉ាងទៀតយើងនឹងឃើញថា ប្រពៃណីហិណ្ឌូមិនបាត់បង់អស់រលីងពីប្រពៃណីចាមបច្ចុប្បន្ននេះ ដូចការស្រាវជ្រាវពុំស៊ីជម្រៅខ្លះ។ ធ្វើឲ្យយើងស្មាននោះឡើយ។ និយាយឲ្យខ្លី គ្មានការផ្ដាច់ខ្លួនស្រឡះពីគ្នាទេ គឺមានតែការវិវឌ្ឍន៍ធម្មតា។ ពីស.វ.ទី១៥ ដល់ ស.វ.ទី១៩ យើងមិនអាចពោលថាចាមបោះបង់ទេពដែលខ្លួនទទួលពីសាសនាហិណ្ឌូពីបុរាណនោះទេ ព្រោះតាមពិតទៅដែលយើងហៅថាសាសនាហិណ្ឌូនៅចម្ប៉ានោះ គឺតែងផ្អែកលើប្រពៃណីមូលដ្ឋាននៃជនជាតិចាមរៀងពីដំបូងមក ព្រោះការរលាយចូលគ្នានោះកើតឡើងបន្តិចម្ដងៗពីស.វ.ទី២ ដល់ស.វ.ទី៥។ និយាយប្រាំដែលម្ដងទៀតថា សាសនាហិណ្ឌូធ្វើការសម្របសម្រួលជាមួយជំនឿអ្នកស្រុកមូលដ្ឋាននៅឥណ្ឌា ហើយធ្វើការសម្របសម្រួលជាមួយអ្នកស្រុកមូលដ្ឋាននៅចម្ប៉ាដូចគ្នាដែរ។ ហិណ្ឌូបានកែច្នៃទំរង់ជំនឿចាស់ដោយបញ្ចូលប្រពៃណីព្រាហ្មណ៍ខ្លះ និងប្រពៃណីឥណ្ឌូ-អឺរ៉ុបខ្លះ។ រីឯលទ្ធផលគឺថានៅឥណ្ឌាក៏ដូចនៅចម្ប៉ាដែរ ខ្លឹមសារនៃសាសនាទាំងមូលនៅតែផ្អែកលើជំនឿអ្នកស្រុកមូលដ្ឋាន។ អាស្រ័យហេតុនេះហើយបានជាសព្វថ្ងៃ យើងឃើញតែមូលដ្ឋាននេះទេដែលលេចធ្លោឡើង ព្រោះស្រទាប់ជំនឿដែលមានភាសាសំស្ក្រឹតជាយាននោះបាត់បង់ទៅ ដោយសារអាណាចក្រចម្ប៉ាត្រូវរលំ។ ពាក្យថាផ្ដាច់ខ្លួនពីជំនឿចាស់នោះគ្មានន័យអ្វីឡើយ។

ការគោរពបូជាសាសនាចាមបច្ចុប្បន្ននេះ គេស្គាល់ក្នុងភាពស្រពិចស្រពិលនៅឡើយ សូម្បីតែលោក Aymonier ខ្លួនឯងក៏ស្រង់ប្រពៃណីមកពុំទាន់អស់ ព្រមទាំងពុំយល់ឲ្យបានល្អិតល្អន់ផង។ តាមពិតទៅ ខ្ញុំសង្កេតឃើញថាជំនឿជនជាតិចាមសព្វថ្ងៃ ពុំខុសគ្នាអ្វីខ្លាំងពីជំនឿយួនជាមូលដ្ឋានសុទ្ធសាធទេ។ ជំនឿទាំងនេះ អាចចែកចេញជាពីរ។ មួយគឺការបូជាប្រចាំគ្រួសាររៀងៗខ្លួន។ អ្នកស្រាវជ្រាវជាច្រើន ដូចជាលោក Aymonier, លោក Cabaton, អ្នកស្រី Leuba ជាដើម ធ្លាប់បានសិក្សាទៅលើការគោរពបូជាទេពដែលជាទេពរួមគ្នារបស់សហគមន៍ចាម។ បើសង្ខេបមក កិច្ចប្រតិបត្តិទាំងនោះរួមមកនៅការសូត្រផ្សេងៗជាភាសាចាម ហើយសំណូត្រនីមួយៗនោះធ្វើឡើងឆ្ពោះទៅទេពណាមួយជាពិសេស។ ក្រៅពីនោះមានពិធីដង្វាយច្រើនបែបច្រើនមុខនៅទេពទាំងនោះ។ រីឯការគោរពបូជាបុព្វការីជនប្រចាំគ្រួសារវិញ តែងមានការបូជាទៀងទាត់ដែលធ្វើឡើងនៅមុខផ្ទាំងម្យ៉ាងហៅថា kut។ ផ្ទាំង kut នោះជានិមិត្តសញ្ញានៃធាតុដែលគេរើសសម្រាំងមកពីការបូជាសព ជាពិសេសធាតុដែលបានមកពីកន្ទ្រងថ្ងាសសព ហើយដែលគេកប់នៅក្រោមនោះ។ ចំណែកឯទីតាំងនៃពិធីបូជាវិញ គឺអាចជាប្រាសាទបុរាណដែលបាក់បែកខ្លះ បើពុំនោះទេគ្រាន់តែជាខ្ទមអ្វីមួយហៅថា bumoṅ។ រីឯ “ទេព” នោះ ជួនកាលជាបដិមាទេពឥណ្ឌា ជួនកាលជាលិង្គ ឬជួនកាលទៀតគ្រាន់តែជាដុំថ្មប៉ុណ្ណោះ។ ចំពោះន័យជាជម្រៅវិញ ចាមចាត់ទុកថាដូចគ្នាទាំងអស់ គឺថានៅក្រោមរូបភាពអ្វីក៏ដោយ ទាំងនោះសុទ្ធសឹងជាទេពដូចគ្នា។

ឥឡូវនេះគប្បីយើងយកសិលាចារឹកមកពិនិត្យឲ្យហ្មត់ចត់ជាងមុន ព្រមទាំងប្រៀបទៅនឹងការបូជានៅឥណ្ឌាផង។ យើងឃើញថាលិង្គដែលនៅក្នុងប្រាសាទនានា ឬក៏បដិមាមានរូបរាងកាយដូចមនុស្ស មានការឆ្លាក់សំអិតសំអាងគួរគាប់ភ្នែក គួរគោរពដូច្នោះមែន ប៉ុន្តែធាតុពិតគឺពុំមានអ្វីលើសពីដុំថ្មរាងមូលឬទ្រវែងនៅក្នុងខ្ទមដែលគេគោរពនៅតាមព្រៃនោះឡើយ។ គេតែងពោលថា សព្វថ្ងៃព្រះឥសូរ, នាងឧមា, ព្រះនារាយណ៍ សុទ្ធសឹងតែអ្នកស្រុកភ្លេចលែងស្គាល់អស់ហើយ ហើយម្យ៉ាងទៀត ទេពឥណ្ឌាទាំងអម្បាលមាណនៅតាមប្រាសាទ អ្នកស្រុកយល់ថាជាព្រះរាជាជំនាន់ដើម ដែលគេគោរពបូជាហាក់ដូចជាទេព ៖ Po Klauṅ Garai ដែលជាស្ដេចនៅក្នុងរឿងព្រេងមកជំនួសឲ្យព្រះឥសូរ ហើយព្រះឥសូរដែលបង្ហាញព្រះភក្ត្រនៅលើមុខលិង្គ គេលែងស្គាល់ថាជាព្រះឥសូរហើយ ស្គាល់តែថា Po Klauṅ Garai ដូច្នេះ។ តើនេះជាការភ្លេចមែនឬអ្វី? ស្ដេចចាមជំនាន់ដើមថ្វាយព្រះនាមរបស់ព្រះអង្គទៅដល់ប្រាសាទនានា ដែលព្រះអង្គបានសង់ មិនតែប៉ុណ្ណោះទៅដល់ទេពដែលតំកល់នៅក្នុងប្រាសាទនោះ។ នេះបញ្ជាក់ថា មកពីព្រះអង្គយល់ថាបុគ្គលរបស់ព្រះអង្គធ្លុះបញ្ចាំងពីរូបភាពទេពនៅលើផែនដី។ គំនិតរបៀបនេះមាននៅចម្ប៉ាផង មាននៅឥណ្ឌាផង។ ចំពោះឥណ្ឌាខ្លួនឯង គំនិតរបៀបនេះជាជំនឿរបស់អ្នកស្រុកចាស់ផង ជាគំនិតដែលពួកឥណ្ឌូ-អឺរ៉ុបនាំចូលមកផង។ មិនថានៅឥណ្ឌាឬនៅចម្ប៉ាឡើយ សាសនាហិណ្ឌូនាំមកនូវភាពត្រចះត្រចង់ដែលជាសម្បកក្រៅ ធ្វើឲ្យមេកើយដែលពោលនៅខាងលើក្លាយទៅជា “ស្ដេច” ដែលមានភាពសក្ការៈកាន់តែខ្លាំងឡើងៗ។ តែខ្លឹមសារពិតប្រាកដនៃជំនឿនោះនៅដដែល គឺថាស្ដេចនៅតែជាមេកើយដែលស្អិតរមួតជាប់និងដីនៃអាណាចក្រ ហើយតាមរយៈព្រះអង្គ ប្រជាជនទាំងមូលក៏ភ្ជាប់ចំណងទៅនឹងទេពនៃដីនោះដែរ។ គឺទេពនៃដីនេះហើយដែលអាចបង្កបង្កើតទ្រព្យសម្បត្តិភោគផលឲ្យសហគមន៍បាន។ ជាធម្មតា ទេពនៃទីកន្លែងនានាលំបាកនឹងយល់ថាជាអ្វីពិតប្រាកដណាស់។ ដូច្នោះហើយបានជាឥណ្ឌាមានទេវកថាព្រមទាំងទ្រឹស្ដីប្លែកៗគ្នាដែលបង្កបង្កើតឡើងដោយព្រហ្មញ្ញសាសនា ហើយដែលអ្នកស្រុកទទួលយកព្រមទាំងអនុវត្តន៍មកលើទេពរបស់ខ្លួនដែលមានស្រាប់។ នៅចម្ប៉ាក៏ពុំខុសអ្វីពីនោះដែរ ៖ សាសនាហិណ្ឌូយកទេវកថារបស់ខ្លួនមកលាបលនលើទេពរបស់អ្នកស្រុកចាមដែលមានស្រាប់ ធ្វើឲ្យទេពចាមទាំងនោះរីកស្រស់បំព្រងឡើង។

ខ្ញុំបាននិយាយអម្បាញ់មិញថា kut ចាមពុំខុសអ្វីពីបន្ទះក្តារដូនតាចិនឬយួននោះទេ ហើយនេះក៏ពុំខុសអ្វីខ្លាំងពីផ្នូរបុរាណមួយប្រភេទនៅឥណ្ឌាដែរ។ វត្ថុទាំងនោះសុទ្ធសឹងជារូបភាពមួយទៀត (double) នៃសព ឬបុព្វការីជនដែលចែកស្ថានទៅហើយ។ ចំណុចនេះត្រូវមានការបញ្ជាក់បន្តិច។ បន្ទះ kut គឺជាអ្នកដែលស្លាប់នោះតែម្តង ពុំខុសគ្នាអ្វីពីដុំថ្មដែលជាទេពឬអ្នកតានោះឡើយ។ ជំនឿចាស់យូរលង់មកហើយនេះ ហាក់ដូចជាឲ្យយើងគិតថា ថ្មសំដៅទៅលើវត្តមាននៃអ្នកស្លាប់។ គំនិតនេះហាក់ដូចជាចំឡែកណាស់ ប៉ុន្តែខ្ញុំយល់ថានេះមិនមែនជាការយល់ច្របូកច្របល់ ដោយសារប្រជាជននោះស្ថិតនៅក្នុងអារ្យធម៌មួយអន់ថយអ្វីឡើយ ផ្ទុយទៅវិញគឺជាទស្សនៈមួយដែលឆ្លងការវិវឌ្ឍន៍ច្រើនដំណាក់មកហើយ។ សូមជ្រាបថាជំនឿនេះជាដានឬស្លាកស្នាមនៃជំនឿចាស់មួយ ដែលពាក់ព័ន្ធនឹងការបែងចែកនិងការគ្រប់គ្រងដីធ្លី។ ក្នុងនោះ មេកើយដើរតួសំខាន់ ត្បិតជាអាជ្ញាកណ្តាលឬចំណុចកណ្តាលដែលភ្ជាប់ភូមិករទៅនឹងសហគមន៍អ្នកស្រុក។ Kut ដែលគេដំកល់នៅកណ្តាលភូមិនោះ ពុំគឺអ្វីក្រៅបុព្វការីជននៃសហគមន៍នោះឡើយ។ ហេតុនេះគ្មានអ្វីគួរឆ្ងល់ទៀតទេ បន្ទះថ្ម kut សំដៅឬស្នងឲ្យដីភូមិករទាំងមូលតែម្តង។ រីឯបុព្វការីជនដែលនៅក្នុងបន្ទះថ្មដដែលនោះគឺបញ្ជាក់អំពីសិទ្ធិកាន់កាប់ដីធ្លីនៃកូនចៅរបស់ខ្លួនតៗមកទៅលើភូមិករ។ ក្នុងន័យនេះ បន្ទះថ្មជាប្រជាជនផង ជាភូមិករផង។ បើគ្មានបន្ទះថ្មនោះទេ ឃើញថាពុំដឹងមានអ្វីធ្វើជាមុខដំណាងចំណងដែលភ្ជាប់សហគមន៍ទៅនឹងដីរបស់ខ្លួន។

ជំនឿឬការគោរពបូជានេះ មានដំណើរការទៅបានលុះត្រាតែមនុស្សអាចចាប់, ប៉ះពាល់, ឬសម្គាល់ទេពដែលពុំដឹងជាអ្វីច្បាស់នោះ ដោយវិធីណាមួយ។ បន្ទះថ្មkut ហាក់ដូចជាបញ្ជាក់ថាបុព្វការីជនអាចចេញពីក្នុងដីមកបាន។

ខ្ញុំសូមរំលឹកម្តងទៀតថា គួរយើងប្រៀបធៀបរឿងនេះទៅនឹងប្រពៃណីចិនបុរាណ ដែលចាត់ទុកបុព្វការីជននៃសន្តតិវង្សណាមួយថាជាទេពប្រចាំនគរទាំងមូល។ ហេតុនេះគេសម្គាល់ទេពបានតាមរយៈភិនភាគមុខមាត់នៃបុព្វការីជននោះឯង។ តែនិយាយនេះ គឺក្នុងលក្ខខ័ណ្ឌដែលថាសន្តតិវង្សនោះនៅគ្រប់គ្រងនគរនៅឡើយ។ ម្យ៉ាងទៀតនៅពេលដែលគេសែនអាហារជាប្រក្រតីដល់ដូនតារបស់គេ ជនជាតិចិនតែងតែយកអាហារនោះទៅថ្វាយឲ្យបន្ទះក្តារដូនតា (សូមមើលនៅខាងលើ)។ នៅពេលនោះតែម្តង ត្រូវមានកូនចៅណាម្នាក់មកទទួលទានសំណែន ហើយមនុស្សនេះគេហៅថា "សព" (cadavre) ក្នុងមួយពេលនោះ ត្បិតទទួលទានជំនួសដូនតា។ មានន័យថា ដូនតាដែលនៅក្នុងបន្ទះក្តារនោះ បង្ហាញខ្លួនច្បាស់ក្នុង "រូបស្នង" ក្នុងមួយរយៈពេល។ បើពិនិត្យជំនឿនេះជាក់លាក់ ឃើញថាពុំមែនដូនតាដូរទីកន្លែងពីក្តារបន្ទះមកក្នុងខ្លួនអ្នកនោះទេ។ គឺដូនតានៅក្នុងក្តារបន្ទះនោះដដែល តែក្នុងពេលជាមួយគ្នានោះ ក៏មកនិមិត្តតាមរយៈអ្នកស្នងផង ពោលឲ្យខ្លីមក គឺថាមានវត្តមានពីរព្រមគ្នា។

មានប្រពៃណីយួននិងចិនម្យ៉ាងទៀត ដែលលោក Przyluski បានប្រទះនិងផ្សព្វផ្សាយ ហើយដែលទាក់ទងនឹងចំណុចនេះដែរ។ អ្នកទាំងនោះជឿថា ថ្មឬឥដ្ឋមួយដុំដែលកប់នៅក្នុងដីជាយូរអង្វែងដោយប្រការណាមួយ យូរទៅក៏ហាក់ដូចជាស្រូបយកថាមពលដីនោះមកបញ្ចូលក្នុងខ្លួន។ ថ្មឬឥដ្ឋនោះក៏ទៅជា "ថ្ម-ទេព" (pierre-génie) ដូចបានពោលពីមុនមក។ មិនតែប៉ុណ្ណោះ បន្តិចម្តងៗ ថ្មឬឥដ្ឋនោះមិនត្រឹមតែដូរធម្មជាតិរបស់ខ្លួនឡើយ គឺថែមទាំងដូររូបរាងទៀតផង គឺថាអាចមានរូបជាឆ្កែ, សេះ, មនុស្ស។ល។ អាស្រ័យទៅតាមធាតុរបស់ខ្លួន។ ជំនឿនេះបង្ហាញថាទេពចាក់ឫសនៅក្នុងថ្ម ហើយបើពោលតាមបញ្ញជិត Cadière ទេពនោះ "គឺជាថ្មនោះឯង"។

គំនិតទាំងអស់នេះ ជនជាតិចាមសុទ្ធសឹងប្រកាន់យក។ តទៅនេះខ្ញុំនឹងបង្ហាញរូបkut ខ្លះៗដែលស្រង់ចេញមកពី សៀវភៅ Inventaire des monuments cams de l'Annam នៃលោក Parmentier។

[ បញ្ចាំងរូបភាព]

*១៨. (រូបលេខ ៦)* kut នេះមានរូបរាងសាមញ្ញបំផុត មានតែភ្ជីខ្លះជាលំអរ ប៉ុន្តែឥតមានអ្វីសម្គាល់ថាជាភិនភាគមនុស្សសោះឡើយ។

*១៩. (រូបលេខ ៧)* kut នេះមានក្បាច់លំអរច្រើនជាងមុន។ ផ្នែកខាងលើមានលំនាំជាម្កុកការពារអ្វីមួយ, ផ្នែកកណ្តាលមានផ្ទាំងច្នូតទទឹង លំនាំដូចខ្សែក្រវ៉ាត់, រីឯផ្នែកក្រោមសង់ខាងមើលទៅហាក់ដូចជាត្រចៀក។ សរុបមក ទាំងអស់នេះមានលំនាំព្រាលៗជាមនុស្ស។ សណ្ឋានមនុស្សនោះដុះចេញពីក្នុងមកក្រៅ ដូច "ថ្ម-ទេព" ដែលដុះចេញពីដី ហើយដែលពោលអម្បាញ់មិញ។



*រូបលេខ ៦* - kut, បន្ទះថ្មជូនតាចាម



*រូបលេខ ៧* - kut ពាក់មួក

២០. *(រូបលេខ ៨)* នេះគឺ kut បី ដែលមើលមួយភ្លែតទៅគ្រាន់តែជាផ្ទាំងសន្លឹកថ្មធម្មតាប៉ុណ្ណោះ។ ប៉ុន្តែផ្ទាំងដែលនៅកណ្តាលនាំយើងឲ្យឃើញវែងឆ្ងាយជាងនេះ។ គឺជា kut នៃមនុស្សស្រី។ ខ្ញុំហ៊ាននិយាយលើសនេះទៅទៀត គឺថា kut នោះ "ជា" មនុស្សស្រី។ សូមសង្កេតក្នុងសក់មនុស្សស្រីនេះ។ ខ្ញុំអាចបង្ហាញដល់លោកអ្នកនូវចម្លាក់ថ្មខ្លះ ដែលគេអាចឃើញស្រោមក្នុងសក់ស្រីរាងមូលដូចយើងឃើញនៅលើ kut នេះដែរ។ ឥឡូវចូរយើងមើលក្នុងសក់ពិតប្រាកដ ដែលគេប្រទះឃើញនៅតាមសមុច្ច័យនានា ហើយដែលគេតែងហៅថា "ព្រះរាជទ្រព្យនៃស្តេចចាម" ដូចតែងឃើញមាននៅទីខ្លះ។ នៅប៉ែកខាងត្បូងនៃអាណាម។

២១. ស្រោមក្នុងនៅក្នុងសមុច្ច័យ Tinh-my *(រូបលេខ ៩)* បើយើងយករូបនេះមកគិតឃើញថា kut នោះស្នងខ្លួនឲ្យមនុស្សស្រីម្នាក់។ ខ្ញុំបាននិយាយម្តងហើយថា ចេតិយ៍ក្នុងព្រះពុទ្ធសាសនាពុំមានន័យអ្វីខុសពីនេះឡើយ ពោលគឺជាកាយមនុស្សដែលជាសព បានសេចក្តីថាកាយនៃព្រះពុទ្ធ។ ដើម្បីរកការប្រៀបធៀបផ្សេងទៀត ខ្ញុំសូមលើកយកទំនៀមនិងជំនឿនៅនេប៉ាល់និងនៅទីបេ ព្រោះនៅឯណោះគេយល់ថា ប៉ែកភ្ញីភ្លើងនៅលើកំពូលចេតិយ៍របស់គេជាតំណាងនៃអណ្តាតភ្លើងដែលផុសចេញនៅលើព្រះកេសនៃព្រះសក្យមុនី។ អស់លោកទាំងអស់ជ្រាបស្រាប់ហើយថា នៅប្រទេសលាវ ព្រះពុទ្ធរូបតែងតែមានអណ្តាតភ្លើងនេះនៅលើព្រះកេស។ ចេតិយ៍ទាំងអស់នេះគឺគ្រាន់តែជារូបស្នងខ្លួន ដែលទ្រង់ទ្រាយសណ្ឋានរាងមនុស្សគេមិនបង្ហាញឲ្យឃើញច្បាស់ លើកលែងតែក្នុងសក់ឬសក់។ ឯ kut ចាមដែលយើងនិយាយនេះក៏ដូចគ្នាដែរ។ មានចំនុចសំខាន់មួយទៀត ៖ ជួនកាលចាមគូរភ្នែកពីរនៅលើថ្មដែលខ្លួនគោរព។ នេះធ្វើឲ្យយើងនឹកឃើញដល់បន្ទះក្តារជូនតានៃចិនដែលមានចំណុចឈាមសន្មត់ថាជាភ្នែកនោះ។ ហើយម្យ៉ាងទៀតសូមលោកអ្នក



*រូបលេខ ៨* - kut បី

កុំភ្លេចថា គេមានគូររូបភ្នែកនៅលើចេតីយ៍ដែរ។ បន្ទះក្តារជូនតាចិន, kut ចាម, ឬចេតីយ៍ទាំងនេះ សុទ្ធសឹងជាជំនឿសាសនាជាមូលដ្ឋានពិតប្រាកដនៃជនជាតិអាស៊ី ពោលគឺសាសនាដែលផ្អែកលើដី ឬមិនអាចផ្តាច់ចេញអំពីដី។

អ្នកខ្លះអាចមិនយល់ស្របហើយប្រកែកថា ស្រោមក្នុងសក់ដែលឆ្លាក់នៅលើ kut នៃមនុស្សស្រីគ្រាន់តែជានិមិត្តរូប ឬថាគ្រាន់តែជាក្បាច់លំអរដែលពុំគួរអ្វីឲ្យពោលថា បន្ទះ kut គឺជាសពស្រីនោះ។ ដើម្បីកុំឲ្យស្រពិចស្រពិលតទៅទៀត ខ្ញុំសូមបង្ហាញរូបដូចតទៅនេះ ដើម្បីឲ្យឃើញទីបញ្ចប់នៃគំនិតដែលថាស្នងនោះ។



*រូបលេខ ៩ - គម្របក្នុងសក់ (អ្នកស្រុកយល់ថាជាព្រះរាជទ្រព្យស្តេចចាម, ស្រុក Tinh-my)*

២២ kut មានរូបមនុស្ស *(រូបលេខ ១០)* នេះគឺឧទាហរណ៍បី ស្រង់ចេញមកពីឧទាហរណ៍ផ្សេងៗជាច្រើន។ ទីនេះយើងឃើញច្បាស់ហើយថា kut ដែលជាបុព្វការីជននោះ មានមុខមាត់ជាបុព្វការីជនមែន ៖ ថ្មគឺជាមនុស្ស រីឯមនុស្សនោះចេញពីថ្មខ្លួនឯងតែម្តង។



*រូបលេខ ១០ - kut មានរូបមនុស្ស*

បើពោលពី kut នេះសុទ្ធតែម្តង គឺគ្មានសាសនាហិណ្ឌូអ្វីមកលាយឡំទេ ត្បិត kut អាចប្រៀបផ្ទឹមទៅជាមួយគ្រឿងបូជានៃបុព្វការីជនចិន ឬយួនទៅវិញ ហើយយ៉ាងណាក៏ដោយទាក់ទងទៅនឹងប្រពៃណីអ្នកស្រុក។ ប៉ុន្តែឥឡូវនេះចូរយើងក្រឡេកមើលទៅវត្ថុបូជាខ្លះដែលពិបាកយល់ន័យ ហើយដែលហាក់ដូចជាស្ពានភ្ជាប់kut ចាមទៅនឹងបដិមានៃអារ្យធម៌ឥណ្ឌា។

២៣ *ព្រះឥសូរអង្គុយចោងហោង (សារមន្ទីរ* Tourane *)*, ដៃពីរ, មានអលង្ការ, ពស់ពាក់ជាសង្វារព្រាហ្មណ៍, ភ្នែកទី៣នៅលើថ្ងាស, កាន់កង្វេរីនិង ត្រីសូល៍ *(សូមបកទៅមើលរូបលេខ ២)*។

ព្រះឥសូរនេះពិតជាបដិមាសាសនាហិណ្ឌូមែន ពោលគឺមានភ្នែកនៅលើថ្ងាស,កង្វេរីព្រមទាំងត្រីសូល៍ជាដើម។ ប៉ុន្តែទេពនេះ គេឆ្លាក់ជាប់ផ្ទាំងថ្មសំប៉ែតមួយ មិនខុសពីរូបបុព្វការីជនដែលផុសចេញពីផ្ទាំង kutឡើយ។ ពិតមែនហើយថា ជង្គង់បត់ជាលក្ខណៈឥរិយាបទមួយដែលគេនិយម

ហៅថាឥរិយាបទផ្កាឈូក ឬមួយថាឥរិយាបទពេជ្រ (បទ្មាសន, វជ្រាសន) ដែលគេស្គាល់ទូទៅថាមាននៅក្នុងបដិមាសាស្ត្រឥណ្ឌាជាធម្មតា ប៉ុន្តែចំពោះព្រះឥសូរនោះវិញ ជង្គង់បត់នោះហាក់ដូចរួញចូលក្នុង។ គេអាចយកឧទាហរណ៍ដទៃទៀតមក ដើម្បីបង្ហាញថាមានបដិមាពាក់កណ្តាលខ្លួន ដែលលេចចេញមកពីបន្ទះផ្ទាំងថ្មមួយ ប៉ុន្តែដែលរបៀបបង្ហាញនោះធ្វើឲ្យយើងនឹកឃើញទៅដល់ kut ដែលមានមុខមនុស្ស។ នៅទីនេះ សិល្បៈនិងសិលាចារឹកមានភាពស្របគ្នាទាំងស្រុង ៖ បដិមាសាសនាហិណ្ឌូ គឺស្នងឲ្យទេពផង ព្រះរាជាផងព្រមគ្នា ពោលគឺឲ្យព្រះឥសូរផង ឲ្យបុព្វការីជនផង។ និយាយម្យ៉ាងទៀតថា ស្នងឲ្យព្រះឥសូរក្រោមរូបភាពជាបុព្វការីជន។ ហេតុនេះហើយបានជាគេឃើញថា បដិមានោះបង្ហាញនៅក្នុងសភាពមួយចន្លោះ kut និង បដិមាពេញលេញដែលពុំភ្ជាប់ខ្លួននឹងផ្ទាំងថ្ម។

តើប្រភេទបដិមានេះលេចចេញពីពេលណាមក? មើលតាមភិនភាគឬរចនាបទ ឃើញថាកើតចេញមកនៅពេលដែលសិល្បៈត្រចះត្រចង់មួយកំពុងចុះអន់ថយទៅរកភាពបាត់បង់ ពោលគឺពេលដែលស្រទាប់អារ្យធម៌ត្រចះត្រចង់មួយកំពុងចុះស្រុត។ យើងអាចនិយាយថាជាចលនាឥទ្ធិពលឥណ្ឌាដែលដើរថយក្រោយ។ រីឯសារៈសំខាន់គឺនៅត្រង់នេះឯងហើយ។ kut ទាំងនេះបង្ហាញថាចាមកំពុងដកស្រង់ន័យដើមនៃទេពរបស់ខ្លួន ដែលខ្លួនធ្លាប់តែជឿថាយូរលង់មកហើយនោះ ឲ្យចេញពីបដិមាដែលមានសំបកក្រៅជាឥណ្ឌា ហើយដែលខ្លួនធ្លាប់និយមមួយរយៈពេលនោះយកមកបញ្ជាក់ឲ្យច្បាស់ក្រោមរូបភាពដើមឡើងវិញ។ បុព្វការីជន ពេលនេះចាមដកយកពីបដិមាព្រះឥសូរឬទេពឥណ្ឌាណាមួយមកវិញ ដើម្បីបំរើប្រយោជន៍ដល់គ្រួសារខ្លួន ឬក៏ប្រជាជាតិខ្លួន។ kut ដែលលេចធ្លោមកវិញជំនួសឲ្យបដិមាប្រភេទឥណ្ឌានោះ អាចឲ្យយើងពិចារណាអំពីការវិវឌ្ឍន៍បញ្រ្ចាសពីនោះមកវិញ ពោលគឺឲ្យយើងគិតថា តើបដិមាប្រភេទឥណ្ឌាមានឥទ្ធិពលសាយភាយមកជំនួសឲ្យkut, ផ្ទាំងថ្ម, គោលភូមិនោះយ៉ាងដូចម្តេចទៅវិញ?

## ការគោរពលិង្គនៅចម្ប៉ា

សេចក្តីពិភាក្សានៅខាងលើនេះនឹងជួយឲ្យយើងយល់ថានៅចម្ប៉ា បដិមាទេពមានដៃ, មានជើង, មុខមាត់ ពុំដែលបានទទួលការវាយតម្លៃខ្ពស់ស្មើនឹងលិង្គទេ។ សូម្បីតែនៅប្រទេសឥណ្ឌាខ្លួនឯងក៏ដោយ លិង្គឬមុខលិង្គ (ដែលមានព្រះភក្ត្រព្រះឥសូរបង្ហាញលើលិង្គនោះ) សំដៅឆ្ពោះត្រង់ទៅរកការគោរពបូជាដី ដែលធ្លាប់មានវត្ថុធម្មជាតិគ្មានរូបរាងជាមនុស្សអ្វីមួយជានិមិត្តរូប។ យើងបានឃើញហើយថា និមិត្តរូបដែលគ្មានរូបរាងជាមនុស្សតែដែលជាវត្ថុអ្វីមួយ (ដុំថ្ម, ដំបូក...) ពុំមែនជាសញ្ញាថាគំនិតឬជំនឿនោះនៅក្នុងកំរិតទាបទេ។ លិង្គឬមុខលិង្គនេះហើយ ដែលមានន័យជាទីបំផុតចំពោះចាម។ មុខព្រះឥសូរដែលអាចចេញនៅលើលិង្គ មានន័យដូចជាបដិមាទេពមានដៃមានជើងសព្វគ្រប់ដែលគេយកទៅដាក់ជិតលិង្គមួយ ក្នុងពេលធ្វើកិច្ចពិធី, ឬក៏អាចប្រៀបប្រដូចទៅព្រះរាជាដែលស្នងឲ្យទេព ដែលមានព្រះនាមដូចទេព។ សូមជ្រាបថាបដិមាព្រះឥសូរទាំងប៉ុន្មានដែលស្តេចភ្ជាប់ព្រះនាមជាមួយ គឺសុទ្ធសឹងជាបដិមាស្តេចនោះឯងតែម្តង។ គំនិតទាំងអស់នេះសុទ្ធសឹងចាក់ឫសត្រង់ទៅពិធីពីបុរាណយូរលង់មក ដែលពាក់ព័ន្ធទៅនឹងដី, ដែលទេពនៃដីនោះរលាយចូលគ្នាជាមួយបុគ្គលនៃបុព្វការីជន, ហើយដែលជាចំណងសម្ព័ន្ធរវាងសហគមន៍ទាំងមូលនិងដីរបស់ខ្លួននោះ។ មរតកជំនឿសាសនានៅឥណ្ឌាមុនពួកអារ្យចូលមកនោះមានភាពរឹងប៉ឹងណាស់។ ពេលដែលលទ្ធិព្រះឥសូរចូលមក អ្នកស្រុកនៅឥណ្ឌូចិនចាប់ឬទទួលយកជំនឿអំពីលិង្គបាន អាស្រ័យដោយន័យនៃលិង្គនោះត្រូវគ្នានឹងមូលដ្ឋានជំនឿរបស់ខ្លួនពាក់ព័ន្ធនឹងដី។ ទាំងសិលាចារឹក ទាំងផ្នែកផ្សេងទៀតនៃបុរាណវិទ្យា បង្ហាញថាមានការស្របគ្នាក្នុងរឿងនេះ។

សាសនារដ្ឋនៅកម្ពុជាក្តីនៅចម្ប៉ាក្តី សុទ្ធសឹងផ្អែកទៅលើការភ្ជាប់បុគ្គលស្តេចទៅនឹងព្រះឥសូរ តាមរយៈលិង្គជាបដិមានៃរាជ្យមួយ។ លោក Finot ពន្យល់អំពីជំនឿនោះថា នាមកាយនៃព្រះរាជា ដែលនៅក្នុងវិស័យអភិធម្មជាតិរលាយចូលគ្នាជាមួយនឹងទេពនៅក្នុងលិង្គនោះឯង។ គឺលោក Cœdès ដែលបានមុជជ្រៅវែងឆ្ងាយជាងគេក្នុងចំណុចនេះ។ តាមរយៈការសិក្សាសិលាចារឹក លោកពន្យល់ថា គឺនាមកាយ (moi subtil) នៃព្រះរាជាដែលកំពុងគ្រងរាជ្យនោះហើយ ដែលស្ថិតនៅក្នុងលិង្គ។ គឺក្រោមរូបភាពនេះហើយ ដែលព្រះរាជាភ្ជាប់ខ្លួនទៅនឹងព្រះឥសូរ។ នៅចម្ប៉ាក៏ដូចគ្នាដែរ ពោលគឺការរលាយចូលគ្នារវាងនាមកាយព្រះរាជានិងទេពនេះ ប្រព្រឹត្តទៅតាមរយៈលិង្គ ត្បិតលិង្គនៃរាជ្យនោះមានឈ្មោះតែមួយ ដែលជាព្រះនាមស្តេចផង ព្រះនាមព្រះឥសូរផង។ បើយកតែបុគ្គលនៃព្រះរាជាមកគិត គេអាចយល់ថា ព្រះរាជាត្រូវគេលើកតម្កើងស្មើព្រះ (apothéose)។

នៅក្នុងអត្ថបទឈ្មោះថា Note sur l'apothéose au Cambodge លោក Cœdès សរសេរថា “ការបូជានេះលើកតម្កើង

ស្តេចដល់កម្រិត។ គេនិយមប្រតិបត្តិខ្លាំងណាស់ ព្រោះងាយស្រួលនឹងបត់បែន”។ តែភ្លាមបន្ទាប់មកលោកបន្ថែមទៀតថា “គំនិតដើមមកពីឥណ្ឌាមែនពិត ប៉ុន្តែកិច្ចប្រតិបត្តិនៅកម្ពុជាបង្ហាញថា គំនិតដើមនោះរីកសាយវែងឆ្ងាយទៅទៀត។ ការស្រាវជ្រាវទៅអនាគតអាចនឹងបញ្ជាក់ប្រាប់យើងថា ឥទ្ធិពលអ្វីខ្លះដែលជំរុញឲ្យមានការរីកសាយនេះ” ។

ខ្ញុំយល់ថាឥឡូវនេះប្រហែលយើងអាចចាប់ផ្តើមមានចម្លើយខ្លះៗ។ ជាដំបូងយើងត្រូវយកលទ្ធិព្រះឥសូរមកពិនិត្យឲ្យកាន់តែជ្រៅ ត្បិតមកទល់ពេលនេះយើងពុំសូវបានយកចិត្តទុកដាក់ពីមូលដ្ឋានគ្រឹះនៃជំនឿអ្នកស្រុកជនបទដែលពាក់ព័ន្ធទៅនឹងដីប៉ុន្មានឡើយ ហើយយើងច្រើនតែយកទ្រឹស្តីឥណ្ឌូ-អឺរ៉ុបមកធ្វើការផ្តាច់មុខ។ ម្យ៉ាងទៀតយើងត្រូវជ្រួតជ្រាបឲ្យច្បាស់អំពីជំនឿនៅឥណ្ឌា មុនពេលពួកអារ្យចូលមក ដែលប្រហាក់ប្រហែលគ្នានឹងជំនឿអ្នកស្រុកនៅឥណ្ឌូចិនមុនពេលឥណ្ឌាចូលមកដែរ។ តាមពិតទៅ អ្នកស្រុកនៅចុងបូព៌ាប្រទេសទទួលចាប់យកលទ្ធិព្រះឥសូរបានយ៉ាងងាយ ត្បិតលទ្ធិនេះ បើពិនិត្យខ្លឹមសារជម្រៅពិតប្រាកដនោះ ពុំមានការប្លែកអ្វីខ្លាំងពីជំនឿដែលខ្លួនមានស្រាប់ឡើយ គ្រាន់តែថា សម្បកក្រៅមានភាពត្រចះត្រចង់ជាង។

ចំពោះប្រការថា ព្រះរាជាគេលើកតម្កើងស្មើព្រះ (apothéose) នោះ គឺត្រូវតែមួយផ្នែកឬមួយជ្រុងប៉ុណ្ណោះ។ ព្រះរាជា, ព្រះញាត្តិវង្សពុំត្រឹមតែទៅសោយសុខនៅស្ថានសួគ៌លើមេឃនោះឡើយ សំខាន់បំផុតនោះគឺព្រះអង្គឬសមាជិកព្រះញាត្តិវង្សទៅសោយសុខនៅចំណុចណាមួយលើដីនៃអាណាចក្រ។ ព្រះអង្គពុំក្លាយទៅជាព្រះឥសូរ ឬព្រះប្រាជ្ញាបារមី ដែលជាទេពលើលោកទាំងមូលនេះទេ តែគឺជាព្រះឥសូរឬព្រះប្រាជ្ញាបារមីនៃប្រាសាទ ឬបូជនីយស្ថានណាមួយដែលវាតឥទ្ធិពលឬអនុភាពទៅលើដែនអាណាចក្រនៅពេលនោះ។ “លើកតម្កើងស្មើព្រះ” នេះមានន័យថាលើកតម្កើងជាព្រះ តាមរូបភាពទេពនៃដីដែលមានទំហំតូចឬធំណាមួយ។ ដូច្នេះគឺតាមរយៈដីតូចឬធំនោះហើយ ដែលព្រះរាជា (ឬសមាជិកព្រះញាត្តិវង្សផ្សេងៗ) ត្រូវគេលើកតម្កើងថាជាព្រះនៅលើមេឃ។ សព្វថ្ងៃនេះយើងដឹងថា ទោះជានៅឥណ្ឌាខ្លួនឯង ក៏លទ្ធិព្រះឥសូរមានការគោរពបូជាក្នុងន័យដូចគ្នានេះច្រើន ពោលគឺផ្អែកទៅលើទំនាក់ទំនងរវាងទេពនៅដី ជាមួយទេពនៅស្ថានលើនោះ។ ពោលម្យ៉ាងទៀតថា គេទាញយកទេពនៅស្ថានលើនោះឲ្យមកគង់នៅស្ថានក្រោម គ្រប់គ្រង ឬភ្ជាប់ព្រះអង្គទៅនឹងផ្ទៃដីណាមួយ។

ជំនឿលើលទ្ធិព្រះឥសូរដែលអ្នកស្រុកប្រកាន់យកនេះ មានជីវិតទៅបានដោយបត់បែនតម្រូវខ្លួនទៅតាមប្រពៃណីចាស់បុរាណយូរលង់ទាក់ទងទៅនឹងដីភូមិករ។ យើងឃើញថាមានទំនាក់ទំនងពីរ។ មួយគឺទំនាក់ទំនងរវាងទេពនៃដីភូមិករជាមួយបុព្វការីជននៃសហគមន៍ពាក់ព័ន្ធ (មេកើយឬបព្វជិត) មួយទៀតគឺរវាងទេពលើលោកទាំងមូលដែលគង់នៅស្ថានសួគ៌ ជាមួយទេពនៃដីភូមិករសហគមន៍នោះ។ ហេតុនេះហើយបានជាទេពលើលោកព្រមទាំងអ្នកស្រុកមករលាយចូលគ្នានៅក្នុងបុគ្គលនៃទេពភូមិករនោះ។  ការសិក្សាអំពីជំនឿនៅឥណ្ឌូចិនបង្ហាញកាន់តែច្បាស់ថាអាណាចក្របុរាណផ្សេងៗនៅទីនោះចាប់យកលទ្ធិព្រះឥសូរប្រកាន់មកថាជាសាសនារដ្ឋ ក្នុងន័យឬក្នុងទស្សនៈខាងលើនេះឯង ហើយចេះតែសំអិតសំអាងទ្រឹស្តីឥសូរនោះបន្តិចម្តងៗ តាមជំនឿ មូលដ្ឋាននិងសេចក្តីត្រូវការរបស់ខ្លួន។
ឥឡូវចូរយើងមើលរូបមួយចំនួនទៀតជាបញ្ចប់។

[ បញ្ចាំងរូបភាព]

២៤-២៥៖ *លិង្គនៅលើបល្ល័ង្កមានចង្អូរបង្ហូរទឹក (ចម្ប៉ា)*

លិង្គទាំងពីរប្រភេទនៅចម្ប៉ាដែលគេតម្កល់នៅចំកណ្តាលបល្ល័ង្កសម្រាប់ធ្វើពិធីស្រោចស្រប់នេះ ធ្វើឲ្យយើងយល់ភ្លាមថា គេបង្ហាញពីនិមិត្តរូបនៃលិង្គដែលភ្ជាប់ខ្លួនទៅនឹងដី។ លិង្គទី២ (*រូបលេខ១១*) គឺយកពីគំនូរនៃលោក Parmentier ។ បន្ទាប់ពីផ្នែកលើដែលមានរាងមូលមក លិង្គក្លាយមកជាប្រាំបីជ្រុង ហើយចុះក្រោមមកទៀត គេឃើញចាប់ផ្តើមមានរាងបួនជ្រុង។ គម្ពីក្នុងលទ្ធិឥសូរនិយាយថាប៉ែកខាងលើជាសញ្ញានៃព្រះឥសូរ, ប៉ែក៨ជ្រុងជាស្រោមដែលព្រះនារាយណ៍យកមកវាន់ រីឯ៤ជ្រុងខាងក្រោមជាស្រោម ដែលព្រះព្រហ្មយកមកពាត់។ គម្ពីទាំងនោះបន្ថែមទៀតថា ព្រះធរណីមកពាត់ឱបលិង្គ ពីលើស្រោមនៃព្រះព្រហ្មនោះទៅទៀត។ ខ្ញុំបាននិយាយហើយថា សូមឲ្យលោកអ្នកគិត ថាបល្ល័ង្កនោះជានិមិត្តរូបនៃដី ពោលឲ្យច្បាស់ជាងនេះគឺដីនៃអាណាចក្រនោះ។ ចូរយើង នឹកស្រមៃមើលថា ព្រាហ្មណ៍បុរោហិតម្នាក់កំពុងតែស្រោចស្រប់ទឹកមន្តទៅលើលិង្គនោះ ហើយទឹកមន្តកំពុងតែហូរធ្លាក់មកលើបល្ល័ង្កជាដើងទម្រ។ តើលោកអ្នកយល់ថានិមិត្តរូប នៃអង្គជាតិមានភាពខ្លាំងក្លាណាស់ទៅឬ? ចំពោះខ្ញុំវិញ

ខ្ញុំយល់ឃើញថាគ្មានខុសគ្នាអ្វីទាំងអស់ពីកិច្ចដែលមនុស្សជំនាន់បុរេប្រវត្តិកំពុងស្រោចស្រប់ដុំថ្មអ្នកតា នឹងទឹកដែលហូរចុះទៅដីដើម្បីទាក់ទាញភ្លៀងឲ្យបង្អុរចុះមក ដើម្បីឲ្យដីបង្ករបង្កើតភោគផលឡើង។ ពិតហើយថាលិង្គនោះជាអង្គជាតិ ហើយរូបរាងក្រៅជាអង្គជាតិ។ រីឯអង្គជាតិនោះបង្ហាញពីសក្តានុពលនៃទេពឥស្វរក្នុងការបង្ករបង្កើនភោគផល។ ប៉ុន្តែន័យមានជ្រៅហួសពីនេះទៅទៀត ពោលគឺ នៅពីក្រោយនិមិត្តរូបព្រះឥស្វរនោះ លិង្គមានទំនាក់ទំនងផ្ទាល់ទៅនឹងដើមកំណើតរបស់ខ្លួនដែលជាដុំថ្មធម្មជាតិគ្មានការកែច្នៃ អ្វីទាំងអស់ពីមនុស្ស៖ គឺជាដុំថ្មដែលមានសក្តានុពល ត្បិតជាដុំថ្មនៃភូមិករ។

ក្នុងលទ្ធិព្រះឥស្វរនៅឥណ្ឌូចិន មានចំណុចជាច្រើនដែល យើងធ្លាប់តែ ស្រពិចស្រពិល តែដែលឥឡូវនេះយើងអាចពន្យល់បាន បើយើងយល់ អំពីបញ្ហាដី ភូមិករ នេះ។



រូបលេខ១១ - លិង្គនៅMi-son

លោកបណ្ឌិត Bosch ដែលជាសហសេវិករបស់យើងនៅ Batavia[៦] ធ្លាប់បានមកធ្វើសន្និសីទមួយយ៉ាងត្រចះត្រចង់នៅទីនេះ ស្តីអំពីសិល្បៈជ្វាដែលយើងទាំងអស់គ្នាមានការស្ងប់ស្ងែងយ៉ាងខ្លាំងនាបីឆ្នាំមុននេះ។ ថ្មីៗនេះ លោកបានធ្វើសេចក្តីពន្យល់អំពីមុខលិង្គដែលគេប្រទះឃើញជារឿយៗ ទាំងនៅចម្ប៉ា ទាំងនៅកម្ពុជា ដោយយករឿងព្រេងមួយមកជាជំនួយ។ រឿងនេះពោលថា ថ្ងៃមួយព្រះនារាយណ៍និងព្រះព្រហ្មជណ្តើមគ្នាធ្វើធំនៅ លើលោកយើងនេះ។ ពេលនោះស្រាប់តែមានសសរភ្លើងដ៏ធំមួយឆេះសន្ធោសន្ធៅចេញមកនៅចន្លោះអ្នកទាំងពីរ។ អ្នកទាំងពីរនោះចង់ដឹងថាសសរភ្លើងវែងប៉ុណ្ណា ទើបព្រះព្រហ្មកាឡាខ្លួនទៅជាហង្សហិចហើរឮដ៏អាកាស ប៉ុន្តែនៅតែរកចុងមិនឃើញ។ ចំណែកឯព្រះនារាយណ៍ក៏តំណែងខ្លួនទៅជាជ្រូកព្រៃ ហើយឈ្មុសចូលទៅក្នុងដីរាប់សតវត្ស ក៏នៅតែរកគល់សសរនោះពុំឃើញ។ អ្នកទាំងពីរអស់តម្រិះក៏មកឱនលំទោននៅមុខសសរ។ សសរដែលជាលិង្គនោះហែកខ្លួនបន្តិច ហើយព្រះឥស្វរក៏ចេញមកបង្ហាញខ្លួន។ រឿងនេះគេនិយមឆ្លាក់ខ្លាំងណាស់នៅឥណ្ឌា។ តទៅនេះជាការបក ស្រាយរបៀបចាម៖

២៦. ផ្តែនៅTrach-pho៖ លិង្គោទ្ភវមូរតិ *(រូបលេខ ១២)*

ខ្ញុំសូមបង្ហាញមុខលិង្គពីរ ដែលលោកបណ្ឌិត Bosch បានឃើញថាជាការបង្ហាញរឿងដែលទើបតែនិយាយមកនេះ។ មួយជាលិង្គដ៏ល្អមួយនៅកម្ពុជា មួយទៀតនៅវត្តពោធិ នាក្រុងបាងកក។

២៧. មុខលិង្គ *(រូបលេខ ១៣)*

រូបលេខ១២ - ព្រះឥស្វរ បង្ហាញខ្លួននៅលើលិង្គ, ស្រុកTrach-pho





រូបលេខ១៣ - មុខលិង្គ

[៦] សព្វថ្ងៃត្រឡប់មកហៅថាJakarta វិញ។

២៨. មុខលិង្គ

លើមុខលិង្គទាំងពីរនេះ គេពុំឃើញមានដានណាមួយនិយាយពីព្រះនារាយណ៍និងព្រះព្រហ្មឡើយ។ លោកបណ្ឌិត Bosch យល់ថាព្រះភក្ត្រព្រះឥសូរនៅលើលិង្គនោះគ្រប់គ្រាន់និងឲ្យយល់ថាជារឿងនោះហើយ។ ប៉ុន្តែយ៉ាងណាក៏លោកពោលនេះនៅក្នុងការវុញ្ញរាដែរ ព្រោះថ្វីត្បិតតែរឿងនេះគេស្គាល់ច្បាស់នៅចុងបូព៌ាប្រទេស ដូចមានសិលាចារិកជាតឹកតាង ក៏រឿងនេះនៅតែជារឿងពិសេសហើយខ្លី ពុំសមថាគេយកទៅឆ្លាក់បង្ហាញជាមុខលិង្គ។

ម្យ៉ាងទៀតខ្ញុំអាចនិយាយថា គេលំបាកនឹងផ្ដាច់ប្រពៃណីចម្លាក់លិង្គដែលមានព្រះភក្ត្រព្រះឥសូរតែមួយ ឲ្យដាច់ចេញពីប្រពៃណីមួយទៀតដែលមាននៅចម្ប៉ាផង នៅឥណ្ឌាផង គឺប្រពៃណីស្រោបលិង្គដោយបំពង់មួយជាមាសឬជាប្រាក់។ បំពង់នោះជាស្រោមដែលបត់បែនរាងទៅតាមលិង្គនោះ គឺមានផ្នែកមូល, ប្រាំបីជ្រុង, និងបួនជ្រុង។ នៅជុំវិញស្រោមឬបំពង់ គេមានឆ្លាក់ព្រះភក្ត្រព្រះឥសូរច្រើនកន្លែង។ បើនៅឥណ្ឌាផងគេតែងឃើញមានមុខបួន ឬប្រាំនៅលើលិង្គនីមួយៗ។ នេះគឺឧទាហរណ៍មួយនៅឥណ្ឌាខាងត្បូង ៖

២៩. លិង្គមានមុខបួន (*រូបលេខ ១៤*)

រឿងព្រេងដែលលោកបណ្ឌិត Bosch លើកឡើងនោះ ពុំនិយាយពីមុខបួននេះឡើយ ថ្វីត្បិតតែលិង្គនេះមានន័យប្រហាក់ប្រហែលគ្នានិងលិង្គដែលមានមុខមួយ។ ដូច្នេះការបកស្រាយត្រូវធ្វើឲ្យបានទូលំទូលាយជាងនេះ ហើយយើងអាចធ្វើទៅបានដោយសារយើងបានជ្រួតជ្រាបពីដំណើរដើមទងនៃលទ្ធិព្រះឥសូរឥណ្ឌារួចមកហើយ។

លិង្គគ្រាន់តែចុះតំណពូជពង្សពីដុំថ្ម ដែលជានិមិត្តសញ្ញានៃទេពពាក់ព័ន្ធនឹងដីសហគមន៍មួយប៉ុណ្ណោះ។ យើងយល់ជ្រួតជ្រាបហើយថា ក្នុងជំនឿចាស់ព្រេងនាយ ទេពនិងដុំថ្មជាអ្វីតែមួយញែកចេញពីគ្នាពុំបាន ប៉ុន្តែព្រមជាមួយគ្នានោះ ទេពក៏សណ្ឋិតក្នុងបុគ្គលនៃមេកើយឬបព្វជិតដែលអន្ទងខ្លួនពុំខុសអ្វីពីបុព្វការីជនក្នុងជំនឿចិនដែលជាបន្ទះក្ដារផង ហើយដែលអាចទទួលទានសំណែនតាមរយៈក្ដារដែលស្នងឲ្យ "បុគ្គល" ខ្លួនឯងនោះផង។ ចូរយើងវែកញែកចំណុចនេះបន្តិចតទៅទៀត។ ខ្ញុំបានពោលអំពី "វត្តមានពីរ" ព្រមគ្នា។ យើងអាចធ្វើការប្រៀបធៀបជំនឿចិននិងជំនឿឥណ្ឌាឲ្យកាន់តែជ្រៅទៀត។ នៅប្រទេសចិន ទេពដែលជាដីមានបន្ទះក្ដារពីរសម្រាប់បូជា។ បន្ទះមួយនោះតម្កល់នៅមួយកន្លែង ពុំអាចប្ដូរទីកន្លែងបានទេ។ បន្ទះទីពីរអាចលើកមកក្នុងក្បួនដង្ហែរអ្វីមួយបាន។ បន្ទះក្ដារទាំងពីរសុទ្ធសឹងស្នងឲ្យទេពតែមួយ។ មិនតែប៉ុណ្ណោះ មេទ័ពម្នាក់ដែលចេញទៅធ្វើសឹកតែងនាំបន្ទះដែលចល័តបានទៅតាមខ្លួន។ ពេលនោះ ទេពនៅតែស្ថិតនៅក្នុងបន្ទះដែលតាំងនៅមួយកន្លែងដដែល ត្បិតដោយសារទេពជាដី ទេពនោះពុំអាចចាកចោលភូមិករឡើយ។ ប៉ុន្តែក្រោមរូបភាពមួយទៀត ទេពដដែលនោះក៏ទៅតាមកងទ័ពដែរ។ ក្នុងប្រការនេះ កិច្ចពិធីធ្វើតាមក្បួនច្បាស់លាស់ណាស់ ៖ មេទ័ពម្នាក់ដែលស្លាប់ទៅ មិនខុសពី "ខ្មោច" (ឬ "សព") នៃបុព្វការីជនដែលនៅក្នុងក្ដារបន្ទះនោះទេ គឺក្នុងនាមជា "ខ្មោច" ដែរដែលមេទ័ពនោះនាំក្ដារបន្ទះដង្ហែរទៅជាមួយទ័ព។ វត្តមានដែលពោលពីលើ កាន់តែមានច្រើនជាន់ទៅទៀត ព្រោះទេពថ្វីត្បិតតែសណ្ឋិតជាប់នឹងក្ដារបន្ទះដែលមិនរើរុះទីកន្លែងនោះ (ក្រោមដើមឈើណាមួយ, ឬក្នុងជំបូកណាមួយ។ល។) ក៏ដោយ ក៏មានវត្តមាននៅក្នុងក្ដារដែលហែរតាមទ័ព ហើយនៅក្នុងសពមេទ័ពនោះព្រមគ្នាផង។ ជំនឿចិននោះដូចគ្នានឹងជំនឿក្នុងលទ្ធិព្រះឥសូរ។ នៅតាមប្រាសាទព្រះឥសូរនានា គេតែងឃើញមានលិង្គដែលតម្កល់ជាប់នៅមួយកន្លែង ហើយព្រមពេលជាមួយនោះ គេមានលិង្គឬបដិមាព្រះឥសូរពេញលេញសម្រាប់ប្រើប្រាស់ក្នុងក្បួនដង្ហែរ (ហៅថា "ឧត្សវវិគ្រហ") ប៉ុន្តែជាអត្ថន័យ គឺបដិមានៅក្នុងប្រាសាទនិងបដិមាដង្ហែរ ជាវត្ថុតែមួយ គឺថាជាទេពតែមួយដែលមានវត្តមានពីរ ដូចក្នុងជំនឿចិនដែរ។ ព្រះឥសូរក្នុងវិស័យជាអទិទេពនោះ គង់ក្នុង



*រូបលេខ ១៤ - លិង្គនៅឥណ្ឌា, មានមុខបួនឆ្លាក់គ្រប់ទិស (យកតាមគំនូរលោក H. Krishna Shastri)*

តួប៉មប្រាសាទដដែល។ ប៉ុន្តែក្រោមទិដ្ឋភាពមួយទៀត អទិទេពដដែលនេះនៅក្នុងក្បួនដង្ហែរ។ សូមកុំភ្លេចថាក្នុងករណីខ្លះគេឃើញមានលិង្គដែលគេតម្កល់នៅក្រោមដើមឈើណាមួយដោយមិនប្តូរផ្លាស់ទីកន្លែង។ ម្យ៉ាងទៀតខ្ញុំសូមបញ្ជាក់ថា ទេពឥសូរដែលនៅក្នុងលិង្គអចល័ត ហើយដែលជាមួយគ្នានោះនៅក្នុងលិង្គចល័តក្នុងក្បួនដង្ហែរ អាចភ្ជាប់ខ្លួនជាមួយនឹងមេកើយនៃសហគមន៍មនុស្ស ឬក៏បព្វជិតដែលចេញពីសហគមន៍នោះផង។

សិលាចារឹកនៅឥណ្ឌូចិនឲ្យយើងដឹងថាបុគ្គល ឬ “អត្ម័ន” នៃស្តេចដែលជាជនួលនៃរាជ្យ គឺស្ថិតនៅក្នុងលិង្គប្រចាំរាជ្យនោះឯង។ ក្នុងន័យនេះ ព្រះរាជាជាទេពដែលគេអាចឃើញនឹងភ្នែក រីឯអាត្ម័នរបស់ព្រះអង្គវិញគឺស្ថិតនៅក្នុងលិង្គ។ អាត្ម័នសម្ងាត់នោះគឺព្រះឥសូរនោះឯង។ ពេលដែលព្រះឥសូរផុសចេញពាក់កណ្តាលខ្លួនមកក្រៅលិង្គនោះ គឺជាព្រះឥសូរដែលកំពុងបង្ហាញវត្តមានទីពីររបស់ព្រះអង្គ ក្រោមរូបភាពជាមានមុខមាត់នៅ ក្នុងរាងកាយ នៃព្រះរាជា។ ជំនឿនេះបង្ហាញច្បាស់ថាចុះតំណពូជពង្សពីជំនឿចាស់យូរលង់ណាស់មកហើយ ដែលបដិមាគ្រាន់តែជាដុំថ្មធម្មជាតិមួយ ឬបង្គោលមួយដើមដែលគេដាំនឹងដី ហើយដែលទេពអាចចេញមកសណ្ឋិតក្នុងខ្លួនបព្វជិត ឬអាចារ្យពិធី ពេលដែលគេអន្ទងមក។

បើយើងមើលទៅលើក្រណាត់សម្តងទៀត យើងឃើញថាលិង្គឥណ្ឌាដែលមានមុខបួននេះនៅរង់ចាំសេចក្តីពន្យល់ពីយើង។ ខ្ញុំគ្រាន់តែអាចធ្វើអត្ថាធិប្បាយត្រួសៗប៉ុណ្ណោះ។ យោបល់អាចមានផ្សេងៗពីគ្នា រីឯឯកសារសម្រាប់ទ្រទ្រង់យោបល់ខ្ញុំ គឺខ្ញុំពុំទាន់មានពេលយកចេញពីហិបសៀវភៅនិងសំណេរមករៀបចំឲ្យមានរបៀបរៀបរយនៅឡើយ។ ចំណុចដែលត្រូវយល់ដំបូងបង្អស់ គឺគំនិតដែលបណ្តាក់គ្នាពីមួយទៅមួយ។ កើតទៅជាកង់មួយជុំដែលជាលក្ខណៈជំនឿនៅអាស៊ីខាងត្បូង។ យើងបានឃើញហើយថា ទេពមានឫសគល់ជាប់នឹងដីហើយគ្មានរូបរាង ឬអាចសន្មតថាគ្មានភិនភាគអ្វីទាំងអស់។ ទេពនោះហៅថាជា “ទេព” បាន ពេលដែលគេយកមកទល់ឬផ្គូផ្គងគ្នាជាមួយសហគមន៍មនុស្សណាមួយក្រុម។ ទំនាក់ទំនងគ្នាធ្វើទៅបានតាមរយៈពិធីជាគុណប្រយោជន៍ដល់សហគមន៍នោះ។ បើនិយាយពីអាណាចក្រមួយទាំងមូល សម្ព័ន្ធរវាងទេពនិងសហគមន៍នៅមានជាធរមាន ដរាបណាសន្តតិវង្សនោះនៅមានពុំដាច់។ ពោលឲ្យខ្លីគឺទេពភ្ជាប់សហគមន៍ទៅនឹងដី។ ត្រឡប់មកនិយាយពីព្រះឥសូរវិញ ៖ ព្រះឥសូរមានតែមួយអង្គ គឺពុំមានបួនអង្គឡើយ។ មុខទាំងបួន (ដែលលោកអ្នកឃើញបីនៅលើរូបនេះ) ពុំមានន័យថាមានទេពបួនអង្គទាល់តែសោះ។ ឥឡូវចូរយើងយកគំនិតថាមានការ “បណ្តាក់គ្នា” ដូចខ្សែនោះមកពន្យល់។ នៅទីនេះយើងមានរូបព្រះឥសូរដែលជាទេពនៃរាជ្យ ក្រោមទិដ្ឋភាពបួនយ៉ាង ម្យ៉ាងៗបែរព្រះភក្ត្រទៅទិសមួយ។ យើងអាចគិតថាទេពនេះបញ្ចេញវត្តមានព្រះអង្គទៅទិសទាំងបួន ពោលគឺទៅសហគមន៍មនុស្សបួន។ ការបែងចែកអាណាចក្រមួយទៅជាសហគមន៍បួននោះគឺអ្វី? គឺនៅឥណ្ឌាបុរាណ គេបែងចែកប្រទេសមួយទៅជាតំបន់ ឬខេត្តបួនដូច្នោះឯង។ លិង្គដែលមុខបួននេះ ពុំគឺអ្វីក្រៅពីនិមិត្តរូបនៃការគ្រប់គ្រងអាណាចក្រក្នុងវិស័យសាសនានិងនយោបាយ ស្របទៅតាមទិសនីមួយៗនោះឡើយ។ គំនិតនេះក៏មាននៅតាមជាតិសាសន៍ដែលទទួលអារ្យធម៌ឥណ្ឌាដែរ[៧]។

ឥឡូវយើងក្រឡេកមើលទៅចិនម្តងទៀត។ ដូចលោកអ្នកជ្រាបស្រាប់ហើយ អាណាចក្រចិនបុរាណគេចែកជាបួនទៅតាមទិសនេះ ពោលក្នុងទស្សនៈជំនឿនិងពិធី។ អាស្រ័យហេតុនេះ វាំងស្តេចត្រូវមានព្រះរាជមន្ទីរឬអាគារបួន ហើយព្រះរាជាគង់ផ្លាស់គ្នាពីមួយទៅមួយ ស្របទៅតាមរដូវ។ ប្រពៃណីនេះលោកH. Maspéro មាននិយាយនៅក្នុងស្នារដៃដ៏ត្រចះត្រចង់របស់លោកដែលមានចំណងជើងថាLa Chine antique។ពីព្រះរាជមន្ទីរឬអាគារនីមួយៗនោះ ព្រះរាជាជះឬបញ្ជូនសក្តានុពលភាពនៃព្រះអង្គទៅទិសដែលពាក់ព័ន្ធ។ រីឯជំនឿឥណ្ឌាស្មុគស្មាញជាងនេះបន្តិច ៖ ទិសជួនកាលមានបួន ជួនកាលមានប្រាំ (ដោយរាប់បញ្ចូលទិសដែលនៅចំពីលើក្បាលយើង) ជួនកាលទៀតមានប្រាំមួយ (ដោយរាប់បញ្ចូលទិសបញ្ច្រាសនៃទិសទីប្រាំ) ឬរហូតដល់ដប់ផង។ មុខនៅលើលិង្គ ទោះជាចំនួនបួន, ប្រាំ, ប្រាំមួយ តែងតែបែរទៅចំណុចទិសទាំងនោះ។ មុខនៃទេពរបស់រាជ្យដែលបែរទៅរកទិសទាំងបួននោះដើរតួនាទីដូចជាព្រះចៅអធិរាជចិនដែរ។ សិលាចារឹកមួយនៅចម្ប៉ាអាចបញ្ជាក់ថាការប្រៀបធៀបនេះមានន័យពិតប្រាកដ។ សិលាចារឹកនោះ ជាភាសាសំស្រ្កឹត បានមកពី Mi-son ហើយចារនៅគ.ស.១១៦៣។ ក្នុងនោះនិយាយពីព្រះបាទជ័យឥន្ទ្រវរ្ម័នថ្វាយស្រោមយ៉ាងប្រណិតមួយ ដែលមានរូបមុខប្រាំសម្រាប់លិង្គព្រះឥសូរមួយ ៖ “ទេពនេះថ្វីត្បិតតែមានសណ្តានចិត្តល្អ ពុំអាចប្រទានពរជ័យដល់តំបន់ទាំង១០ឡើយ។ ឥឡូវនេះ ព្រះអង្គក្លាយជាទេពារក្ស មានព្រះភក្ត្រប្រាំព្រមទាំងព្រះឱស្ឋប្រាំ។ តាមរយៈព្រះឱស្ឋដែលមើលឃើញយ៉ាងច្បាស់នេះ ព្រះសិវៈ (ព្រះឥសូរ) មានសម្លេងខ្ទរខ្ទារច្រើនបែបយ៉ាង”។ មានសិលាចារឹកមួយទៀតប្រៀបធៀបមុខទាំងបួនដែលរចនាលើស្រោមលិង្គទៅនឹងប្រទីបបួនដែលបំភ្លឺចតុទិស។ ពាក្យពេចន៍ទាំងនេះសព្វគ្រប់ល្មមឲ្យយល់ការអធិប្បាយខាងលើនេះហើយ។ ព្រះចៅអធិរាជចិនគង់ផ្លាស់ពីព្រះរាជមន្ទីរមួយទៅព្រះរាជមន្ទីរមួយដើម្បីឲ្យក្នុងមួយឆ្នាំៗបានសម្លឹងមើលទៅគ្រប់ខេត្តធំៗទាំងបួន។ ឯលិង្គមុខបួននេះក៏ដូចគ្នាដែរ គឺជាមុខតែមួយដែលនិមិត្តក្រោមទិដ្ឋភាពផ្សេងៗគ្នាទៅតាមលក្ខណៈនៃតំបន់ នីមួយៗនៃអាណាចក្រ។

---

[៦] ប្រពៃណីឥណ្ឌានិយាយទៀតថាមានព្រះឥសូរ “ទី៥” ដែលមើលមិនឃើញ ព្រោះគេពុំឆ្លាក់ហើយដែលនៅចំកណ្តាលលិង្គ។ ចំពោះខ្ញុំ នោះហើយជាទេពពេញលេញដែលគេសរុប ទិដ្ឋភាពទាំងបួន ហើយដែលគេឆ្លាក់នោះ។

ឥឡូវយើងពុំសូវមានការលំបាកប៉ុន្មានទេក្នុងការពន្យល់បន្ថែមទៅលើគំនិតដ៏ជ្រៅរបស់បណ្ឌិត Bosch។ មុខលិង្គទាំងអស់ ពុំមែនគ្រាន់តែជានិមិត្តនៃរឿងលិង្គផុសមកចន្លោះព្រះឥសូរនិងព្រះព្រហ្មប៉ុណ្ណោះទេ *(លោកបណ្ឌិត Bosch ក៏ពុំដែលមានគំនិតពន្យល់ខ្ចីរបៀបនេះដែរ)*។ មុខលិង្គនេះទាក់ទងទៅនឹងប្រពៃណីជំនឿពីបុរាណកាលដែលមានយូរអង្វែងមក។ ទេវកថាដែលលោកបណ្ឌិត Bosch បានលើកយកមក ហើយដែលមានការបង្ហាញតាមចម្លាក់នានានៅឥណ្ឌានិងឥណ្ឌូចិននោះ ក្លាយចេញមកពីជំនឿជាមូលដ្ឋានដើមនៃអ្នកស្រុក។

រីឯមុខលិង្គឯទៀត ជាពិសេសលិង្គដែលមានមុខច្រើន ក៏ចេញមកពីមូលដ្ឋាននៃអ្នកស្រុកនោះឯងដែរ។ នេះគឺចលនាផ្សេងគ្នាពីរ ដែលវិវឌ្ឍន៍ស្របគ្នា ហើយដែលចេញមកពីមូលដ្ឋានតែមួយ។ ប្រភពដើមតែមួយនៃប្រពៃណីទាំងពីរនេះ គឺការគោរពបូជាពីបុរាណកាល ដែលក្នុងនោះទេពមានវត្ថុធម្មជាតិមួយជាស្នង ហើយដែលអាចចេញមកប្រាស្រ័យជាមួយក្រុមមនុស្សបាន ដោយសណ្ឋិតខ្លួននៅក្នុងបុគ្គលនៃបព្វជិត, មេកើយ, ឬអាចារ្យណាមួយដែលធ្វើពិធីនោះ។ ទេព, ដុំថ្ម, មេកើយទាំងនេះរមួតចូលគ្នាក្រោមទិដ្ឋភាពជាព្រះឥសូរ ឬជាលិង្គនៃរាជ្យ។ ជួនកាលក្រោមទិដ្ឋភាពជាព្រះឥសូរដែលនិមិត្តជាបួន, ប្រាំ, ឬប្រាំមួយ ទៅតាមការបែងចែកតំបន់ឬខេត្តធំៗនៃអាណាចក្រ។ រីឯជំនឿលើដីជាមូលដ្ឋានដើមនោះពុំដែលរង្គោះរង្គើទៅណាឡើយ។

*៣០. រូបបំបែកជាពីរនៃ* Po Nraup *(រូបលេខ ១៥)*

រូបចុងក្រោយបង្អស់នេះ សរុបគោលគំនិតទាំងអស់ ដែលខ្ញុំបាន យកមកលាតត្រដាងឡើង។ នៅលើបល្ល័ង្ក តើយើងឃើញលិង្គដែលគេពុះតាមបណ្តោយជាពីរ, ឬជាផ្ទាំងបង្អែក, ឬជាមួយទៀតជា kut? ឯរូបភិនភាគមនុស្សដែលចេញមកពាក់កណ្តាល តើជាព្រះឥសូរឬក៏ព្រះរាជាអង្គណាមួយ? សព្វថ្ងៃនេះ ប្រជាជនចាមចាត់ទុកថាជាព្រះបាទ Po Nraup ។ លោក Parmentier ជាម្ចាស់គំនូរនេះពោលថា៖ “*ភាពចំឡែកនៃបដិមានេះ ស្ថិតនៅត្រង់រូបនោះមានរូបតូចមួយទៀតនៅពីមុខ ហាក់ដូចជានៅលើភ្លៅ ប៉ុន្តែដែលមានមុខមាត់ដូចគ្នា។ អ្នកស្រុកចាមសព្វថ្ងៃអះអាងថាជាព្រះរាជបុត្រនៃស្តេចនោះ*”។ ចំពោះប្រការនេះ គេអាចសង្ស័យថាជាទេពដែលចេញមកពីថ្ម រីឯរូបទីពីរជារូបចម្លងទេពដដែលនោះមកក្នុងបុគ្គលនៃព្រះរាជា។ បើការសង្ស័យនេះត្រូវនឹងការពិត នោះមានន័យថាជាទេពមួយអង្គដែលការពារព្រះរាជា គឺពុំមែនឪពុកនិងកូនទេ។ ប៉ុន្តែយើងនឹងឃើញថាការបកស្រាយទាំងពីរផ្អែកនៅលើជំនឿតែមួយ។ តាមពិតទៅការបកស្រាយទាំងពីរនោះ ចាក់ស្រេះចូលគ្នា។

លោកអ្នកជ្រាបហើយថា ស្តេចចាមសម័យបុរាណតែងថ្វាយនាមរបស់ព្រះអង្គទៅលិង្គដែលព្រះអង្គសាង។ នៅ Mi-Son លិង្គដែលព្រះបាទភទ្រវរ្ម័នសាងមានឈ្មោះថា “*ភទ្រេស្វរ*”។ ព្រះបាទសម្ភុវរ្ម័ន ដែលសោយរាជ្យបន្ទាប់មក បានសាងលិង្គដដែលនោះសាជាថ្មីឡើងវិញ ដោយថ្វាយព្រះនាមថា “*សម្ភុ-ភទ្រេស្វរ*” ពោលគឺជាការផ្គួបព្រះនាមព្រះអង្គផ្ទាល់ទៅជាមួយព្រះនាមព្រះរាជាមុន។ ក្រោយមកទៀតមកព្រះបាទឥន្ទ្រវរ្ម័នទី១ គោរពបូជាលិង្គមួយដែលមាននាមថា “*ឥន្ទ្រភទ្រេស្វរ*”។ ឈ្មោះលិង្គទាំងនេះងាយយល់ណាស់ គឺថាព្រះរាជាជាព្រះឥសូរដែលអាចមើលឃើញនៅលើដីនេះ។ ប៉ុន្តែមិនមែនសំដៅលើព្រះឥសូរដែលជាទេពលើលោកឬចក្រវាឡទាំងមូលទេ គឺព្រះឥសូរជាម្ចាស់នៃអាណាចក្រចម្ប៉ា។ ហេតុនេះហើយ ជាការធម្មតាទេដែលនាមព្រះរាជាសំដៅទៅលើទិដ្ឋភាពមួយនៃព្រះឥសូរដែលព្រះអង្គស្នងនោះ។ បើយើងយល់ស្របថាដូច្នេះហើយ យើងអាចសួរតទៅទៀតថា ការស្នងរាជ្យពីអង្គមួយទៅអង្គមួយធ្វើឡើងរបៀបណា? យើងបាននិយាយពីលើថា បុព្វការីជននិងទេពរលាយចូលគ្នា ក្រោមរូបភាពជាទេពមួយដែលមានតួនាទីនិងព្រំដែនច្បាស់លាស់។ ជំនឿនោះហាក់ដូចជានិមិត្តរូបនៃសម្ព័ន្ធឬកិច្ចសន្យាអ្វីមួយដែលភ្ជាប់សហគមន៍មនុស្សទៅនឹងដីជាទីសក្ការៈរបស់ខ្លួន។ ព្រះរាជាមួយ



*រូបលេខ ១៥ - រូប* Po Nraup *ពីរជាន់គ្នា*

អង្គ។សុទ្ធសឹងចុះតំណពូជពង្សពីបុព្វការីជនដែលបង្កើតសន្តតិវង្សនោះ ដូច្នោះព្រះរាជាជានិមិត្តសម្តែងក្រោមរូបភាពជាបុគ្គលនៃការបន្តសម្ព័ន្ធឬកិច្ចសន្យានោះឯង។ សម្ព័ន្ធឬកិច្ចសន្យាដែលមានទេពជាជន្ទល់ នៅតែមានដដែល ហើយគេនៅតែហៅដដែលថា "ភទ្រេស្វរ"។ ប៉ុន្តែព្រះបាទសម្ភុវរ្ម័នបានមកឡាយព្រះហស្តលេខាបន្ថែមលើកិច្ចសន្យានោះ ដោយបញ្ចូលព្រះនាមព្រះអង្គឲ្យក្លាយទៅជា "សម្ភុភទ្រេស្វរ" នេះបើខ្ញុំនិយាយជាភាសាច្បាប់វិញ។ ធ្វើយ៉ាងនេះ ព្រះអង្គក៏ក្លាយទៅជាព្រះឥសូរដែរ ប៉ុន្តែជាព្រះឥសូរដែលចុះតំណមកពី "ឥស្វរ_ភទ្រេវរ្ម័ន" ។ នាមនៃលិង្គទាំងអស់នោះហាក់ដូចជាបញ្ជីនៃការស្នងរាជ្យដែរ។

ស្តេចមួយអង្គ។ដែលសោយរាជ្យតៗគ្នា សុទ្ធសឹងជាបុគ្គលដែលថតចម្លងឬផ្តិតចេញពីបុគ្គលនៃបុព្វការីជន ដែលជាដើមកំណើតនៃសន្តតិវង្ស។ តែដើមឡើយ ដោយហេតុថាជាជនទីមួយនៃពូជពង្សខ្លួន បុព្វការីជននោះគឺជាទេពដែលចេញមកពីលិង្គឬពីថ្មធម្មជាតិនោះឯង។ ដូច្នេះន័យនៃ Po Nraup គឺមានសិលាចារិក Mi-Son ជួយបំភ្លឺ។Po Nraup នោះជាទេពផង ជាស្តេចផង ជាឪពុកនៃកូនរបស់ខ្លួនផង ហើយជាទេពនៃកូននោះទៀតផង។ Po Nraup ចេញពីបង្អែកនោះមកក្រៅ បែងភាគខ្លួនទៅជាពីរ ហើយពខ្លួនឯងនៅលើភ្លៅខ្លួនឯង ៖ សម្ព័ន្ធឬកិច្ចសន្យានោះក៏បន្តទៅទៀតជាធម្មតា។

## ជម្រៅនៃឥទ្ធិពលឥណ្ឌា និងសំណល់មរតកនៅចម្ប៉ាសព្វថ្ងៃ

អារ្យធម៌ដែលចូលមកចម្ប៉ាពុំមែនជ្រួតជ្រាបតែទៅលើស្រទាប់សង្គមតែមួយ ពោលគឺស្រទាប់អភិជនប៉ុណ្ណោះទេ។ ឥឡូវគួរយើងចោទសួរថា តើចាមទទួលពីឥណ្ឌាមក នូវអ្វីដែលខ្លួនពុំទាន់មានឬមួយយ៉ាងណា? ប្រការនេះគឺពិតជាដូច្នេះហើយ។ អ្វីៗដែលទទួលមកពីឥណ្ឌា សុទ្ធសឹងមានភាពត្រចះត្រចង់ ទោះជាខ្លឹមសារជាមូលដ្ឋាននៃគំនិតឬជំនឿដែលទទួលមកនោះដូច ឬប្រហាក់ប្រហែលគ្នានឹងជំនឿដែលចាមខ្លួនឯងធ្លាប់មានមកហើយក៏ដោយ។ តើអារ្យធម៌ឥណ្ឌានោះចាក់ឫសជ្រៅដល់ណា? យើងពុំអាចដឹងរឿងនេះដោយគ្រាន់តែមើលថា តើសព្វថ្ងៃនៅសេសសល់អ្វីខ្លះ ក្រោយពីពួកយួនមកវាយលុក, ក្រោយពីការបាក់ទ័ពមួយលើកជាពីរលើកតៗគ្នា រហូតដល់បាត់បង់នគរទាំងមូល? តាមពិត គួរឲ្យភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលយើងឃើញថា នៅតាមភូមិចាមដែលនៅសេសសល់ខ្លះនៅអាណាមប៉ែកខាងត្បូង គេឃើញស្លាកស្នាមឬសំណល់អារ្យធម៌កាលពីជំនាន់ដែលនគរថ្កុំថ្កើង។ រឿងនិទានផ្សេងៗនៅពោរពេញទៅដោយរឿងឥណ្ឌាដែលស្គាល់ពីមុនមក។ មនុស្សស្រីដែលនៅក្នុងខ្ទមកំសត់រយីករយាក នៅតែស្គាល់រឿងព្រេងដែលមាននិយាយពីបដិហារនៃព្រះឥន្រ្ទ គ្រាន់តែសម្បកក្រៅនៃរឿងអស់នោះ មើលទៅជារឿងប្លែក។ តាមពិតគឺជាព្រះឥន្ទ្រដែលមាននៅក្នុងគម្ពីរ "ព្រាហ្មណ"។ គេហៅថា Yaṅ In ពោលគឺព្រះឥន្ទ្រ។ សាច់រឿងនិងអំពើទាំងអស់នៃតួអង្គ គួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់។ ក្នុងរឿងព្រេងចាមនោះ Yaṅ In ជាសម្ព័ន្ធមិត្តនៃព្រះរាជាមួយអង្គ ព្រះនាម Po Tabai ។ ស្តេចនេះមានស្រីកំណាន់ម្នាក់ជាសម្ងាត់ ដែលជាទេពធីតាមួយអង្គ ហើយដែលលាក់ខ្លួននៅក្នុងភ្នកដីរមួយ។ ថ្ងៃមួយ ព្រះឥន្ទ្រដឹងរឿងពិត។ ព្រះអង្គក៏កាឡាខ្លួនទៅជា Po Tabai ហើយចូលទៅរួមរ័កជាមួយនាងទេពធីតាដែលពុំយល់ការអ្វី ស្មានជាកំណាន់របស់ខ្លួន។ ប៉ុណ្ណេះលោកអ្នកអាចយល់ហើយថា នេះជារឿងព្រះឥន្ទ្រដែលបន្លំទៅធ្វើជាកំណាន់នាង "អហល្យា" ដូចមានចែងនៅក្នុងគម្ពីព្រាហ្មណ ហើយលោកអ្នកក៏ពុំទាន់ភ្លេចទេអំពីតួអង្គ "កុត្ស" ដែលសង់សឹកតាមវិធីដដែលនេះមកវិញ។ ដូច្នេះឃើញថាតួអង្គ Yaṅ In នៅតែជាព្រះឥន្ទ្រដដែល គឺព្រះឥន្ទ្រដែលមិនទាន់អស់គុណវិបត្តិ ហើយគឺព្រះឥន្ទ្រដែលពោរពេញទៅដោយចេស្តាផង។ ជនជាតិចាមបន្ថែមថា ព្រះឥន្ទ្របានសាងទំនប់មួយយ៉ាងធំធេង នៅតាមចង្អេះនៃជួរភ្នំអាណាម ទៅខាងលើជ្រលង Song Luy (ជាភាសាចាមគឺ Krauṅ byuh)។ ទំនប់នេះមិនត្រឹមតែទប់ទឹកស្ទឹងទន្លេប៉ុណ្ណោះឡើយ គឺទប់ទាំងទឹកដែលមកពីស្ថានលើផង។ បើ Yaṅ In មិនព្រមបើកទ្វារទឹកណាបន្តិចនោះ គឺភ្លៀងក៏លែងបង្អុរចុះ រីឯទឹកស្ទឹងទន្លេក៏ស្ងួតអស់។ ហេតុនេះហើយបានជានៅឆ្នាំណាដែលមានការរាំងស្ងួត អ្នកស្រុកចាមទៅបន់ស្រន់ Yaṅ In ដើម្បីបានទឹកមកប្រើប្រាស់។ កាលៈទេសៈខុសគ្នាមែនពិត, ភូមិសាស្ត្រខុសគ្នាមែនពិត, ប៉ុន្តែតួអង្គនៅជាទេពដដែល ពោលគឺព្រះឥន្ទ្រ។ ព្រះឥន្ទ្រចាមនេះពុំខុសគ្នាអ្វីពីព្រះឥន្ទ្រនៃគម្ពីរវេទ, នៃគម្ពីព្រាហ្មណ និងគម្ពីសំស្ក្រឹតឯទៀតឡើយ។ ប្រទេសចម្ប៉ាដែលរលាយរលត់ទៅហើយនេះ នៅតែរក្សាមរតកឥណ្ឌាមួយផ្នែកដែរ។

ជាការច្បាស់ហើយដែលថាអារ្យធម៌ឥណ្ឌាបានចូលមកចាក់ឫសជ្រៅនៅចម្ប៉ា។ យើងអាចប្រមាណមើលថា តើភាពត្រចះត្រចង់នោះ

ដល់កំរិតណា ដោយយកល្បះសំស្ក្រឹតដែលលោក Abel Bergaigne បានប្រែពីសិលាចារឹកមួយមកមើល។ កាព្យសំស្ក្រឹតនោះជាកាព្យពោលសសើរដល់ទេពីនៃ Nha-Trang ដែលជំនាន់ដើមជានាង *"ភគវតី កៅដ្ឋារេស្វរី"* ហើយដែលករឹទុកជានាងឧមា គឺជាយានៃព្រះឥសូរ។ នេះជាសម្រង់កាព្យ៖ *"ព្រះនាងដែលនៅជាប់ជាមួយព្រះគម្ពែងនៃវត្តមាននិងអវត្តមាន, ព្រះនាងដែលមានវិស័យពិតប្រាកដជាអ្នកបង្ករបង្កើតជីវិតនៅលើដី..., ព្រះនាងដែលរលាយស្អិតរមួតចូលគ្នាជាមួយអវត្តមាននិងវត្តមាននៅលើលោកនេះ, ដែលជាវត្តមានឬអវត្តមាន, ព្រះនាងដែលមានកាយមួយចំហៀងជាព្រះឥសូរ គឺព្រះគម្ពែងដែលមានព្រះចន្ទ្រជាក្បាំង, ព្រះនាងដែលមានរូបឆោមស្រស់, ព្រះនាងដែលជាចំណែកនៃព្រះគម្ពែង..., ឱ! ភគវតី, យើងខ្ញុំឱនវន្ទាចំពោះចេស្តានៃព្រះនាង"*។ កាព្យនេះលើកដោយព្រះបាទស្រីបរមេស្វរ។ នេះបង្ហាញថាចាមមានទស្សនវិជ្ជា ហើយបញ្ចេញទស្សនៈនោះតាមពាក្យពេចន៍ជាសំស្ក្រឹតដល់កំរិតណា នៅគ.ស.១០៥០។ ឥឡូវយើងមើលមកបញ្ច្រាមប្រទេសវិញ។ កាព្យនោះលើកឡើង ១៦ ឆ្នាំមុនពួក Normands មកវាយលុកប្រទេសអង់គ្លេស។ តើជំនាន់នោះ នៅអឺរ៉ុបអាចមានអ្នកនិពន្ធណាម្នាក់មានទស្សនៈជ្រៅ ព្រមទាំងវោហាគ្រប់គ្រាន់សម្រាប់បញ្ចេញទស្សនៈ ដែលពោពេញទៅដោយគំនិតជ្រៅ ដូចគ្នានឹងពាក្យសសើរនាងភគវតីនោះទេ? ប្រហែលជាអាចមានដែរ ក្នុងចំណោមបព្វជិតដែលធ្វើការស្ងាត់ស្ងៀមក្នុងបណ្ណាល័យដាច់ស្រយាលសម្រាប់អ្នកបួសនៅ Auxerre ឬនៅ Chartres។ តែទោះជាយ៉ាងនេះក្តី តើប្រាកដថាអាចសរសេរជាឡាតាំងបានឬទេ? ត្បិតគ្មានភាសាធម្មតាណាមួយ ដែលអាចជាយាននៃទស្សនវិជ្ជាជ្រៅយ៉ាងនេះបានឡើយ។

យើងបញ្ចប់ការប្រៀបធៀបប៉ុណ្ណោះចុះ ព្រោះអាចយល់បានហើយថាកំរិតវប្បធម៌ចាមដល់ត្រឹមណា ពេលដែលទាហានយួនចាប់ផ្តើមចូលវាយលុកម្តងបន្តិចៗ មានចាញ់ផង មានឈ្នះផង តែដែលទីបំផុតទៅធ្វើឲ្យប្រទេសចម្ប៉ារលំ។ ពេលនោះគឺអារ្យធម៌ចាមចូលមកដល់សម័យកណ្តាល *(Moyen Age)* ហើយ។ មិនខុសគ្នាអ្វីពីបព្វជិតបារាំងដែលពោលអម្បាញ់មិញនេះទេ គឺករីចាមនៅPo Nagar បញ្ចេញទស្សនៈរបស់ខ្លួនបានដោយយកភាសាសំស្ក្រឹតដ៏ត្រចះត្រចង់មកធ្វើជាយាន។ ឯទស្សនៈនោះក៏ដុះដាលឡើងដោយមានឥទ្ធិពលពីបរទេសដែរ។ ម្យ៉ាងទៀត ដូចក្នុងសម័យកណ្តាលនៃអឺរ៉ុបដែរ ចាប់ពីស.វ.ទី១១ ទៅ ចម្ប៉ាដាច់ទំនាក់ទំនងនឹងប្រទេសដែលជាប្រភពនៃអារ្យធម៌ខ្លួន។ នៅអឺរ៉ុបពេលនោះ អារ្យធម៌គ្រឹស្តសាសនាដែលមានឡាតាំងជាយាន លែងចេញពីអ៊ីតាលីមកសាយភាយនៅអឺរ៉ុបទៀតហើយ។ រីឯនៅឥណ្ឌាវិញ គឺសាសនាឥស្លាមចាប់ផ្តើមវាយលុក ធ្វើឲ្យឥទ្ធិពលឥណ្ឌាមកក្រៅចុះអន់ថយ។ "សម័យកណ្តាល" គឺជាពេលដែលប្រជាជាតិមួយបានទទួលមរតកវប្បធម៌ពីអតីតកាលរបស់ខ្លួនសព្វគ្រប់អស់ហើយ ហើយដែលប្រជាជាតិនោះកំពុងរៀបចំឲ្យមានទិដ្ឋភាពថ្មីឡើង បង្កើតជាជំហានអារ្យធម៌ថ្មីទៀត។ យើងទើបនឹងឃើញថាចម្ប៉ាឈានមកដល់ដំណាក់កាលនោះជំនាន់ប្រហាក់ប្រហែលគ្នានឹងអឺរ៉ុបខាងលិចដែរ។ យើងអាចធ្វើការប្រៀបធៀបបន្តិចទៀត ៖ នៅស.វ.ទី១១ និង ១២ ភាសាចាមចាប់ផ្តើមបត់បែនរៀបចំសំអិតសំអាងខ្លួនឲ្យមានលក្ខណៈអក្សរសាស្ត្រខ្ពង់ខ្ពស់ ដោយខ្ចីពាក្យសំស្ក្រឹតច្រើនយកមករៀបចំតាមលំនាំខ្លួន តាមវេយ្យាករណ៍ខ្លួន។ ប៉ុន្តែបន្ទាប់មកក៏មានការបែកផ្លូវគ្នា។ នៅបស្ចឹមប្រទេស ដំណើរជីវិតឬព្រឹត្តិការណ៍ផ្សេងៗក្រោយមកបង្កើតបានជាអារ្យធម៌ថ្មីនៅលើមូលដ្ឋានអារ្យធម៌សម័យកណ្តាលនោះ។ នេះមកអំពីប្រជាជាតិទាំងនោះពង្រីកទឹកដី ធ្វើដំណើរទៅទីឆ្ងាយ ហើយបង្កើតបានជាសហគមន៍ធំៗនៅពាសវាលពាសកាល។ រីនៅឯឆ្នេរសមុទ្ររបស់ខ្លួនវិញ ជនជាតិចាមមិនដឹងជារុករានឬរីកសាយទៅណាទៀតបានឡើយ ណាមួយឆ្នេរសមុទ្រនោះក៏គ្មានអំណោយផលផង។ ចាមហាក់ដូចជាកូន ដែលឥណ្ឌាជាមេបាទុកឲ្យនៅកំព្រា។ ភូមិសាស្ត្រក៏គ្មានអំណោយផល ត្បិតនៅខាងជើងមានប្រទេសដូចជាតុងកឹងជាដើមដែលពោពេញទៅដោយមនុស្សនិងដោយកំលាំង។ បើថ្លឹងជញ្ជីង ឃើញថាមិនស្មើគ្នាឡើយ។ ការដែលប្រជាជាតិពីរដល់គ្នា គឺប្រជាជាតិខ្សោយដែលតែងរលំ ប៉ុន្តែខ្សោយនោះគឺខ្សោយកំលាំងកាយ ពុំមានន័យថាខ្សោយខាងអារ្យធម៌ឡើយ។ អ្វីដែលយើងដឹងនៅពេលនេះ គឺប្រទេសចម្ប៉ាមានពេលគ្រប់គ្រាន់នឹងទទួលអារ្យធម៌ឥណ្ឌាក្នុងរយៈពេលច្រើនសតវត្សដែលជាសតវត្សដ៏រុងរឿងរបស់ខ្លួន។ មូលដ្ឋានអារ្យធម៌ចាស់ពេលនោះរឹងប៉ឹងមាំ ល្មមឲ្យប្រទេសចម្ប៉ាទទួលឥទ្ធិពលពីក្រៅដោយយកមកកែច្នៃ បត់បែនតាមផ្នត់គំនិតរបស់ខ្លួន រហូតដល់បង្កើតបានជាអារ្យធម៌ដ៏ត្រចះត្រចង់ថ្មីមួយរបស់ខ្លួនផង។ អារ្យធម៌ថ្មីដែលបម្រុងនឹងរីកសាយនោះ យើងពុំអាចដឹងថាជាអ្វីប្រាកដឡើយ ត្បិតពេលដែលចាប់ពន្លកនឹងលូតលាស់ឡើង ប្រវត្តិសាស្ត្របានបញ្ចប់វាសនាប្រទេសចម្ប៉ា នៅត្រឹមនោះ។

## កំណត់អ្នកប្រែ

អត្ថបទនៃលោក Paul Mus នេះ មិនគួរនឹងខ្ញុំហ៊ានយកមកប្រែឡើយ ត្បិតការលំបាកមានច្រើនពន់ប្រមាណ។ ម្យ៉ាងមកពីភាសា ឬពាក្យពេចន៍នោះជ្រៅ ប៉ុន្តែការលំបាកធំបំផុត គឺគំនិតពិចារណាគ្រប់បន្ទាត់, គ្រប់ឃ្លា, ជ្រៅហួសលើសវិស័យប្រាជ្ញានៃជនសាមញ្ញទូទៅ។ យ៉ាងណាក៏ដោយ ខ្ញុំយល់ថា សារៈសំខាន់នៃអត្ថបទនោះខ្លាំងលើសលុប ធ្វើឲ្យខ្ញុំប្រថុយប្រថានប្រែមកជាភាសាជាតិ ដើម្បីសម្រួលការឲ្យនិស្សិត ឬអ្នកស្រាវជ្រាវជាតិខ្លះៗ។ ខ្ញុំដឹងច្បាស់ណាស់ថាសេចក្ដីជាខ្មែរមានការខ្វះខាតឬធ្គាំធ្គងច្រើន តែបំណងខ្ញុំគឺធ្វើយ៉ាងណាឲ្យអ្នកសិក្សាជាភាសាខ្មែរអាចចាប់យកគំនិតធំៗនោះបានខ្លះ។ សូមអស់លោកអ្នកអានយល់ថាការ “ប្រែ” នេះគ្រាន់តែជាការ “ប្រែសម្រួល” ប៉ុណ្ណោះ ទោះបីជាដូច្នេះហើយក៏នៅតែពុំទាន់ “ស្រួល” យល់ក្ដី។

ស៊ីយ៉ុន សុភារិទ្ធ